**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciencess Economiques

Royal University of Law and Economics


សារណាបញ្ចប់ការសិក្សា

# ការបង្កើតទីក្រុងរណប

**(ផលប៉ះពាល់ និងគុណប្រយោជន៍នៃការបង្កើតទីក្រុងរណបនៅរាជធានីភ្នំពេញ)**

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ញូន ស្រីនីត**

**លោក ម៉ក់ វាសនា**

សាស្ត្រាចារ្យណែនាំ

**លោក ជុំ អ៊ីម**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមខ្ញុំបាទ-នាងខ្ញុំ ទាំងពីរនាក់ជានិស្សិតនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះលោកឪពុក-អ្នកម្តាយ ដែរលោកបានផ្តត់ផ្គង់ទាំងផ្នែកសម្ភារៈ និងហិរញ្ញវត្ថុដែលជាផ្នែកមួយពុំអាចខ្វះបានក្នុងការសិក្សារៀនសូត្រតាំងតែពីកម្រិតដំបូងរហូតដល់បញ្ចាប់ការសិក្សានៅកម្រិតថ្នាក់បរិញ្ញបត្រមួយនេះ។ ទន្ទឹមនឹងនេះលោកគ្រូ-អ្នកគ្រូ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសុទ្ធសឹងតែជាអ្នកមានគុណបំណាច់ធំធេង ដែរពុំអាចមើលរំលងបានចំពោះពួកខ្ញុំ តាមរយៈការបង្ហាត់បង្ហាញទាក់ទិននឹងទ្រឹស្តី រួមទាំងផ្សារភ្ជាប់ជាមួយការអនុវត្តជាក់ស្តែងក្នុងសង្គមបច្ចុប្បន្នផងដែរ។

ក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះខ្ញុំបាទ-នាងខ្ញុំ ពិតជាទទួលបាននូវការអប់រំ-ទូន្មានយ៉ាងច្រើនព្រមទាំងប្រកបដោយគុណភាពពីសំណាក់លោកគ្រូ-អ្នកគ្រូ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាពិសេស **លោកគ្រូ ដុំ អ៊ីម** ដែលជាគ្រូដឹកនាំសារណារបស់ក្រុមពួកខ្ញុំ ដោយលោកបានខិតខំប្រឹងប្រែងព្រមទាំងលះបង់ទាំងពេលវេលា និងកម្លាំងកាយចិត្តតាំងតែពីការចាប់ផ្តើមដំបូងរហូតដល់ការបញ្ចាប់សារណាមួយដោយជោគជ័យ។

ការចូររួមចំណែករបស់ **លោកគ្រូ ដុំ អ៊ីម** នាពេលនេះពិតជាបានបញ្ជាក់នូវទឹកចិត្តដ៏ថ្លៃថ្លាជាមួយនឹងគុណតម្លៃនៃគ្រូបង្រៀនដែលពុំអាចពណ៌នាបានឡើយចំពោះក្រុមខ្ញុំបាទ-នាងខ្ញុំ។ ជាក់ស្តែងសមិទ្ធផលនៃការបញ្ចប់សារណាដោយជោគជ័យនេះគឺជា ឧទាហរណ៍មួយបញ្ជាក់យ៉ាងច្បាស់ថា លោកពិតជាបានដើរតួនាទីយ៉ាងសំខាន់។

ជាចុងបញ្ចាប់ខ្ញុំបាទ-នាងខ្ញុំ សូមប្រសិទ្ធពរ ជូនចំពោះលោកឪពុក-អ្នកម្តាយ លោកគ្រូ-អ្នកគ្រូ សាស្ត្រាចារ្យ ជាពិសេស **លោកគ្រូ ដុំ អ៊ីម** សូមទទួលបាននូវសុភមង្គល សិរីសួស្តី បវរមហាប្រសើរ និងសមប្រកបតែនឹងពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រោមប្រធានបទ "ការបង្កើតទីក្រុងរណប" គឺជាស្នាដៃដំបូងរបស់ក្រុមយើងខ្ញុំ ដែលបានរៀបចំចងក្រងឡើងសម្រាប់ជាកម្មវត្ថុក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ដើម្បីរៀបចំបង្កើតឡើងបាននូវសារណាមួយនេះ យើងខ្ញុំបានព្យាយាមស្វែងរកនូវឯកសារសំខាន់ៗជាច្រើនគ្រប់ប្រភព ដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គេហទំព័ររបស់អង្គភាពទាំងស្ថាប័នរដ្ឋ និងឯកជន ដែរមានផ្ទុកនូវឯកសារទាំងនេះ បណ្ណាគារដែរមានឯកសារទាក់ទង គួបផ្សំនឹងការណែនាំបន្ថែមរបស់សាស្ត្រាចារ្យណែនាំសារណារបស់ក្រុមយើងផងដែរ។ ក្នុងការចងក្រង យើងខ្ញុំបានប្រើប្រាស់ឯកសារទាំងនោះ យកមកស្វែងយល់ និងចងក្រងឡើងតាមលំដាប់សំដោយទៅតាមគម្រូប្លង់នៃសារណាដែរក្រុមយើងខ្ញុំបានតាក់តែងឡើងពីដំបូង។

សព្វថ្ងៃនេះ វិស័យអចលនទ្រព្យកំពុងមានសន្ទុះជាមួយភាពរីកលូតលាស់គួរឲ្យកត់សម្គាល់។ មានកត្តាជាច្រើនដែរជម្រុញឲ្យវិស័យនេះរីកចម្រើនយ៉ាងនេះ ដូចជាកត្តាសង្គម កត្តាសុខសន្តិភាពជាតិ កត្តាធនធានធម្មជាតិដែរកម្ពុជាមាន និងកត្តាកំណើនខ្ពស់នៃសេដ្ឋកិច្ចជាតិជាដើម។ ក្នុងផ្នែកដែរសំខាន់ជាងគេ ដែលជម្រុញឲ្យវិស័យអចលនទ្រព្យកម្ពុជាមានសក្កដានុពលនោះគឺ សន្ទុះនៃតម្រូវការជាច្រើននៃសំណង់អគារពាណិជ្ជកម្ម និងលំនៅឋាន និងលំហូរចូរយ៉ាងច្រើនសន្ធឹកសន្ធាប់នៃវិនិយោគិនបរទេស។ បើពុំមានតម្រូវការដូចដែរបានរៀបខានមុខនេះទេ ការរៀបចំក្រុង និងការបង្កើតឲ្យមានទីក្រុងរណបថ្មីៗក៏ប្រហែលជាមិនអាចកើតមានដែរនេះបើនិយាយជាបែបទូលាយ តែបើនិយាយបែបចង្អៀតការរៀបចំអោយមានការបង្កើតទីក្រុងរណប គឺធ្វើឡើងដោយការជួយសម្រួលបន្ទុកនៃទីក្រុងចាស់ដែរមានសភាពតូចង្អៀត តែបែរជាមានប្រជាជនជាច្រើនដែរលើសពីសមត្ថភាពដែរក្រុងចាស់អាចទ្រាំទ្របាន។ ដើម្បីគ្រប់គ្រងបាននូវស្ថានការណ៍បែបនេះ រាជរដ្ឋាភិបាល ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវមានយន្តការ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងវិស័យដីធ្លីទាំងនោះប្រកបដោយប្រសិទ្ធិភាព និងគុណភាព។

ដោយមានការយល់ឃើញបែបនេះហើយ បានជាក្រុមយើងខ្ញុំមានការចាប់អារម្មណ៍និងសម្រេចជ្រើសរើសប្រធានបទមួយនេះយកមកសិក្សាស្វែងយល់ និងសង្ឃឹមថាអាចទទួលបានចំណេះដឹងថ្មីៗទាក់ទងនឹងវិស័យផ្សេងៗក្រៅពីវិស័យនៃជំនាញដែរយើងខ្ញុំកំពុងសិក្សា។ ការសិក្សានេះបានផ្តល់សារៈសំខាន់ជាច្រើនមកដល់យើងខ្ញុំថែមទាំងបានបន្ថែមចំណេះដឹងទាក់ទងនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវកម្ពុជានិង

បានយល់ដឹងពីប្រព័ន្ធនៃការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋទៅលើការអនុវត្តជាក់ស្តែងក្នុងសង្គម ដែលជាការចាំបាច់សម្រាប់និស្សិតដូចជាយើងខ្ញុំ។

ទោះជាមានការយកចិត្តទុកដាក់ខ្ពស់ និងការពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក្តី ក៏កំហុសអចេតនានឹងកើតមានឡើងជាក់ជាមិនខាន។ ក្នុងករណីនេះ យើងខ្ញុំសូមការអនុញ្ញាតធ្វើអធ្យាស្រ័យចំពោះកំហុសឆ្គងទាំងនោះផង និងក្រុមយើងខ្ញុំបើកចិត្តទូលាយស្វាគមន៍រាល់មតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីឲ្យស្នាដៃក្រោយៗទៀតមានសភាពល្អប្រសើរឡើង។

# មាតិកា

**ទំព័រ**


**សេចក្ដីផ្ដើម** ........................................ **1**

១. លំនាំបញ្ហា ........................................ 1

២. ចំណោទបញ្ហា ........................................ 2

៣. គោលបំណងនៃការស្រាវជ្រាវ ........................................ 2

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................ 3

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ 3

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ 4

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ 5


## ជំពូកទី១

## ផលប្រយោជន៍ទូទៅនៃទីក្រុងរណប


**១.១. សញ្ញាណទូទៅ** ........................................ 6

**១.២. និយមន័យ ទីក្រុង និង ទីក្រុងរណប** ........................................ 9

**១.៣. បរិបទទូទៅនៃមូលហេតុនាំឲ្យមានការរៀបចំក្រុង** ........................................ 10

១.៣.១. កំណើនប្រជាជន និងដង់ស៊ីតេ ........................................ 10

១.៣.២. ការដាក់សម្ពាធបរិស្ថាន ........................................ 11

១.៣.៣. គុណភាពនៃការរស់នៅ ........................................ 12

១.៣.៤. កត្តាភាពក្រីក្រ ........................................ 12

*ក.ភាពក្រីក្រនៅតាមជនបទ ........................................ 12*

*ខ. ភាពក្រីក្ររបស់ទីក្រុង ........................................ 13*

**១.៤. លក្ខណៈសម្បត្តិនៃទីក្រុងរណប** ........................................ 13

១.៤.១. ហេដ្ឋារចនាសម្ព័ន្ធ ........................................ 14

១.៤.២. សំណង់អគារនានា ........................................ 14

*ក. ការអនុញ្ញាតអោយសាងសង់ ជួសជុល ឬរុះរើ ........................................ 15*

*ខ. ការគ្រប់គ្រងគម្រោងប្លង់ ........................................ 16*

*គ. ការគ្រប់គ្រងការងារសាងសង់ឬរុះរើ ........................................ 16*

*ឃ. ការប្រើប្រាស់សំណង់ ............ 17*
១.៤.៣. ប្រព័ន្ធសុវត្ថិភាព ............ 17
**១.៥. ទាក់ទាញការវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុក** ............ 18
១.៥.១. បង្កើតឱកាសការងារជូនប្រជាជន ............ 19
១.៥.២. លទ្ធភាពនៃការនាំចេញនៅនឹងកន្លែង ............ 19
១.៥.៣. លើកកម្ពស់ផ្នែកសេដ្ឋកិច្ច ............ 20
*ខ. ចំណូលប្រជាជនក្នុងស្រុកមានការកើនឡើង ............ 21*

**ជំពូកទី២**

## ការទទួលសិទ្ធិដើម្បីទទួលបានការអនុញ្ញាតលើទីក្រុងរណបនៅរាជធានីភ្នំពេញស្របតាមផែនការរូបវន្តទីក្រុង

**២.១. ផែនការរូបវន្តទីក្រុង និងនីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង** ............ 22
២.១.១. ផែនការរូបវន្តទីក្រុង ............ 22
*ក.ប្លង់គោលប្រើប្រាស់ដី ............ 22*
*ខ.ផែនការប្រើប្រាស់ដី ............ 23*
*គ.ប្លង់លម្អិតនគរូបនីយកម្ម ............ 25*
២.១.២. នីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង ............ 25
*ក. ការផ្សព្វផ្សាយគម្រោង និងការចុះសិក្សាបឋមលើទីតាំង និងការប្រមូលទិន្នន័យ ............ 26*
*ខ. ការវិភាគទិន្នន័យ និងការរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រ ............ 27*
*គ. ការបិទផ្សាយជាសាធារណៈ ............ 28*
*ឃ. ការកែសម្រួលចុងក្រោយ ............ 28*
*ង. ការរៀបចំគម្រោងអទិភាព ............ 29*
*ច. ការសម្រេចលើប្លង់គោលប្រើប្រាស់ដី ............ 29*
**២.២. ការគ្រប់គ្រងការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង និងការកសាងទីក្រុង** ............ 30
២.២.១. ក្រសួងមានសមត្ថកិច្ចគ្រប់គ្រងកិច្ចការនគរូបនីយកម្ម និងសំណង់ ............ 30
២.២.២. នីតិវិធីនៃការស្នើសុំការអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ ............ 31
**២.៣. ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាសាធារណៈជូនសាធារណៈជន** ............ 33
២.៣.១. ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ............ 33
២.៣.២. សំណង់ផ្តល់សេវាសាធារណៈជូនសាធារណៈជន ............ 34

២.៣.៣. អំពីលំហរសាធារណៈ ........................................ 34

**២.៤. សកម្មភាពអភិវឌ្ឍន៍បន្ត និងវិនិយោគសាធារណៈ** ........................................ 34

២.៤.១. ការកសាង និងការអភិវឌ្ឍបន្តទីក្រុងរណបនានាដូចជា កោះពេជ្រ ជ្រោយចង្វារ និងបឹងកក់ ........................................ 35

២.៤.២. ជម្រុញឲ្យមានការអភិវឌ្ឍទីក្រុងរណបកាន់តែច្រើនឡើងៗ ........................................ 36

## ជំពូកទី៣

## ផលប៉ះពាល់ដែលកើតចេញពីការអភិវឌ្ឍទីក្រុងរណប

**៣.១. ផលប៉ះពាល់** ........................................ 37

៣.១.១. បរិស្ថាន ........................................ 37

៣.១.២. ទំនាស់ដីធ្លីជាមួយប្រជាជននៅទីតាំងដែលត្រូវអភិវឌ្ឍន៍ ........................................ 38

*ក. ប្រជាជនរស់នៅទីតាំងដែលត្រូវអភិវឌ្ឍន៍ប៉ុន្តែគ្មានប័ណ្ណកម្មសិទ្ធិ ........................................ 39*

*ខ. កិច្ចអន្តរាគមន៍ក្នុងការដោះស្រាយវិវាទដីធ្លីជូនប្រជាជន ........................................ 40*

*គ. លទ្ធផលក្រោយវិវាទដីធ្លីត្រូវបានបញ្ចប់ ........................................ 40*

**៣.២. បញ្ហាផ្សេងៗត្រូវបានចោទឡើង** ........................................ 41

៣.២.១. កត្តាភូមិសាស្ត្រ ........................................ 41

៣.២.២. ប្រជាជនក្នុងតំបន់អភិវឌ្ឍន៍ ........................................ 42

**៣.៣. គុណភាពនៃសំណង់នានាក្នុងទីក្រុងរណប** ........................................ 42

៣.៣.១. ការត្រួតពិនិត្យ និងការផ្តល់សិទ្ធិសាងសង់ទៅម្ចាស់គម្រោងដោយមន្ត្រីមានសមត្ថកិច្ច ........................................ 42

៣.៣.២. ការទទួលខុសត្រូវលើគុណភាពសំណង់ដែលបានសាងសង់រួច ........................................ 42

*ក. សំណង់អគារសាងសង់រួចតែគ្មានគុណភាព ........................................ 43*

*ខ. អ្នកដែលត្រូវចូលរួមទទួលខុសត្រូវចំពោះសំណង់ទាំងនោះ ........................................ 43*

**សេចក្តីសន្និដ្ឋាន ........................................ 46**

**វាយតម្លៃនិងអនុសាសន៍ ........................................ 47**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ការអភិវឌ្ឍទីក្រុងជាកិច្ចការមួយដែរបណ្តាប្រទេសជុំវិញសកលលោកបានយកមកធ្វើការប្រកួតប្រជែងគ្នា ក្នុងនោះមានទាំងបណ្តាប្រទេសអភិវឌ្ឍន៍ក្តី និងប្រទេសកំពុងអភិវឌ្ឍន៍ក្តី បានខិតខំប្រឹងប្រែងធ្វើយ៉ាងសកម្ម។ ដើម្បីសម្រេចបាននូវភាពរីកចម្រើនលូតលាស់វិស័យសេដ្ឋកិច្ចរបស់ខ្លួន ប្រទេសទាំងនោះបានប្រើប្រាស់ធនធាន ដែរខ្លួនមានមកកែច្នៃ អភិវឌ្ឍន៍ រៀបចំ និងកែលម្អ ក្នុងគោលបំណងបង្កើនចំណូលបន្ថែមក្នុងចរន្តសេដ្ឋកិច្ចជាតិ របស់ខ្លួន។ ជាក់ស្តែងប្រទេសទំនើបមួយចំនួនបានកំពុងប្រឹងប្រែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម បច្ចេកវិទ្យា និង វិទ្យាសាស្ត្រ ដើម្បីបម្រើដល់តម្រូវការជាចាំបាច់ក្នុងជីវភាពរស់នៅរបស់មនុស្សនាពេលបច្ចុប្បន្ន ក៏ប៉ុន្តែបណ្តាប្រទេស មួយចំនួនផ្សេងទៀតក៏បានចាត់ទុកវិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្មជាវិស័យនាំមុខក្នុងការស្តារនិង អភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសរបស់ខ្លួន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបន្តធ្វើកំណែទម្រង់ ស្ថាប័នរដ្ឋឲ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អ ការផ្តល់គណនីយភាព សេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាល កម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍន៍ តាមរយៈការ ធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឲ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាម វិស័យប្រកបដោយសុខដុមរម្យនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ក្នុងគោលដៅធានាការគ្រប់គ្រង ការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិ ព្រមទាំងការអភិវឌ្ឍតំបន់ ក្នុងរាជធានី ក្រុង ប្រកបដោយចីរភាព គណៈកម្មាការអន្តរក្រសួងដែលបច្ចុប្បន្នជាគណៈកម្មាធិការរៀបចំដែនដីនិង នគរូបនីយកម្មថ្នាក់ជាតិដឹកនាំដោយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំនូវប្លង់គោលប្រើប្រាស់ដី រាជធានីភ្នំពេញឆ្នាំ២០៣៥ ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសអភិវឌ្ឍន៍ដែនដីនៃរាជធានីភ្នំពេញ ទាំងមូល ស្របតាមចក្ខុវិស័យនៃគោលនយោបាយដីធ្លី ជាពិសេសគោលនយោបាយជាតិស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ការរៀបចំអោយមានការបង្កើតក្រុងរណប ដោយមើលឃើញពីសារៈសំខាន់ដល់សេដ្ឋកិច្ចកម្ពុជាព្រមទាំងប្រព័ន្ធនៃការរស់នៅបែបសម័យទំនើប។ រាជរដ្ឋាភិបាលបានដាក់អោយមានការរៀបចំបែបនេះ ក៏ពុំមានអ្វីដែលចំឡែកនោះដែរ ពោលគឺនៅតាមប្រទេសជាច្រើនបានអនុវត្តរួចមកហើយជាលទ្ធផលក៏ទទួលបានភាពជោគជ័យគួរឲ្យកត់សម្គាល់ផងដែរ ដូច្នេះការបង្កើតឲ្យមានការបង្កើតទីក្រុងរណបត្រូវតែបង្កើតឡើង និងត្រូវបង្កើតឲ្យច្រើនទៀតផង។

## ២. ចំណោទបញ្ហា

នាពេលបច្ចុប្បន្ន វិស័យអចលនវត្ថុនៅកម្ពុជាបាននិងកំពុងមានសន្ទុះខ្លាំងខ្លាជាមួយភាពពេញនិយមសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្នុងការវិនិយោគ ក្នុងការទាញផលប្រយោជន៍ជាច្រើនខាងផ្នែកសេដ្ឋកិច្ច។ ក្នុងន័យនេះ ដើម្បីរក្សាបាននូវនីត្យានុកូលភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងការគ្រប់គ្រងបាននូវហានិភ័យទាំងឡាយដែលកើតមានឡើងពីការប្រើប្រាស់ដី ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធបានខិតខំបង្កើតនូវយន្តការ និងលិខិតបទដ្ឋានគតិយុត្តគាំទ្រជាច្រើន សម្រាប់អនុវត្តការងារគ្រប់គ្រងរបស់ខ្លួន។ បើទោះបីជាមានយន្តការ និងបទដ្ឋានគតិយុត្តដែរបានចេញមកជាច្រើនក៏ដោយ តែភាពចន្លោះខ្វះខាតនៅតែជៀសមិនផុតដែលជាហេតុទាមទារឲ្យរដ្ឋាភិបាលមានការយកចិត្តទុកដាក់ជាពិសេស ក៏ព្រោះតែការបង្កើតទីក្រុងរណបនីមួយៗសុទ្ធសឹងតែមានផលប៉ះពាល់ជាខ្លាំងទៅនឹងប្លង់គោលប្រើប្រាស់ដីធ្លី ជាមួយនិងទិសដៅនៃគោលនយោបាយការអភិវឌ្ឍរយៈពេលខាងមុខទាំងរយៈពេលវែង និងខ្លី។ ដូចនេះដើម្បីស្រាយចម្ងល់នូវរាល់បញ្ហាទាំងនេះ ដែលកំពុងកើតមានឡើងនូវរាជធានីភ្នំពេញ ការសិក្សាស្រាវជ្រាវក្រោមប្រធានបទនេះនឹងធ្វើការបកស្រាយទៅលើសំណួរសំខាន់ៗចំនួន២គឺ៖

១. តើអ្វីទៅជាទីក្រុងរណប? ហេតុអ្វីត្រូវបង្កើតទីក្រុងរណប និងត្រូវឆ្លងកាត់នីតិវិធីអ្វីខ្លះ?

២. តើមុននឹងក្រោយនៃការអភិវឌ្ឍទីក្រុងរណបនូវរាជធានីភ្នំពេញ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទទួលបានផលប្រយោជន៍ និងផលប៉ះពាល់យ៉ាងណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះក្នុងគោលបំណងធំៗចំនួន២ គឺ៖

ក. ដោយសារតែនូវក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្នកំពុងមានសន្ទុះខ្លាំងទៅលើវិស័យអចលនវត្ថុស្ទើរតែទូទាំងប្រទេសកម្ពុជា ដើម្បីជាការស្វែងយល់ឲ្យកាន់តែស៊ីជម្រៅទាក់ទិននឹងការវិនិយោគទាំងនេះ ជាពិសេសការបង្កើតទីក្រុងរណប។ ដោយយល់ឃើញថាការបង្កើតទីក្រុងរណបក៏មានភាពទាក់ទងខ្លាំងជាមួយនឹងច្បាប់ជាច្រើនហើយក៏មានចំណុចជាច្រើនដែលបង្កើតជាបញ្ហាតាមរយៈការបង្កើតទីក្រុងរណបក៏ប៉ុន្តែពុំមានច្បាប់ណាមួយបានចែងជាមុនសម្រាប់កាត់សេចក្តីបន្ទាប់ពីបញ្ហាបានកើតមានឡើយ។ បើទោះបីជាមានលិខិតបទដ្ឋានគតិយុត្តបាន

ចែងជាហូរហែក្នុងនោះរួមមានព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្ដីប្រកាសជាច្រើនក៏ដោយ តែឯកសារមួយចំនួនហាក់មិនបានដាក់បង្ហាញជាសាធារណៈជូនឲ្យសាធារណៈជនបានស្វែងយល់ឲ្យកាន់តែច្បាស់នោះទេ ហើយវាក៏ជាមូលហេតុចម្បងផងដែរ។

ខ. ដើម្បីចងក្រងជាសំណុំឯកសារមួយចំនួនដែរទាក់ទិននឹងការបង្កើតទីក្រុងរណប បើទោះជាវាមិនបានក្ដាប់បានគ្រប់ជ្រុងជ្រោយក៏ដោយក៏វាបានមួយផ្នែកសម្រាប់អ្នកដែរចង់ដឹងពី ផលប្រយោជន៍ ផលប៉ះពាល់ និងនីតិវិធីនៃការបង្កើតទីក្រុងរណបនៅរាជធានីភ្នំពេញ។ ហើយការស្រាវជ្រាវមួយនេះក៏ឲ្យពួកយើងបានស្រាយចម្ងល់ជាច្រើនស្ដីពីគោលនយោបាយនៃការប្រើប្រាស់ដីរបស់រាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងដីរយៈពេលវែងផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ទំហំ និងដែនកំណត់នៃការស្រាវជ្រាវទៅលើប្រធានបទនេះ ក្រុមយើងខ្ញុំបានផ្ដោតសំខាន់ត្រឹមគុណសម្បត្តិ និងផលប៉ះពាល់ដែរកើតចេញពីការអភិវឌ្ឍទីក្រុងរណបនៅរាជធានីភ្នំពេញ។ ជាមួយនិងការបង្ហាញពីក្រសួងដែលមានសមត្ថកិច្ច ព្រមទាំងក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធជាមួយផងដែរ ហើយក្នុងនោះក៏បានរំលេចនូវនីតិវិធីនៃការទទួលបានសិទ្ធិក្នុងការអភិវឌ្ឍទីក្រុងរណបនូវរាជធានីភ្នំពេញ ដែលវាស្របទៅតាមបទដ្ឋានគតិយុត្តិ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងផ្ដល់សារៈសំខាន់ជាច្រើនដល់ក្រុមយើងខ្ញុំ ក៏ដូចជាអ្នកសិក្សានានាដូចជា៖

- បានស្គាល់ និងយល់ដឹងច្បាស់អំពីស្ថានភាពទូទៅនូវវិស័យគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនូវរាជធានីភ្នំពេញ។ ការយល់ដឹងនេះ អាចជាយានដល់បុគ្គលគ្រប់រូបសម្រាប់ជាចំណេះដឹងទូទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន និងអាចយកទៅអនុវត្តន៍ក្នុងការសិក្សា ការងារ និងកិច្ចពិភាក្សាផ្សេងៗ។ ការយល់ដឹងនេះក៏អាចចូររួមអភិវឌ្ឍន៏វិស័យអចនទ្រព្យនៅកម្ពុជាផងដែរ ពីព្រោះសកម្មភាពទិញលក់ដីមានភាពសកម្មជាខ្លាំង។
- បានស្វែងយល់ពីរបៀបរបប និងយុទ្ធសាស្ត្ររបស់ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងរាជរដ្ឋាភិបាលក្នុងការអនុវត្តការងារគ្រប់គ្រងនូវការប្រើប្រាស់ដីដោយប្រសិទ្ធិភាពខ្ពស់នូវរាជធានីភ្នំពេញ។ លើសពីនេះយើងក៏បានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តិនានាដែលមាន និងកំពុងរៀបចំតាក់តែងបង្កើតឡើងសម្រាប់គាំទ្រដល់ការគ្រប់គ្រងរបស់ស្ថាប័ន។
- បានជ្រួតជ្រាប និងស្វែងយល់អំពីនីតិវិធីមួយចំនួនក្នុងការស្នើសុំអាជ្ញាបណ្ណសម្រាប់វិនិយោគវិស័យអចលនវត្ថុ។ សារៈសំខាន់មួយនេះ ពិតជាបានចូររួមចំណែកជាច្រើនក្នុងការពង្រឹងគុណភាពនៃការ

គ្រប់គ្រងការប្រើប្រាស់ដីធ្លី ដោយយល់ឃើញថាចំណេះដឹងដែរទាក់ទិននឹងការស្នើសុំអាជ្ញាបណ្ណនេះធ្វើឲ្យរាល់សកម្មភាពវិនិយោគដីធ្លីត្រូវបានប្រព្រឹត្តឡើងប្រកបដោយនីត្យានុលកូល និងធ្វើឲ្យសង្គមជាតិកម្ពុជាក្លាយជានីតិរដ្ឋ។

និយាយជារួម សារៈសំខាន់ដូចដែលបានរៀបរាប់ខាងលើ មិនត្រឹមតែសម្រាប់យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវប៉ុណ្ណោះទេ ពោលវាជាផ្នែកមួយដ៏សំខាន់នៃចំណេះដឹងទូទៅរបស់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន គ្រប់បុគ្គលទាំងឡាយ គ្រប់ស្រទាប់វណ្ណៈ។ ខ្លឹមសារនៃការសិក្សាស្រាវជ្រាវនេះបានចូររួមចំណែកក្នុងការអភិវឌ្ឍចំណេះដឹងរបស់មនុស្សគ្រប់រូបឲ្យបានស្វែងយល់ពីទិដ្ឋភាពទូទៅនៃការប្រើប្រាស់ដីនូវរាជធានីភ្នំពេញ ទិដ្ឋភាពគតិយុត្តិក្នុងការគ្រប់គ្រងការវិនិយោគអចលនវត្ថុ យន្តការនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងរបស់មន្ត្រីមានសមត្ថកិច្ច ដែលទាំងអស់នេះបានជួយពង្រឹង ការអនុវត្តច្បាប់ និងចូររួមបង្កើនភាពងាយស្រួលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រនៃស្រាវជ្រាវចម្រុះដោយផ្អែកទៅលើឯកសារបទដ្ឋានគតិយុត្តិជាច្រើនដែររួមមានទាំងអនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ផងដែរ ក្រៅពីនោះក៏បានដកស្រង់ចេញពីបណ្ដាពត៌មានដែរបានបង្ហាញពីទិដ្ឋភាពជាក់ស្ដែង។ ដើម្បីសម្រេចបាននូវការសិក្សាស្រាវជ្រាវនិងចងក្រងឡើងបាននូវសារណានេះ វិធីសាស្ត្រចម្បងជាងគេ គឺឯកសារដែលមាននូវក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងនោះក៏មានឯកសារខ្លះបានមកពីក្រសួងផ្សេងៗដែលមានការពាក់ព័ន្ធ។ ចំពោះឯកសារដែរពួកខ្ញុំទទួលបានដើម្បីយកមកដាក់បញ្ចូលក្នុងសារណាមួយនេះ គឺយើងខ្ញុំបានចុះធ្វើការស្រាវជ្រាវ និងស្នើសុំដល់ទីស្ដីការក្រសួងផ្ទាល់ ដោយការទាញយកពីវេបសាយផ្លូវការរបស់ក្រសួងដែរបានដាក់បង្ហាញជាសាធារណៈ និងតាមបណ្ដាសារពត៌មានធំៗទាំងក្នុងស្រុកនិងក្រៅស្រុក ជាមួយគ្នានោះក៏បានសាកសួរពត៌មានចាំបាច់មួយចំនួនពីសំណាក់អ្នកដែររស់នៅភូមិសាស្ត្រនៃការអភិវឌ្ឍទីក្រុងរណបដែលមានសារៈប្រយោជន៍ដល់ការស្រាវជ្រាវខណៈពេលនោះយើងខ្ញុំក៏បានចុះទៅទីតាំងផ្ទាល់ក្នុងគោលបំណងឲ្យកាន់តែប្រាកដថារាល់ពត៌មានដែរទទួលបានពុំមានការបំភ័ន្តឡើយ។

ទន្ទឹមនឹងការស្រាវជ្រាវនូវឯកសារទាំងនោះ និងដើម្បីឲ្យការសិក្សាស្រាវជ្រាវកាន់តែមានភាពត្រឹមត្រូវទៅតាមតថភាពជាក់ស្ដែង ទាំងទិដ្ឋភាពច្បាប់និងបច្ចេកទេស ក្រុមយើងខ្ញុំបានសាកសួរពត៌មានសំខាន់ៗ និងស្រាយនូវមន្ទិលសង្ស័យនានាដែលយើងខ្ញុំមាន ពីសំណាក់មន្ត្រីជំនាញមួយចំនួននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលពួកគាត់ជាអ្នកអនុវត្តផ្ទាល់ទាក់ទិននឹងវិស័យទាំងនេះ។ យោងតាមវិធីសាស្ត្រដូចបានរៀបរាប់ខាងលើ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាការសិក្សាស្រាវជ្រាវនេះនឹងមានភាពត្រឹមត្រូវទៅតាមទិដ្ឋភាពច្បាប់និង

ទិដ្ឋភាពជាក់ស្តែងក្នុងសង្គមព្រមទាំងប្រកបដោយគុណភាព ជាមួយភាពដែលអាចជឿទុកចិត្តបាន សម្រាប់អ្នកមានបំណងចង់សិក្សាទៅការអភិវឌ្ឍទីក្រុងរណបមួយនេះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវភាពងាយស្រួលក្នុងការស្វែងយល់ និងយល់ដឹងរបស់អ្នកអាន ការសិក្សាស្រាវជ្រាវចំពោះប្រធានបទខាងលើនេះ ក្រុមយើងខ្ញុំបានបែងចែកជា ៣ជំពូកធំៗគឺ៖

- ជំពូកទី១ ផលប្រយោជន៍ទូទៅនៃទីក្រុងរណប
- ជំពូកទី២ ការទទួលបានសិទ្ធិដើម្បីទទួលបានការអភិវឌ្ឍទីក្រុងរណបនៅរាជធានីភ្នំពេញស្របតាមផែនការរូបវន្តទីក្រុង
- ជំពូកទី៣ ផលប៉ះពាល់ដែលកើតចេញពីការអភិវឌ្ឍទីក្រុងរណបនៅរាជធានីភ្នំពេញ

# ជំពូកទី១

# ផលប្រយោជន៍ទូទៅនៃទីក្រុងរណប

# ជំពូកទី១

# ផលប្រយោជន៍ទូទៅនៃទីក្រុងរណប

## ១.១. សញ្ញាណទូទៅ

Faiyum (ហ្វេយូម) គឺជាទីក្រុង មួយដែលនៅចំកណ្ដាលប្រទេសអេហ្ស៊ីប មានចម្ងាយ១០០គីឡូម៉ែត្រពីទិសខាងត្បូងឆៀងខាងលិចនៃក្រុង Cario (ការីអូ)។ ហើយមួយផ្នែកនៃទីក្រុងនេះត្រូវបាន ចូលត្រួតត្រាដោយសម័យកាល Crocodilopolish ឬ Arsinoe បុរាណ។ Faiyum ត្រូវបានរកឃើញនៅអំឡុង ៤០០ឆ្នាំមុនគ.ស ដែលជាក្រុងដែលចាស់ជាងគេបំផុតនៅក្នុងប្រទេសអេហ្ស៊ីប និងនៅតែបន្តជាទីក្រុងដ៏ចំណាស់ជាងគេនៅក្នុងសកលលោក[1]។

ទីក្រុង Faiyum គឺជាប្រភពនៃរបាំងមុខមនុស្សស្លាប់ ឬការពិពណ៌នាអំពីសាកសពមាំមី ដ៏ល្បីល្បាញ ដែលបានគូរអំឡុងកាន់កាប់ដោយ Roman។ ខណៈពេលដែលស្ថិតក្នុងការ គ្រប់គ្រងរបស់ចក្រភព Roman របាំងមុខមនុស្សស្លាប់អេហ្ស៊ីបត្រូវបានគេគូរនៅលើឈើ ហើយប្រើក្រមួនពណ៌លាបពីលើ ដោយប្រើបច្ចេកទេសដែលគេឲ្យឈ្មោះថា Encaustic ការពិពណ៌នាពីរូបភាពមាំមី Faiyum តំណាងឲ្យបច្ចេកទេស។ ជាទូទៅគេជឿថារូបទាំងនោះធ្វើដើម្បីតំណាងឲ្យជនជាតិក្រិកដែរបានរួមចំណែកក្នុងការរកឃើញ ទីក្រុងដំបូងនេះ នៅក្នុងប្រទេសអេហ្ស៊ីប ពិពណ៌នារូប Faiyum ផងដែរនោះក៏ជំនួសឲ្យការឆ្លុះបញ្ចាំងពីការសំយោគដ៏ស្មុគស្មាញនៃវប្បធម៌ជនជាតិអេហ្ស៊ីបដ៏លេចធ្លោ ហើយនឹងជនជាតិក្រិកភាគតិចនៅក្នុងក្រុងនេះផងដែរ។

Faiyum មានផ្សារធំៗជាច្រើន, វិហារអ៊ីស្លាម, កន្លែងងូតទឹក និងផ្សារប្រចាំសប្ដាហ៍។ លើសពីនេះក្រុងនេះមានប្រឡាយទឹកមួយគេហៅថា Bahr Yussef ហូរតាមបណ្ដោយទីក្រុង និងមានផ្ទះជាជួរនៅតាមច្រាំងទន្លេនោះ។ មានស្ពានពីរកាត់ទន្លេមួយក្នុងចំណោមនោះតភ្ជាប់ពីផ្លូវធំទៅកាន់ផ្សារនៅក្នុងក្រុង។ ពំនូកខាងជើងនៃទីក្រុងគឺសម្គាល់ថាជាផ្នែកនៃ Arsino ដែលបង្ហាញអំពីការគោរពបូជាសត្វក្រពើរបស់ជនជាតិក្រិក ហើយរក្សាទុកនៅបឹង Moeris ជាទីសក្ការៈ នៅចំកណ្ដាលទីក្រុងមាន ប្រឡាយទឹកដែរមានហាត់ទឹកចំនួន៤ បង្កើតដោយអាណាភិបាលនៃ Faiyum ជាតំណាងនិមិត្តសញ្ញាជាតិ ពោលគឺរទេះចម្បាំង និងផ្សារដើម្បីឲ្យមានភាពងាយស្រួលចំណាំ[2]។

---

[១] WORLD HISTORY ENCYCLOPEDIA

[២] Joshua J. Mark, World history encyclopedia

ការរៀបចំក្រុងនាពេលបច្ចុប្បន្ន និងការបង្កើតទីក្រុងថ្មីៗកាន់តែច្រើនឡើងៗនាសម័យកាលនេះ គឺត្រូវបានយកគំរូតាមទីក្រុងចាស់ៗដែរធ្លាប់បានបង្កើតរួចមកហើយ ក៏ប៉ុន្តែចំណុចខ្វះខាតមួយចំនួនដែរទីក្រុងចាស់មិនទាន់មានក៏ត្រូវបានដាក់បំពេញ ដើម្បីបំពេញតាមតម្រូវការចាំបាច់ជាក់ស្តែងជាមួយនឹងភាពចាំបាច់នាពេលអនាគតផងដែរ។ ដូចនេះបានជានៅតាមប្រទេសជាច្រើនស្ទើរតែទូទាំងពិភពលោក បានធ្វើការកែលម្អប្រទេសរបស់ខ្លួនតាមរយៈការពង្រីកទីក្រុង ការរៀបចំរចនាសម្ព័ន្ធទីក្រុងឡើងវិញ ឬ ម្យ៉ាងទៀតដោយការបង្កើតទីក្រុងថ្មីៗនៅតាមជាយទីក្រុងចាស់ឬនៅក្នុងក្រុងចាស់តែម្តង ហើយការបង្កើតទីក្រុងថ្មីបែបនេះត្រូវបានគេហៅថា ទីក្រុងរណប។

នៅត្រឹមចុងឆ្នាំ២០២០ រាជធានីភ្នំពេញទទួលបានគម្រោងនៃការវិនិយោគទីក្រុងរណបចំនួន៨ ហើយទីក្រុងរណបទាំងនោះបានបោះទុនរាប់សិបលានដុល្លារអាមេរិក ដែលកំពុងរីកត្រដែតទាំងនូវជាយក្រុង និងកណ្តាលរាជធានីភ្នំពេញ ក្នុងនោះរួមមាន៖

- **ទីក្រុងរណបកាំកូស៊ីធី** ៖ មានម្ចាស់ក្រុមហ៊ុន វើល ស៊ីធី របស់កូរ៉េខាងត្បូងដែលតម្លៃគម្រោងចុះបញ្ជីទុនវិនិយោគប្រមាណ ២ពាន់លានដុល្លារ ក្នុងផ្ទៃក្រឡាសាងសង់ជាង ១១៩ហិកតា ដែលស្ថិតនៅក្នុងតំបន់អភិវឌ្ឍន៍ បឹងពោងពាយ ខណ្ឌឬស្សីកែវ ខាងជើងរាជធានីភ្នំពេញ។ ទីក្រុងរណបកាំកូស៊ីធី បានធ្វើការអភិវឌ្ឍសាងសង់រួចរាល់មួយចំនួនដូចជា អគារខុនដូរ ផ្ទះវីឡា ផ្សារ សាលារៀនជាដើម។
- **ទីក្រុងរណបហ្គ្រេនភ្នំពេញ អ៊ិនធើណេសិនណាល់ ស៊ីធី** ៖ ម្ចាស់គម្រោង គឺឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន និងជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនខេបូឌា វ៉ាយ អិន ភី សហការជាមួយក្រុមហ៊ុនឥណ្ឌូនេស៊ី ស៊ីញូត្រា ក្រុប។ ក្រោមតម្លៃគម្រោងចុះបញ្ជី ទុនវិនិយោគដំបូង៦០០លានដុល្លារអាមេរិក ដែលមានផ្ទៃក្រឡាសាងសង់ចំនួន ២៦០ហិកតា ដែរស្ថិតនៅសង្កាត់ ឃ្មួញ ខណ្ឌឬស្សីកែវ ខាងជើងរាធានីភ្នំពេញ។
- **ទីក្រុងរណបកោះពេជ្រ ស៊ីធី** ៖ ម្ចាស់គម្រោង គឺអ្នកឧកញ៉ា ពុង ឃាវសែ នៃប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនបណ្តាក់ទុនវិនិយោគកម្ពុជាក្រៅប្រទេស ជាមួយតម្លៃគម្រោងចុះបញ្ជីទុនវិនិយោគ ១ពាន់លានដុល្លារអាមេរិក ក្នុងផ្ទៃក្រឡាសាងសង់ ១០០ហិកតា ដែរស្ថិតនៅបណ្តោលទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាធានីភ្នំពេញ។ រហូតមកដល់ពេលនេះ ទីក្រុងរណបកោះពេជ្រមានសកម្មភាពលេចធ្លោជាងគេ ដែលបានកៀងគរអ្នកវិនិយោគបរទេសជាច្រើនអោយមកបណ្តាក់ទុនសាងសង់អាគារពាណិជ្ជកម្ម អាគារលំនៅឋាន ដែរមានតម្លៃរាប់ពាន់លានដុល្លារអាមេរិក។

- **ទីក្រុងរណបអភិវឌ្ឍន៍បឹងកក់** ៖ ម្ចាស់គម្រោងសាងសង់ ឯកឧត្តម ឧកញ៉ា ឡៅ ម៉េងឃិន ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន ស៊ូកាគូអីន ជាមួយតម្លៃចុះបញ្ជីទុនវិនិយោគចំនួន ១៥០០លានដុល្លារអាមេរិក ដែរមានផ្ទៃក្រឡាសាងសង់ ១១៤ហិកតា ដែរស្ថិតនៅតាមបណ្តោលផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ។
- **ទីក្រុងរណបជ្រោយចង្វារ** ( **ទីក្រុងនៃអនាគត** ) ៖ ម្ចាស់គម្រោង គឺអ្នកឧកញ៉ា ពុង ឃាវសែ នៃប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនបណ្តាក់ទុនវិនិយោគកម្ពុជាក្រៅប្រទេស ក្នុងតម្លៃគម្រោងចុះបញ្ជីទុនវិនិយោគ ១៦០០ លានដុល្លារអាមេរិក ផ្ទៃក្រឡាសាងសង់មានទំហំ៣៨៧ ហិកតា ស្ថិតនៅសង្កាត់ទន្លេជ្រោយចង្វារ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។ បច្ចុប្បន្ន គម្រោងទីក្រុងមួយនេះកំពុងមានសកម្មភាពយ៉ាងខ្លាំងជាមួយការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ផ្លូវតភ្ជាប់ខ្វាត់ខ្វែង និងសាងសង់ផ្ទះល្វែងមួយចំនួនផងដែរ។ បើតាមផែនការ ទីក្រុងរណបមួយនេះកំពុងដំណើរការទៅមុខយ៉ាងរលូនក្នុងគម្រោងប្លង់មេ និងមានការសាងសង់អគារពាណិជ្ជកម្មធំៗ ផ្សារទំនើប លំនៅដ្ឋានប្រណីតៗ អគារស្នាក់នៅ និងកន្លែងកំសាន្តផ្សេងៗទៀត បើតាមការប៉ាន់ស្មានគម្រោងនេះនឹងបញ្ចប់ការសាងសង់ក្នុងឆ្នាំ២០២៦។
- **ទីក្រុងរណប លី យ៉ុងផាត់** ៖ ម្ចាស់គម្រោង គឺអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានក្រុមប្រឹក្សាភិបាលនៃ ក្រុមហ៊ុន អិល វ៉ាយ ភី គ្រុប តម្លៃគម្រោងចុះបញ្ជីទុនវិនិយោគ ១៥០០លានដុល្លារអាមេរិក ជាមួយផ្ទៃក្រឡា ១០០០ហិកតា ស្ថិតនៅព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ក្រុមហ៊ុន YLP Group កំពុងអភិវឌ្ឍន៍តំបន់នេះឲ្យក្លាយទៅជាទីក្រុងរណបថ្មីមួយប្រកបដោយការទាក់ទាញអ្នកវិនិយោគ អ្នកធុរកិច្ច ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម មជ្ឈមណ្ឌលកំសាន្តទេសចរណ៍ដោយមានទីលានវាយកូនហ្គោល សួនសត្វ សួនទឹកកំសាន្ត ពហុកីឡាដ្ឋានមរតកតេជោ និងសណ្ឋាគារផ្កាយប្រាំជាដើម។
- **ទីក្រុងរណប អ៊ឹង ស៊ីធី** ( **ING City** ) ៖ ម្ចាស់គម្រោង ឧកញ៉ា អ៊ឹង ប៊ុនហ៊ួរ ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ING HOLDINGS តម្លៃគម្រោងចុះបញ្ជីទុនវិនិយោគ ២ពាន់លានដុល្លារអាមេរិក ក្នុងផ្ទៃក្រឡា ២៥៧២ហិកតា ស្ថិតក្នុងខណ្ឌមានជ័យ ខណ្ឌដង្កោ និងក្រុងតាខ្មៅ ដែលការអភិវឌ្ឍស្ថិតក្នុងបឹងធម្មជាតិគឺ បឹងទំពុន ឬបឹងជើងឯក ក្នុងរាជធានីភ្នំពេញ។
- **ទីក្រុងរណបកោះនរា** ៖ ក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា(OCIC) ជាក្រុមហ៊ុនវិនិយោគក្នុងស្រុកដ៏មានសក្តានុពលក្នុងវិស័យជាច្រើនដែរមាន អ្នកឧកញ៉ា ពុង ឃាវសែ ជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន OCIC បានបង្ហាញផែនការបោះទុនសរុបប្រមាណ២,៥ពាន់លានដុល្លារអាមេរិកសម្រាប់

អភិវឌ្ឍន៍កោះនរាទៅជាទីក្រុងរណបថ្មីមួយទៀត ដែរនៅតាមបណ្តោយទន្លេបាសាក់។ ក្នុងគម្រោងទុនវិនិយោគសរុបមានការអភិវឌ្ឍស្ពានចំនួនពីរអស់ជាង៣៩,៦លានដុល្លារអាមេរិកដែរជួយសម្រួលចរាចរណ៍ពីក្នុងក្រុងទៅកាន់ក្រៅក្រុង ពោលគឺចេញពីកោះពេជ្រឆ្លោះទៅកាន់ផ្លូវជាតិលេខ១។

## ១.២. និយមន័យ ទីក្រុង និង ទីក្រុងរណប

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើជាចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង[3]។ ហើយមិនត្រឹមតែប៉ុណ្ណោះទេ ទីក្រុងក៏សំដៅទៅដល់ទីកន្លែងដែលមិនមានសកម្មភាពកសិកម្មផងដែរ លក្ខណៈវិនិច្ឆ័យមួយចំនួនក៏អាចរួមបញ្ចូលបានផងដែរដូចជា ទីធ្លាទំនេរ និងចរន្តការនៃសេដ្ឋកិច្ច។ ដោយឡែកយោងទៅតាមវចនានុក្រម សម្តេច ព្រះសង្ឃរាជ ជួន ណាត **ក្រុង** សំដៅដល់នគរ រាជធានី បុរី[4]។

**ទីក្រុងរណប** សំដៅទៅលើក្រុង និងទីប្រជុំជនដែលទើបបង្កើតថ្មី ដែរអាចមាននៅក្នុងទីក្រុងចាស់ ឬជាយក្រុង ក្នុងគោលបំណងសម្រាលបន្ទុកដល់ទីក្រុងធំ។ ទីក្រុងរណបត្រូវបានបង្កើតឡើងដោយការវិនិយោគដោយវិស័យឯកជន ឬដោយរដ្ឋាភិបាលផ្ទាល់ អាស្រ័យទៅតាមបណ្តាប្រទេសនីមួយៗដែរខ្លួនមានលទ្ធភាពឬអត់ ហើយវាក៏អាចជាយុទ្ធសាស្ត្រគោលនយោបាយក្នុងការដឹកនាំនៃប្រទេសទាំងនោះផងដែរ។ ជាក់ស្តែងនៅប្រទេសកម្ពុជា ការបង្កើតទីក្រុងរណបត្រូវបានធ្វើឡើងតាមការវិនិយោគរបស់ក្រុមហ៊ុនឯកជនដែរមានទាំងក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុក។

ទីក្រុងរណបក៏ជា តំបន់ដែលអភិវឌ្ឍន៍ខ្លាំងបំផុតបន្ទាប់ពីទីក្រុងគោលហើយក៏នៅមិនឆ្ងាយពីទីក្រុងគោលប៉ុន្មានដែរ និងជាតំបន់អភិវឌ្ឍន៍ទៅលើគម្រោងធំៗបន្ទាប់ពីទីក្រុងគោល ដូចនេះប្រសិនបើនិយាយឲ្យខ្លី ទីក្រុងរណបគឺជាតំបន់អភវឌ្ឍន៍ឲ្យក្លាយទៅជាទីក្រុងថ្មីមួយ អាចរស់នៅ ធ្វើការ និងកម្សាន្តបានយ៉ាងសម្បូរបែបដោយមិនចាំបាច់ពឹងផ្អែកទៅលើទីក្រុងគោលក៏បានដែរ។

[3] សន្ទានុក្រម នៃអនុក្រឹត្យលេខ៤២/អនក្រ.បក, ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥

[4] សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ

## ១.៣. បរិបទទូទៅនៃមូលហេតុនាំឲ្យមានការរៀបចំក្រុង

បុព្វហេតុនៃការរៀបចំក្រុងមួយចាំបាច់ត្រូវធ្វើឡើងប្រកបដោយសន្និទានកម្ម ពោលគឺមានការគិតគូយ៉ាងហ្មត់ចត់សព្វជ្រុងជ្រោយ។ ដូច្នេះក្រុងមួយកើតឡើងពុំមែនដោយសារកត្តាចៃដន្យនោះទេ ពោលគឺកើតឡើងដោយសារមានមូលហេតុជម្រុញពីក្រោយជាច្រើនដូចជា៖ កំណើនប្រជាជន និងដង់ស៊ីតេ(១.៣.១.) ការដាក់សម្ពាធបរិស្ថាន(១.៣.២.) គុណភាពនៃការរស់នៅ(១.៣.៣.) និងកត្តភាពក្រីក្រ(១.៣.៤.)។

### ១.៣.១. កំណើនប្រជាជន និងដង់ស៊ីតេ

ដោយសារមានកំណើនប្រជាជនជារៀងរាល់ឆ្នាំ ប្រជាជនទាំងនោះត្រូវស្វែងរកការងារនៅតាម ទីក្រុង ទីប្រជុំជន ខេត្ត ដែលជាហេតុនាំឲ្យមានការប្រមូលផ្តុំ ឬធ្វើអន្តោប្រវេសន៍ក្នុងទីក្រុង-ខេត្តកាន់តែច្រើន។ តាមរយៈការធ្វើជំរឿនចំនួនប្រជាជនកម្ពុជានៅក្នុងឆ្នាំ១៩៩៨ របស់ក្រសួងផែនការកម្ពុជា មានអត្រាកំណើនប្រជាជនចំនួន ១១,៤៥ លាននាក់ដែរមានអត្រាកំណើន ២,៤៩ភាគរយក្នុងមួយឆ្នាំ រីឯអត្រាកំណើនប្រជាជននៅតាមទីប្រជុំជនកើនជាមធ្យមប្រមាណ ៣,៤ភាគរយនៅក្នុងមួយឆ្នាំ។ ដប់ឆ្នាំបន្ទាប់ពោលគឺការធ្វើជំរឿនក្នុងឆ្នាំ២០០៨ បានអោយដឹងថាប្រជាជនបានកើនដល់ ១៣,៣៩៥,៦៨២នាក់ ក្រោយពីការធ្វើជំរឿនចុងក្រោយនៅឆ្នាំ២០១៩ តាមរយៈរបាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយជំរឿនទូទៅនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ជាលទ្ធផលបានបង្ហាញឲ្យឃើញថាប្រជាជនបានកើនដល់ ១៥,២៨៨,៤៨៩នាក់ គឺកើន១៦ភាគរយបើធៀបនឹងឆ្នាំ២០០៨ បើគិតត្រឹមថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩[5]។ ចំនួននេះបានកើនឡើងយ៉ាងឆាប់រហ័សថែមទៀតនាពេលអនាគតប្រសិនបើពុំមានបញ្ហាធំដែរគួរអោយកត់សម្គាល់នោះទេ។ កំណើនប្រជាជន ក៏បាននាំបញ្ហាមកទីប្រជុំជន ទីក្រុង ឬខេត្ត នេះអាចបណ្ដាលមកពីភាពក្រីក្រខ្លាំងនៅតាមជនបទ និងបណ្ដាលមកពីលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គម នៅទីក្រុង និងនៅជនបទមានភាពខុសគ្នាខ្លាំង។ ការដែរធ្វើអន្តោប្រវេសន៍របស់ប្រជាជនតាមជនបទមករកការងារធ្វើនៅក្នុងទីក្រុង ធ្វើអោយមានសម្ពាធទៅលើការខ្វះខាតការងារ តម្រូវការហេដ្ឋារចនាសម្ព័ន្ធទីក្រុងដើម្បីឲ្យស្របតាមការប្រើប្រាស់របស់ប្រជាជន។

ការកើនឡើងយ៉ាងច្រើនសន្ធឹកសន្ធាប់នៃប្រជាជននៅក្នុងទីក្រុង បានខ្លាចជាកង្វល់របស់រាជរដ្ឋាភិបាលដែរត្រូវលើកយកមកសដោះស្រាយ។ ជាទូទៅសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុងមាន៣សំខាន់ៗ៖ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនប្រជាជនដោយចំណាកស្រុកពីជនបទមក និងកំណើនប្រជាជនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនជាលក្ខណៈធម្មជាតិបានធ្វើអោយមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកកំណើន

[5] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ, ជំរឿនទូទៅនៃប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

ដោយសារចំណាកស្រុកពីជនបទ និងកំណើនដោយសារការបែងចែកប្រភេទសណ្ឋានដីនៃទីក្រុងថ្មី ដែរពីមុនមក តំបន់នេះជាទីជនបទគ្រាន់តែជាធាតុផ្សំចូររួមបន្ទាប់បន្សំប៉ុណ្ណោះ។

កំណើនប្រជាជននាពេលអនាគតជារឿងមួយដែរមិនអាចមើលរំលងបានឡើយ មានន័យថារដ្ឋាភិបាលគួរយកចិត្តទុកដាក់ឲ្យបានច្រើន និងត្រូវមានផែនការច្បាស់លាស់មួយដើម្បីទប់ស្កាត់រាល់បញ្ហាផ្សេងៗដែលត្រូវចោទឡើង។ តាមតួរលេខរបស់អង្គការសហប្រជាជាតិបានបង្ហាញកាលពីថ្ងៃទី២៧ ខែ០២ ឆ្នាំ២០០១ បានបញ្ជាក់ថាចំនួនប្រជាជនពិភពលោក បានកើនឡើងដល់៦,១ពាន់លាននាក់ ក្នុងពាក់កណ្ដាលឆ្នាំ២០០០ទៅហើយ ដោយឡែកបច្ចុប្បន្នកំពុងកើនឡើងជាមធ្យមចំនួន ៧៧លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ខាងមុខ ចំនួនប្រជាជនពិភពលោកនឹងមានការកើនឡើងខ្លាំងនៅចន្លោះពីចំនួន ៧,៩ពាន់លាននាក់ ទៅ១០,៩ពាន់លាននាក់។ បើទោះបីជាមានប្រទេសមួយចំនួនបានលេចចេញនូវអត្រាភាពនៃអត្រាមរណៈភាពខ្ពស់ដោយសារតែ ជំងឺអេដស៍ក៏ដោយ ក៏កំណើនប្រជាជននៅតែខ្ពស់ដដែល[៦]។

ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដង់ស៊ីតេប្រជាជនកម្ពុជាក្នុងមួយគីឡូម៉ែត្រក្រឡាមាន៧៥នាក់ក្នុងឆ្នាំ២០០៨ និងកើនដល់៨៧នាក់ក្នុងឆ្នាំ២០១៩។ ដង់ស៊ីតេនេះប្រជាជនកម្ពុជានៅទាបជាងច្រើនបើធៀបនឹងដង់ស៊ីតេប្រជាជននៅតាមបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ រាជធានីភ្នំពេញមានដង់ស៊ីតេប្រជាជនខ្ពស់បំផុតគឺ ៣,៣៦១នាក់ក្នុងផ្ទៃដីមួយគីឡូម៉ែត្រក្រឡា ចំពោះផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០១៩ ស្មើនឹង ១,៦៩៤ដុល្លារអាមេរិក ដែលនៅក្នុងឆ្នា២០០៨មានត្រឹមតែ៧៣៩ដុល្លារប៉ុណ្ណោះ។

### ១.៣.២. ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធនឹងវិស័យបរិស្ថានគឺ កង្វះដីបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះមានច្រើនក្នុងករណីដែលដីរបស់ពួកគេទទួលបានពីដូនតា ឪពុកម្ដាយ របស់ខ្លួនត្រូវបានពួកគេចែកឲ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូច មិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះនិងមានជីជាតិទៀត។ ប្រសិនបើក្រឡេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលពួកគាត់មានដីគ្រប់គ្រាន់ហើយ តែបែរជាគាត់ខ្វះប្រព័ន្ធធារាសាស្ត្រស្រោចស្រពនិងជីកសិកម្មសម្រាប់បង្កបង្កើនផលឲ្យបានគ្រាន់ទៅវិញ ករណីនេះច្រើនកើតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់មេគង្គក្រោម[៧]។

---

[៦] UN POPULATION DIVISION ISSUES ‘WORLD POPULATION PROSPECTS : THE 2000 REVISION’

[៧] Sajor, 2001

### ១.៣.៣. គុណភាពនៃការរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាពគឺជា កត្តាចម្បងដែលត្រូវបានគិតគូនៅពេលមានការពីភាក្សាជុំវិញការជម្រុញឲ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សន៍នៅទីក្រុង ជាកត្តាដែរទាក់ទាញមនុស្សឲ្យមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងអ្នកទីក្រុង និងជនបទមានគម្លាតខ្ពស់ ប្រជាពលរដ្ឋនៅជនបទនៅតែចង់មករស់នៅក្នុងទីក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអត្រានិកម្មភាពខ្ពស់ជាងកត្តាជម្រុញចំណាកស្រុកដោយសារតែពេលខ្លះការងារនៅជនបទនៅមានកម្រិត ដូចន្នេះបើទោះបីជាទទួលបានប្រាក់ខែទាបក៏នៅតែ បង្ខំចិត្តចំណាកស្រុកមកទីក្រុងដែរ[៨]។ លើសពីនេះនៅទីក្រុងការមានប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរខណៈពេលសេវាសុខាភិបាល និងអប់រំមានសម្បូរបែបរឹតរឹងតែធ្វើងអោយអ្នករស់នៅទីនោះមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។

### ១.៣.៤. កត្តាភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកក្នុងការកំណត់ណាស់ តែជាទូទៅភាពក្រីក្រសម្តៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប ដែលពួកគេ មិនអាចចាយវាយបានគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃបានឡើយ ហើយតម្រូវការរូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារ ធនធានទឹក អគ្គីសនី អនាម័យសុខមាលភាពសង្គម មានការខ្វះខាត។

ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាប របស់បុគ្គលមួយៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជាៈ ចំនួននៃឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈចំណូលនោះឡើយ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង២០%នៃប្រជាជនពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយ៩០%នៃចំនួននេះកំពុងស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

#### ក.ភាពក្រីក្រនៅតាមជនបទ

ស្ថិតនៅក្នុងបរិការណ៍នៃបច្ចុប្បន្នភាព ស្ថានភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មានការកើនឡើងជាលំដាប់។ កំណើននេះអាស្រ័យដោយស្ថានភាពសេដ្ឋកិច្ចសង្គម ប្រជាសាស្ត្រ ភូមិសាស្ត្រនយោបាយ គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុនិងកង្វះដីបង្កបង្កើនផលជាដើម។ ភាពក្រីក្រនៅជនបទនាំអោយមានចំណាកស្រុកទៅទីក្រុង ហើយចរន្តការនេះនឹងកើនឡើងនៅពេលដែលស្ថានភាពនៅតំបន់ជនបទកាន់តែលំបាក។ ដូច្នេះការបង្កើនសកម្មភាព សេដ្ឋកិច្ចនៅជនបទ ជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាពជាទីបំផុតដើម្បីគ្រប់គ្រងការចំណាកស្រុក។

[៨] Brookfield and Bryon, 1993

### ខ. ភាពក្រីក្ររបស់ទីក្រុង

ជាទូទៅ ពុំមានលក្ខណៈជាសមាសភាពទេ កាលណាគេធ្វើការប្រៀបធៀបពីភាពក្រីក្រ ដោយដាក់បន្ទាត់មួយក្រឹតឲ្យស្មើរភាពគ្នានោះទេ។ ឧទាហរណ៍ ការប្រើប្រាស់ថវិការ ១ដុល្លារសហរដ្ឋអាមេរិក ដូចគ្នា តែបុគ្គលម្នាក់នៅជនបទ ចំណែកបុគ្គលម្នាក់ទៀត នៅទីក្រុងមិនស្មើគ្នាទេ មូលហេតុនោះគឺដោយសារថា ជាធម្មតាការចំណាយនៅទីក្រុងខ្ពស់ជាងជនបទដាច់ស្រយាលឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះ អ្នករស់នៅតាមទីជនបទអាចមានឱកាសស្វែងរកការកចិញ្ចឹមជីវិត តាមរយៈការទទួលអំណោយ ភោគផល ពីធម្មជាតិច្រើនជាងអ្នកទីក្រុង។ តាមរយៈនេះគេអាចនិយាយបានថាអ្នកក្រនៅទីក្រុងក្រជាង និងមានស្ថានភាពលំបាកជាង អ្នកក្រនៅជនបទ។ ដោយឡែកការនិយាយបែបនេះក៏ពុំត្រឹមត្រូវទាំងស្រុងនោះដែរ ដោយហេតុថា នៅទីក្រុងមានបរិយាកាសសង្គម ដែលបង្កលក្ខណៈវិជ្ជមានច្រើនដល់ឱកាសការងារ ការសិក្សាអប់រំ សុខាភិបាល សុខមាលភាពសង្គម អនាម័យសាធារណៈ ដែលអាចជួយឲ្យអ្នកដែលស្ថិតនៅក្នុងភាពក្រីក្រអាចមានឱកាសដើរចេញពីស្ថានភាពលំបាកនេះក្នុងស្ថានភាពខ្ពស់។[៩]

## ១.៤. លក្ខណៈសម្បត្តិនៃទីក្រុងរណប

រាជធានីភ្នំពេញជាទីក្រុងរាជធានីសំខាន់តែមួយគត់របស់កម្ពុជា ដែលហ៊ុមព័ទ្ធដោយតំបន់ជនបទនៅឡើយ និងជាប៉ូលសេវាកម្មកណ្តាលមួយក្នុងតំបន់ដែលប្រមូលផ្តុំនូវប្រជាជនជាង ៦លាននាក់នៅក្នុងកាំរង្វង់ចម្ងាយ១០០ គីឡូម៉ែត្រជុំវិញ ដែរប្រហាក់ប្រហែលនឹងទីក្រុងធំៗមួយចំនួននៅអាស៊ីអាគ្នេយ៍ ដូចជាទីក្រុងបាំងកកបម្រើប្រជាជន ៩លាននាក់ ទីក្រុងហាណូយ៨លាននាក់ ទីក្រុងហូជីមិញ៧លាននាក់ សិង្ហបុរី៤លាននាក់ និងទីក្រុងកូឡាឡាំពួរ៤លាននាក់[10]។ ជាការឆ្លើយតបជាមួយមុខងារទាំងនេះ ភ្នំពេញត្រូវតែមានផែនការជាយុទ្ធសាស្ត្រមួយដែរមានកម្រិតខ្ពស់ ក្នុងនោះជាអាទិ៍ទាក់ទងនឹងវិស័យរៀបចំដែនដី ការគ្រប់គ្រងទីក្រុងនិងសន្តិសុខព្រមទាំងគុណភាពនៃទីក្រុងក្នុងការបង្ហាញអំពីអត្តសញ្ញាណ ពោលគឺរាជធានីភ្នំពេញគឺជាកញ្ចក់ឆ្លុះបញ្ចាំងពីគុណភាពឲ្យជាតិទាំងមូល។

ម្យ៉ាងទៀតក៏មានជាភាពតំណាងមួយធំជាងគេក្នុងវិស័យរដ្ឋបាល និងសេវាសាធារណៈនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ដែលក្នុងនោះមានសាលារាជធានីភ្នំពេញ រដ្ឋាករទឹកស្វយ័តភ្នំពេញ អាកាសយានដ្ឋានភ្នំពេញ សភាពាណិជ្ជកម្មភ្នំពេញ ក្លឹបពាណិជ្ជកម្មសំខាន់ៗដទៃទៀតនៅក្នុងប្រទេស ដែលមានភាពសកម្មក្នុងវិស័យពាណិជ្ជកម្ម

---

[៩] Habitat,1996

[១០] ទំព័រទី៩ នៃប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ២០១៣៥, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥

ដែលមានលក្ខណៈអន្តរជាតិ[11]។ ដោយមានតម្រូវការនៃការប្រើប្រាស់ដីមមាញឹកបែបនេះហើយ បានជាទាមទារឲ្យទីក្រុងត្រូវតែមានគុណភាពខ្ពស់ស្ទើរគ្រប់វិស័យដែរក្នុងនោះមានដូចជា៖

### ១.៤.១. ហេដ្ឋារចនាសម្ព័ន្ធ

បើយើងសម្លឹងទៅមើលការសាងសង់ទីក្រុងរណប យើងឃើញថាវាជាជំនួយមួយនៃការបញ្ចៀសចរាចរណ៍នៅក្នុងទីក្រុងភ្នំពេញបានច្រើនមែនទែនព្រោះនៅក្នុងទីក្រុងភ្នំពេញរាល់ថ្ងៃគឺជាទីក្រុងមួយដែរមានសកម្មភាពពាណិជ្ជកម្មខ្លាំងខ្លា បានន័យថាជាកន្លែងដែលប្រជាជនបានសម្រុកចូលមករកស៊ី។ ហើយការណ៍ដែរគេសាងសង់ទីក្រុងរណបនៅជុំវិញរាជធានីភ្នំពេញនោះគឺជាកន្លែងស្នាក់នៅ វាជាការបញ្ចៀសមួយល្អសម្រាប់ទីក្រុងភ្នំពេញ ព្រោះបើមនុស្សនាំគ្នាចូរមកផ្តុំគ្នាក្នុងទីក្រុងតែមួយវានឹងក្លាយជាបន្ទុកដ៏ធ្ងន់សម្រាប់រដ្ឋាភិបាល តែដោយសារមានការអភិវឌ្ឍទីក្រុងរណបស្ទើរគ្រប់ជ្រុងទាំងអស់ដែរអាចនិយាយបានថា ជាការបញ្ចៀសចរាចរណ៍ និងការអភិវឌ្ឍគ្រប់ជ្រុងជ្រោយនៃរាជធានីភ្នំពេញ។

ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងទីក្រុងរណប គឺមានសភាពស្អាតជាមួយគុណភាពខ្ពស់នឹងបានភ្ជាប់ទៅទីក្រុងគោលហើយនាពេលអនាគតគឺដូចនឹងទីក្រុងអញ្ចឹង។ រាល់ការស្ថាបនាស្ពានថ្នល់ និងប្រព័ន្ធបញ្ជូនទឹកនៅក្នុងទីក្រុងរណបគឺបានធ្វើឡើងដោយមានការយកចិត្តទុកដាក់ទាំងខាងបច្ចេកទេសសាងសង់ និងសម្ភារៈសាងសង់ដើម្បីទទួលបានសំណង់ដែរមានគុណភាពខ្ពស់ ដោយបានជួយសម្រួលដល់បញ្ហាមួយចំនួនរបស់រាជធានីភ្នំពេញដែរកំពុងប្រឈមនាពេលបច្ចុប្បន្នក្នុងការផ្តល់សេវាមូលដ្ឋានពាក់ព័ន្ធនឹងប្រព័ន្ធលូ ការសំអាតទឹកស្អុយ ការដឹកជញ្ជូនសាធារណៈ និងកាកសំណល់ដែរមានទាំងកាកសំណល់រឹង និងរាវ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនេះ ត្រូវបានតាមដានយ៉ាងជិតស្និតពីសំណាក់មន្ត្រីនៃក្រសួងសាធារណៈការ និងដឹកជញ្ជូនជាអ្នកត្រួតពិនិត្យកិច្ចការទាំងនេះ ចំពោះការសាងសង់ត្រូវបានបានកំណត់ដោយក្រសួងផងដែរពោលគឺហេដ្ឋារចនាសម្ព័ន្ធទាំងនោះត្រូវមាន ផ្លូវសម្រាប់យានយន្តផ្លូវសម្រាប់ថ្មើជើង និងគម្លាតសុវត្ថិភាពរវាងសំណង់ជាមួយផ្លូវសាធារណៈ។

### ១.៤.២. សំណង់អគារនានា

គ្រប់ម្ចាស់គម្រោងសាងសង់អគាទាំងអស់ ដើម្បីអាចទទួលបានសិទ្ធិក្នុងការសាងសង់គម្រោងនីមួយៗត្រូវឆ្លងកាត់នីតិវិធីច្បាប់ដោយខានពុំបាន ព្រមទាំងមានការតាមដានយ៉ាងជិតស្និតពីសំណាក់មន្ត្រីមានសមត្ថកិច្ចផងដែរ។ រាល់សំណង់អគារទាំងអស់នៅក្នុងទីក្រុងរណបក៏មិនខុសពីកន្លែងផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជានោះទេគឺត្រូវគោរពតាមគោលការណ៍រួមដូចគ្នាទាំងអស់។ ក៏ប៉ុន្តែដូចដែរបានដឹងហើយថាដោយសារប្រទេសកម្ពុជាជា

[11] ទំព័រទី១១ កថាខណ្ឌទី៣, នៃប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ២០៣៥

ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រជាជនមួយចំនួនពុំបានយល់ច្បាស់ពីកាតព្វកិច្ចដែរខ្លួនត្រូវបំពេញចំពោះនីតិវិធីច្បាប់ដូចជា មិនបានស្នើសុំសិទ្ធិពីមន្ត្រីមានសមត្ថកិច្ច និងមិនអ្នកជំនាញវិជ្ជាជីវខាងសំណង់ពិតប្រាកដមកធ្វើការត្រួតពិនិត្យ (ជាងម៉ៅការសំណង់ចេះតាមគ្នា) ជាហេតុធ្វើអោយការសាងសង់មួយចំនួនធំពុំសមស្របតាមបច្ចេកទេស និងគ្មានគុណភាពវាក៏ជាកត្តាមួយដែរនឹងជះផលប៉ះពាល់នាពេលខាងមុខ ទាំងរយៈពេលខ្លី និងវែង។ ចំពោះគម្រោងនៃការសាងសង់អាគារនៅឯទីក្រុងរណបវិញ ត្រូវបានយកចិត្តទុកដាក់ជាពិសេសដោយមានការតាមដានយ៉ាងហ្មត់ចត់និងត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួនមុននឹងដាក់អោយធ្វើការប្រើប្រាស់ ក្នុងនោះរួមមាន៖ ការអនុញ្ញាតអោយសាងសង់ជួសជុល ឬរុះរើ(ក) ការគ្រប់គ្រងគម្រោងប្លង់(ខ) ការគ្រប់គ្រងការងារសាងសង់ឬរុះរើ(គ) និងការប្រើប្រាស់សំណង់(ឃ)៖

**ក. ការអនុញ្ញាតអោយសាងសង់ ជួសជុល ឬរុះរើ**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច[12]។ ការសាងសង់ឬរុះរើមួយចំនួនមិនតម្រូវឲ្យមានការអនុញ្ញាត(ពុំចាំបាច់ដាក់ពាក្យស្នើសុំការអនុញ្ញាតឡើយ) ក្នុងករណីដូចជា៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើ ឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ

ប្រភេទ និងទំហំនៃការសាងសង់ឬរុះរើដែលមិនតម្រូវឲ្យមានការអនុញ្ញាត ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យ។

ក៏ប៉ុន្តែរាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឲ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែរការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភ័ណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឲ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។ ការអនុវត្តការសាងសង់ ឬរុះរើចំពោះសំណង់ដែរមិនតម្រូវឲ្យមានលិខិតអនុញ្ញាតនាំឲ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ[13]។

[12] មាត្រា២៦ នៃច្បាប់ស្តីពីសំណង់, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[13] មាត្រា៣១ នៃច្បាប់ស្តីពីសំណង់, ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

### ខ. ការគ្រប់គ្រងគម្រោងប្លង់

រាល់គម្រោងប្លង់ដែរប្រើប្រាស់សម្រាប់ការងារសាងសង់ ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែរមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ រាល់គម្រោងប្លង់ដែរប្រើប្រាស់សម្រាប់ការងារសាងសង់ ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្ម។ អនុភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិរៀបចំដែនដីនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គម្រោងសាងសង់ ឬរុះរើសំណង់ដែរត្រូវតម្រូវឲ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែរមានអជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់[14]។

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ ឬរុះរើដែលតម្រូវឲ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។ មុនអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឲ្យកែសម្រួយគម្រោងប្លង់ដែលទទួលបានការយល់ព្រមរួចហើយ។ ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលប្លង់ ចំពោះលក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយច្បាប់ស្តីពីសំណង់[15]។

### គ. ការគ្រប់គ្រងការងារសាងសង់ឬរុះរើ

រាល់ការងារសាងសង់ ឬរុះរើត្រូវអនុវត្តដោយអ្នកសាងសង់ដែរមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។ អ្នកសាងសង់មិនតម្រូវអោយមានអជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចជា ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ សាងសង់ឬរុះរើសំណង់ដែរជាលំនៅឋានរបស់ខ្លួន និងសាងសង់ឬរុះរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

រាល់ការងារសាងសង់សំណង់ដែលតម្រូវឲ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើការដ្ឋានជាមុន។ ហើយអ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ នៅបរិស្ថាននៅការដ្ឋានសំណង់ ទន្ទឹមនឹងនោះម្ចាស់សំណង់ត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច

[14] មាត្រា៣២ និង៣៣, នៃច្បាប់ស្តីពីសំណង់, ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[15] មាត្រា៣៤, នៃច្បាប់ស្តីពិសំណង់, ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

របាយការណ៍ទាំងនោះត្រូវតែមានការឯកភាពពីម្ចាស់សំណង់។ ក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការសាងសង់ឬរុះរើ ជាការសហការម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែរពាក់ព័ន្ធការងារសាងសង់ រាប់ទាំងអ្នកអភិវឌ្ឍន៍អចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងសាងសង់ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់ ក្នុងករណីដែរអជ្ញាធរអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឲ្យរុះរើ ឬចាត់វិធាការចាំបាច់ផ្សេងៗទៀត ក្នុងករណីរកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត។

### ឃ. ការប្រើប្រាស់សំណង់

ការប្រើប្រាស់សំណង់ដែរតម្រូវឲ្យមានការលិខិតអនុញ្ញាតសាងសង់ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រ មុននឹងប្រើប្រាស់ ឬដាក់ឲ្យប្រើប្រាស់សំណង់ទាំងនោះ។ ហើយរាល់សំណង់តម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យ និងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែរមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងអជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឲ្យចូរប្រើប្រាស់សំណង់[16]។

អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឲ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្តោះអាសន្នបានចំពោះសំណង់ទាំងមូល ឬមួយផ្នែកណាមួយនៃគម្រោងសាងសង់ក្នុងករណីដែលសំណង់ទាំងមូល ឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។

### ១.៤.៣. ប្រព័ន្ធសុវត្ថិភាព

ទីក្រុងរណប បានបង្កើតឡើងដោយមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាល និងបណ្តាក្រសួងដែរមានការពាក់ព័ន្ធជាច្រើនជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅក្នុងទីក្រុងរណបនៅភ្នំពេញនាពេលបច្ចុប្បន្នសុទ្ធសឹងតែបានបំពាក់នូវប្រព័ន្ធការពារសុវត្ថិភាពបានយ៉ាងល្អ ដើម្បីជាការបង្ការនូវចំណោទបញ្ហាផ្សេងដែរអាចនឹងកើតមានក្នុងទីក្រុងក្នុងនោះមានដូចជា ការបំពាក់កាំមេរ៉ាសុវត្ថិភាពនូវតាមដងផ្លូវ និងក្នុងអគារ ការរៀបចំប្រព័ន្ធទឹក និងស្ថានីយ៍ពន្លត់អគ្គីភ័យនូវតាមទីក្រុងនៃការអភិវឌ្ឍទាំងនោះ ការដាក់ពង្រាយភ្នាក់ងារសន្តិសុខយាមកាមពាសពេញផ្ទៃនៃទីក្រុង។

[16] មាត្រា៤៤ នៃច្បាប់ស្តីពីសំណង់, ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

បន្ថែមពីលើនោះទីក្រុងរណបក៏បានលុបបំបាត់កង្វល់ទាំង ៤ធំៗ ដែរសាលារាជធានីភ្នំពេញកំពុងជួប ហើយក៏ពិបាកក្នុងការដោះស្រាយឲ្យមានប្រសិទ្ធិភាពពោលគឺមានវិធានការចំពោះ ការបំពុលទឹក ការបំពុលខ្យល់ និងការបំពុលដោយសំណល់រឹង និងរាវ។ ក្រុមអភិវឌ្ឍន៍នៃទៅក្រុងរណបបានចាត់វិធានការណ៍ទាំងនោះតាមរយៈ៖

- **ការបំពុលទឹក** នៅទីក្រុងរណបបានគ្រប់គ្រងសម្រាមបានល្អ គ្រប់គ្រងប្រព័ន្ធទឹកកង្វក់បានល្អ និងមានវិធានការខ្ពស់ចំពោះអ្នករស់នៅទីនោះ។
- **ការបំពុលខ្យល់** នៅទីក្រុងរណបបានធ្វើការដាំនៅដើមឈើជាច្រើននៅតាមដងផ្លូវនៃទីក្រុងរណប និងការសាងសង់នូវសំណង់ដែរភ្ជាប់ជាមួយរុក្ខជាតិបៃតងដែរវាបានសមស្របនឹងគម្រោងនៃការលើកកំពស់នៃទីក្រុងបៃតងរបស់សាសារាជធានីភ្នំពេញ។ ការដាំដើមឈើបែបនេះបានជួយបន្សុតខ្យល់ឲ្យមានគុណភាពខ្ពស់ មានន័យថាជាការជួយសម្រួលការលុបបំបាត់ជាតិពុលនៅក្នុងខ្យល់។
- ***ការបំពុលដោយសំណង់រឹង និងរាវ*** ដើម្បីឲ្យទីក្រុងមានសភាពស្អាត គេមានវិធានការចំនួន៣ជាការឆ្លើយតបនោះគឺ ការវិចខ្ចប់កាកសំណល់ ការប្រមូលកាកសំណល់ និងការបញ្ជូនកាកសំណល់ទៅកាន់ទីកន្លែងរក្សា និងបំផ្លាញ់ចោល។

## ១.៥. ទាក់ទាញការវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុក

នៅកម្ពុជាប៉ុន្មានឆ្នាំចុងក្រោយនេះគេសង្កេតឃើញថា វិនិយោគិនបរទេស ជាពិសេសគឺមកពីប្រទេសចិន និងហុងកុងបានសម្រុកចូរមកបោះទុនវិនិយោគនៅប្រទេសកម្ពុជាមានចំនួនកើនឡើងជាបន្តបន្ទាប់ រាប់ចាប់ពីវិស័យកាត់ដេរ រហូតដល់អចលនទ្រព្យ និងសំណង់លំនៅឋាន ហើយការបង្កើតទីក្រុងរណបជាគោលដៅរបស់អ្នកវិយោគធំៗ។ បើតាមប្រសាសន៍លោក ជា សុផារ៉ា ឧបកនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ លោកមានប្រសាសន៍សង្កត់ធ្ងន់ថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវ ក្នុងការអភិវឌ្ឍវិស័យឯកជននិងទាក់ទាញការវិនិយោគ និងបានផ្តល់ការអនុគ្រោះយ៉ាងច្រើនដល់វិនិយោគិនបរទេសចំពោះសិទ្ធិលើអចលនទ្រព្យតាមច្បាប់កម្ពុជា [17] ។ ដោយសារមានការលើកទឹកចិត្ត និងការសម្រួលនីតិវិធីតាមផ្លូវច្បាប់ក្នុងការវិនិយោគចំពោះការវិស័យអចនទ្រព្យនេះហើយ បានជាមានទាំងវិនិយោគិនបរទេស និងវិនិយោគិនក្នុងស្រុកមានទំនុកចិត្តខ្ពស់ក្នុងការបោះទុនរកស៊ីរហូតដល់រាប់រយពាន់លានដូល្លារអាមេរិក។ ជាមួយនឹងទុនវិនិយោគ

[17] ប្រសាសន៍លោកឯឧត្តម ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ថ្លែងក្នុងវេទិការសាធារណៈឯកជនលើកទី១ស្តីពីការអភិវឌ្ឍនគរូបនីយកម្មកម្ពុជា-ជប៉ុន, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩

ដែរមានទំហំដ៏ធំធេងបែបនេះហើយ ដែរវាជាកត្តាចម្បងក្នុងការ បង្កើតឱកាសការងារជូនប្រជាជន លទ្ធភាពនៃការនាំចេញនៅនឹងកន្លែង និងបានលើកកម្ពស់ផ្នែកសេដ្ឋកិច្ចនូវកម្ពុជា។

### ១.៥.១. បង្កើតឱកាសការងារជូនប្រជាជន

ដោយសារការវិនិយោគកាន់តែច្រើនឡើងៗ និងកាន់តែធំឡើងៗ តម្រូវការកម្លាំងពលកម្មក៏មានការកើនទៅតាមនោះដែរ។ កម្លាំងពលកម្មជាស្នូលដ៏សំខាន់ដើម្បីអោយគម្រោងនៃការអភិវឌ្ឍអាចដើរទៅមុនបាន ក្នុងនោះកម្លាំងពលកម្មក្នុងស្រុកនូវកម្ពុជាមានចំនួនច្រើន និងមានតម្លៃទាបដែរអាចវិនិយោគិនរីករាយនឹងការចំណាយថវិការមកលើប្រជាជនរបស់យើង ក្នុងកាលៈទេសៈដ៏អំណោយផលយ៉ាងនេះបើប្រជាជនពិតជាមានភាពសកម្មពិតប្រាកដមែននោះច្បាស់ណាស់ឱកាសការងារសម្រាប់ពួកគេគឺមានច្រើន។ នៅទីបំផុតបន្ទាប់ពីប្រជាជនទទួលបានការងារទាំងនេះហើយ ការកើនឡើងទៅលើវិស័យសេដ្ឋកិច្ចមិនថាទាំងជាតិ និងប្រជាពលរដ្ឋផ្ទាល់នឹងកើនឡើងទៅជាមួយគ្នាដែរពុំអាចប្រកែកបាន។

### ១.៥.២. លទ្ធភាពនៃការនាំចេញនៅនឹងកន្លែង

រាល់គម្រោងនៃការអភិវឌ្ឍទាំងអស់តែងតែមានតម្រូវការជាចាំបាច់ទៅលើការប្រើប្រាស់នៅធនធានមនុស្ស និងសម្ភារៈជាច្រើនមុខ ក្នុងនោះស្បៀងអាហារ និងទំនិញប្រើប្រាស់ប្រចាំថ្ងៃក៏ជាតម្រូវការដែលមិនអាចមើលរំលងបានឡើយ។ បើនិយាយក្នុងបរិបទដែរវិនិយោគិនជាជនជាតិបរទេស ច្បាស់ណាស់គេប្រាកដជាបានសិក្សារួចហើយមុននឹងសម្រេចបោះទុនវិនិយោគមកលើប្រទេសយើងមានន័យថាគេបានសម្លឹងឃើញពីសក្កដានុពលនៃការរីកលូតលាស់នៃសេដ្ឋកិច្ចក្នុងតំបន់ និងផលិតផលក្នុងស្រុកមានតម្លៃទាបរួមទាំងថ្លៃពលកម្មផងដែរ។ ការដែរមានការវិនិយោគក្នុងស្រុកកាន់តែច្រើនឡើងវាក៏ជាឱកាសសម្រាប់វិនិយោគិនខ្មែរ និងប្រជាពលរដ្ឋដែរជាអ្នកផលិតវត្ថុធាតុដើម ឬមួយផលិតផលពាក់កណ្តាលសម្រេច ឬផលិតផលធ្វើបានសម្រេច សម្រាប់លក់ជូនម្ចាស់គម្រោងទាំងនោះទៅប្រើប្រាស់។ តាមទិដ្ឋភាពជាក់ស្តែង តម្រូវការជាស្បៀងអាហារ ទំនិញប្រើប្រាស់ប្រចាំថ្ងៃដែរប្រជាជនតែងតែនាំយកទៅលក់នូវឯក្រៅប្រទេសជួបការលំបាកទាំងការដឹកជញ្ជូន ចំណាយខ្ពស់ទៅលើថ្លៃសេវានៃការដឹកជញ្ជូន ព្រមទាំងចំណាយទៅលើការបង់ពន្ធទាំងក្នុងស្រុក និងក្រៅស្រុក។ ជាការមើលត្រលប់មកវិញទិសដៅនៃអ្នកដែរអ្នកវិនិយោគិន និងប្រជាពលរដ្ឋបានខិតមកជិតនឹងខ្លួន ហើយវាបានជួយសម្រាលដល់ការផ្គត់ផ្គង់ព្រមទាំងកាត់បន្ថយការចំណាយជាច្រើន ជាការសន្និដ្ឋានរបស់ប្រមុខរាជរដ្ឋាភិបាលដែរធ្លាប់បានលើកឡើងកន្លងមកបានសន្មតថា វាជាការនាំចេញនូវនឹងកន្លែង។

### ១.៥.៣. លើកកម្ពស់ផ្នែកសេដ្ឋកិច្ច

បើតាមការលើកឡើងរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា ការវិនិយោគទៅលើការអភិវឌ្ឍទីក្រុងរណបគឺជាសមិទ្ធផលរបស់ជាតិ ហើយជាឧទាហរណ៍គ្រាន់តែការបង្កើតកោះនរាបានធ្វើឲ្យកំណើនសេដ្ឋកិច្ចកើនដល់ ២២៥លានដុល្លារក្នុងមួយឆ្នាំដែរវាស្មើរនឹង ០.៩ភាគនៃផលិតផលសរុបនាពេលបច្ចុប្បន្នអញ្ចឹងវាជាកំណើនផ្នែកសេដ្ឋកិច្ចរបស់យើងដែរ ហើយពេលនោះច្បាស់ណាស់រដ្ឋយកពន្ធបានរាល់ឆ្នាំ បន្ទាប់ពីនោះយកពន្ធទៅលើអចលនទ្រព្យ។ ជាការបញ្ជាក់បន្ថែមសម្តេចបានបន្តថា វាជាយុទ្ធសាស្ត្រយកស្លឹកត្នោតខ្ចប់ស្ករត្នោតដោយអភិវឌ្ឍន៍ទីក្រុងរណបកោះពេជ្រយកលុយពីកោះពេជ្រទៅធ្វើស្ពាននៅកន្លែងផ្សេងៗ ការអភិវឌ្ឍទីក្រុងរណបខាងជ្រោយចង្វារយកថវិការពីជ្រោយចង្វារទៅធ្វើសំណង់អគារសាធារណៈបានជាច្រើនកន្លែងដែរជាតម្រូវការចាំបាច់ និងការអភិវឌ្ឍទីក្រុងរណបកោះពេជ្រគឺបានទទួលថវិការមួយចំនួនធំមកធ្វើជាស្ពានឆ្លកាត់ទន្លេ ដែរទាំងអស់នេះសុទ្ធសឹងតែជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋហើយក៏បានបម្រើប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ[18]។

#### ក. ចំណូលថវិការជាតិ

តាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញពីស្ថានភាពចំណូលថវិការរដ្ឋក្នុងឆ្នាំ ២០១៩ថា ក្នុងក្របខណ្ឌនៃគោលដៅរបស់រាជរដ្ឋាភិបាលត្រូវបានបង្កើនចំណូលសរុបថវិការរដ្ឋ ឬចំណូលថវិការជាតិឲ្យស្មើនឹង ២៦ ៧៥៩ ៩៩៦ លានរៀល (ស្មើនឹង៦,៦៩០លានដូល្លារ បើគិតតាមមេគុណ៤០០០រៀលក្នុង១ដូល្លារ)[19]។ ប្រទេសកម្ពុជាមានរបបវិនិយោគបរទេសសេរី និងបើកទូលាយ ដែរមានក្របខណ្ឌច្បាប់និងគោលនយោបាយដែលជួយដល់វិនិយោគិនបរទេស។ ច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ កំណត់ដំណើរការផ្លូវការសម្រាប់ និងលើកទឹកចិត្តដល់វិនិយគិនទាំងក្នុងស្រុក និងបរទេសឲ្យចូររួមក្នុងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅកម្ពុជា[20]។ អាចទទួលអនុគ្រោះពន្ធ និងដំណើរការរដ្ឋបាលងាយស្រួល និងលឿនជាងមុនពីរដ្ឋាភិបាល បើតាមច្បាប់ភូមិបាលឆ្នាំ២០០១ វិនិយោគិនបរទេសអាចកាន់កាប់ដីបានតាមរយៈសម្បទានដីសេដ្ឋកិច្ច។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ស្របជាមួយនឹងការអភិវឌ្ឍយ៉ាងលឿនរហ័សក្នុងវិស័យអចនលទ្រព្យចំណូលពន្ធលើអចលនទ្រព្យ, ពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនប្រើប្រាស់ មានការកើនឡើងគួរឲ្យកត់សម្គាល់។

---

១៨ ប្រសាសន៍សម្តេចតេជោ ហ៊ុន សែន ក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានបេតុងពីផ្លូវជាតិលេខ១ទៅកាន់តំបន់អភិវឌ្ឍន៍កោះនរា និងស្ពានបេតុងខ្សែកាបពីតំបន់អភិវឌ្ឍន៍កោះនរាទៅកាន់ទីក្រុងកោះពេជ្រ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០

១៩ ទំព័រទី១០ នៃសៀវភៅស្តីពី ថវិការសង្ខេប ឆ្នាំ២០១៩, នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២០ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការវិនិយោគ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣

ជាក់ស្តែង ចំណូលពន្ធសរុបទាំងបីប្រភេទបានកើនពី ៣៥២ ពាន់លានរៀលក្នុងឆ្នាំ២០១៤ ដល់ ៧៥០ ពាន់លានរៀលក្នុងឆ្នាំ២០១៨[21]។ ចំពោះការសាងសង់អគារនូវក្នុងទីក្រុងរណបក៏ជាប្រភពនៃប្រមូលពន្ធផងដែរ ដើម្បីអាចធ្វើការសាងសង់រាល់អគារទាំងអស់រដ្ឋតម្រូវឲ្យមានការបង់ពន្ធជាកំហិត។

**ខ. ចំណូលប្រជាជនក្នុងស្រុកមានការកើនឡើង**

ចាប់តាំងពីមានការអនុវត្តន៍ផែនការអោយមានការរៀបចំបង្កើតទីក្រុងរណប រហូតដល់មានគម្រោងខ្លះបានសម្រេចហើយក្តី ជាការកត់សម្គាល់ប្រជាពលរដ្ឋក្នុងតំបន់បានក្តាប់យកឱកាសនេះយ៉ាងទាន់ពេលវេលា។ ពួកគេបានទទួលនូវចំណូលជាច្រើនតាមរយៈគម្រោងនៃការអភិវឌ្ឍ ចំពោះចំណូលដែរពួកគេទទួលបាននោះគឺបានមកដោយការលក់សម្ភារៈ និងចំណីអាហារជាច្រើនហើយក៏ជាតម្រូវការចាំបាច់របស់ក្រុមហ៊ុនអភិវឌ្ឍន៍ហើយការផ្គត់ផ្គង់នេះមិនមែនធ្វើតែម្តងចប់នោះទេ មានន័យប្រជាពលរដ្ឋត្រូវផ្គត់ផ្គង់ក្នុងរយៈពេលយូជាមួយបរិមាណច្រើន។ ក្រៅពីនោះការកើនឡើងនូវតម្លៃអចនទ្រព្យក៏រឹងរឹតតែមានសន្ទុះខ្លាំងខ្លាផងដែរ ជាគុណសម្បត្តិនៃសន្ទុះនេះប្រជាពលរដ្ឋដែរមានអចនទ្រព្យក្នុងតំបន់ទាំងនោះអាចធ្វើការទាញនូប្រយោជន៍មួយចំនួនទៀតដោយការវិនិយោគទៅលើអចលនទ្រព្យរបស់ពួកគេដូចជាការជួលដីនៅក្នុងតម្លៃខ្ពស់។

២១ ទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩

# ជំពូកទី២

# ការទទួលសិទ្ធិដើម្បីទទួលបានការ
# អភិវឌ្ឍលើទីក្រុងរណបនៅរាជធានី
# ភ្នំពេញស្របតាមផែនការរូបវន្តទីក្រុង

# ជំពូកទី២

# ការទទួលសិទ្ធិដើម្បីទទួលបានការអភិវឌ្ឍលើទីក្រុងរណបនៅរាជធានីភ្នំពេញស្រប តាមផែនការរូបវន្តទីក្រុង

## ២.១. ផែនការរូបន្តទីក្រុង និងនីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង

ជាយន្តការ សម្តតកិច្ចនិងភារកិច្ច ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ[22]។

### ២.១.១. ផែនការរូបវន្តទីក្រុង

ផែនការរូបវន្ត សំដៅការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីធានាការអភិវឌ្ឍ ការអភិរក្សនិងកាសាងសង់នូវក្នុងក្រុង ស្រុក ខណ្ឌ ឲ្យមានចីរភាព តុល្យភាព សុខុមាលភាព សុខភាព សោភណភាព និងសមធម៌។

ផែនការរូបវន្តទីក្រុងមាន ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម[23]៖

#### ក.ប្លង់គោលប្រើប្រាស់ដី

ប្លង់គោលប្រើប្រាស់ដី ចង់សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសសម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់អំពីប្រភេទនៃការប្រើប្រាស់ដី (ប្រភពដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ បណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍សំខាន់ៗនៃទីក្រុង ស្រុក ខណ្ឌ និងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ និងតំបន់ជុំវិញ។ ប្លង់គោលប្រើប្រាស់ដី ត្រូវភ្ជាប់ជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍ និងអភិរក្សក្រុង ស្រុក ខណ្ឌ ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី

[22] ប្រការ០៦ នៃសេចក្តីសម្រេចលេខ០៤១ សសរ, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤, ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

[23] មាត្រា១០ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

មធ្យម និងវែង។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដបប្រាំ) ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងតយៈពេល៥ (ប្រាំ)ឆ្នាំម្ដង។

ការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការការប្រើប្រាស់ដីថ្នាក់ក្រុង ត្រូវគោរពតាមគោលការណ៍ដូចមានខាងក្រោម៖

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ
- គោរពតាមឋានានុក្រមនិងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សម្ថកិច្ចជំនាញ និងអាជ្ញាធរពាក់ព័ន្ធ
- យកផែនការរូបវន្តទីក្រុង ស្រុក ខណ្ឌជាមូលដ្ឋានបង្អែកសម្រាប់ការអភិវឌ្ឍ ការអភិរក្ស ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់គ្រប់ប្រភេទក្នុងក្រុង ស្រុក ខណ្ឌ ព្រមទាំងការធ្វើសមាហរណកម្ម ដើម្បីធ្វើឲ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានតុល្យភាព និងមានសមធម៌
- រួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល និងលើកកម្ពស់ការអភិវឌ្ឍបៃតង
- យកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរា និងជនងាយរងគ្រោះ។

**ខ.ផែនការប្រើប្រាស់ដី**

ផែនការប្រើប្រាស់ដី សំដៅដល់ផែនការលម្អិតចេញប្លង់គោលប្រើប្រាស់ដី ដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្ដែង ការសាងសង់ការអភិវឌ្ឍ និងការអភិរក្សតំបន់នីមួយៗ។ ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥ (ប្រាំ)ឆ្នាំម្ដង។

ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានទំហំការងារអប្បរមាដូចខាងក្រោម៖

១. ការប្រមូល និងវិភាគទិន្នន័យៈ ត្រូវប្រមូល និងវិភាគទិន្នន័យរូបវន្ត នគរូបនីយកម្ម ការប្រើប្រាស់ដី សំណង់ លំនៅដ្ឋាន សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ធនធានធម្មជាតិ ប្លង់ និងរូបភាព។

២. ការកំណត់យុទ្ធសាស្ត្រ ត្រូវកំណត់យុទ្ធសាស្ត្រឲ្យស្របតាមប្លង់គោលប្រើប្រាស់ដី។

៣. គំនូសប្លង់ក្នុងផែនការប្រើប្រាស់ដី មានដូចជា៖

**៣.១**. ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

-ប្លង់បង្ហាញទីតាំង

-ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំផែនការប្រើប្រាស់ដី

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់កំណត់ប្រភេទប្រើប្រាស់ដី

-ប្លង់បណ្ដាញហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ

-ប្លង់លំហសាធារណៈ និងផ្ទៃបៃតង

-ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូតិ៍

-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី

-ប្លង់ផ្លាគម្លាតសំណង់ និងប្លង់តម្រង់ជួរ

-ប្លង់កំណត់កម្ពស់សំណង់

-ប្លង់សរុប។

**៣.២**. ប្លង់អនាគតកាលមានដូចជា៖

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់បែងចែកតំបន់ប្រើប្រាស់ដី

-ប្លង់បណ្ដាញហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ

-ប្លង់លំហសាធារណៈ និងផ្ទៃបៃតង

-ប្លង់បង្ហាញពីទិសដៅប្រើប្រាស់ដី

-ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូតិ៍

-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី

-ប្លង់ផ្លាគម្លាតសំណង់ និងប្លង់តម្រង់ជួរ

-ប្លង់កំណត់កម្ពស់សំណង់

-ប្លង់សរុប។

**៤**. បទបញ្ញាប្រើប្រាស់ដី ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់គ្រប់ប្រភេទ។

**៥**. ឯកសារ និងឧបសម្ព័ន្ធ។

ផែនការប្រើប្រាស់ដីក្រុង ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ[24]។

**គ.ប្លង់លម្អិតនគរូបនីយកម្ម**

ប្លង់លម្អិតនគរូបនីយកម្ម សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍន៍ទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយឬច្រើននៃក្រុង ស្រុក ខណ្ឌ ដូចជាការបង្ហាញអំពីការរៀបចំ ការរចនា ទម្រង់ រូបរាងនិងសោភសាភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ប្លង់លម្អិតនគរូបនីយកម្ម** មានទំហំការងារអប្បបរមាដូចជាខាងក្រោម៖

- **ការប្រមូលនិងវិភាគទិន្នន័យ** ផ្អែកតាមទិន្នន័យប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។
- **គំនូសប្លង់លម្អិតនគរូបនីយកម្ម** ប្លង់បង្ហាញទីតាំង ប្លង់សរុបដោយមានកំណត់ព្រំប្រទល់ ប្លង់លម្អិតការប្រើប្រាស់ដី ប្លង់បណ្តាញផ្លូវថ្នល់ ប្លង់លំហសាធារណៈនិងផ្ទៃបៃតង ប្លង់សន្ទស្សន៍ប្រើប្រាស់ដី ប្លង់ធ្លាគម្លាតសំណង់និងប្លង់តម្រង់ជួរ ប្លង់កំណត់កម្ពស់សំណង់ ប្លង់គំហើញសំណង់និងរចនាសម្ព័ន្ធ និងប្លង់នេត្រាទស្សន៍ឬគំរូសំណាក។

ប្លង់លម្អិតនគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី[25]។

**២.១.២. នីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស

[24] មាត្រា១២ នៃអនុក្រឹត្យលេខ៤២អនក្រ.បក, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[25] មាត្រា១៣ នៃអនុក្រឹត្យលេខ៤២អនក្រ.បក, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល ៦០(ហុកសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ និងផ្តល់យោបល់ដើម្បីផ្ញើរជូនទៅគណៈកម្មាធិការរៀបចំដីនិងនគរូបនីយកម្មថ្នាក់ជាតិពិនិត្យនិងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះ អាចត្រូវបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិន) ថ្ងៃនៃថ្ងៃធ្វើការ ស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិកា ររៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីរាជរដ្ឋាភិបាល ក្នុងរយៈពេលយ៉ាងយូរ៦០ (ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០ (ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេល ស្របតាមទំហំការងារជាក់ស្តែងដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ[26]។

**ក. ការផ្សព្វផ្សាយគម្រោង និងការចុះសិក្សាបឋមលើទីតាំង និងការប្រមូលទិន្នន័យ**

គណៈកម្មាធិការរៀបចំដែនដី និងនគររូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផ្សព្វផ្សាយគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ នៅទីតាំងដែលត្រូវអនុវត្តគម្រោមនេះតាមរយៈ៖

-កិច្ចប្រជុំផ្សព្វផ្សាយ ឬសិក្ខាសាលាផ្សព្វផ្សាយ នៅទីតាំងដែលត្រូវអនុវត្តគម្រោង

-ការបិទផ្សាយគម្រោងនៅទីតាំងដែលត្រូវអនុវត្តគម្រោង

-ប្រព័ន្ធឃោសនានានា ដូចជាតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវតី និងបណ្តាញព័ត៌មានវិទ្យា។ល។

ការផ្សព្វផ្សាយខាងលើនេះមានសារៈសំខាន់ណាស់ ដើម្បីឲ្យប្រជាពលរដ្ឋនៅទីតាំងនោះយល់ដឹងអំពីផលប្រយោជន៍ដែលខ្លួននិងត្រូវទទួលបានពីគម្រោងនេះ និងចូលរួមសហការ ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។ តំណាងប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយនេះ។

[26] មាត្រា១៤ នៃអនុក្រឹត្យលេខ៤២អនក្រ.បក, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនតំណឹងដល់អ្នកចូលរួម និងអ្នកពាក់ព័ន្ធឲ្យបានយ៉ាងតិច១សប្តាហ៍មុន កាលបរិច្ឆេទនៃការប្រជុំផ្សព្វផ្សាយ។

ការចុះសិក្សាបឋមលើលទីតាំង ត្រូវត្រួតពិនិត្យស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន ចរាចរណ៍ ការប្រើប្រាស់ដី និងសំណង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងព័ត៌មានរូបវន្តមួយ ចំនួនដែលមានស្រាប់ ដើម្បីជាមូលដ្ឋាន និងដាក់ចេញនូវគោលគំនិតសំខាន់ៗក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី នាពេលអនាគត។

អ្នកជំនាញបច្ចេកទេសចូលរួមក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី មានជាអាទិ៍ នគរូបនីយកម្ម ស្ថាបត្យករ អ្នករៀបចំដែនដី វិស្វករ ប្រជាសាស្ត្រវិទូ អ្នកច្បាប់ សង្គមវិទូ សេដ្ឋកិច្ចវិទូ និងអ្នកជំនាញផ្សេងៗទៀត ដែលមានការ ពាក់ព័ន្ធ។ល។ អ្នកជំនាញទាំងនេះត្រូវសហការគ្នាលើកឡើងនូវគំនិតច្នៃប្រឌិតខ្ពស់ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី។ អ្នកជំនាញទាំងនេះត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួនស្របតាមវិសាលភាពការងារថវិការ និងពេលវេលា ដែលបានកំណត់តាមជំហាននីមួយៗ។

ការចុះប្រមូលទិន្នន័យ ដែលរួមមានទិន្នន័យបឋមនិងទិន្នន័យទី២ ត្រូវបានធ្វើឡើងក្នុងក្របខណ្ឌនៃដែនដីដែរត្រូវរៀបចំប្លង់គោលប្រើប្រាស់ដី ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ ទិន្នន័យមានសារៈសំខាន់ជាមូលដ្ឋានគ្រឹះសិក្សាវិភាគស្វែងយល់ពីស្ថានភាពបច្ចុប្បន្នក្នុងគោលដៅរៀបចំប្លង់គោលប្រើប្រាស់ដីនាពេលអនាគត។

ទិន្នន័យនិងពត៌មានដែលត្រូវប្រមូលមានជាអាទិ៍ ទិន្នន័យរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ការប្រើប្រាស់ដី និងសំណង់ ប្រជាសាស្ត្រ គម្រោងអភិវឌ្ឍន៍។ល។ ទិន្នន័យនិងពត៌មានទាំងនេះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើជារបាយការណ៍បច្ចេកទេស និងប្លង់[27]។

### ខ. ការវិភាគទិន្នន័យ និងការរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រ

ការវិភាគទិន្នន័យមានគោលបំណងវិភាគពីលក្ខខណ្ឌមានស្រាប់ដើម្បីស្វែងរកបញ្ហាដែលកើតមាន និងសក្តានុពលរបស់តំបន់។ លទ្ធផលនៃការវិភាគទិន្នន័យខាងលើនេះ ត្រូវបង្ហាញនៅលើប្លង់ និងដ្យាក្រាមផ្សេងៗ ដោយធ្វើចំណោល ដើម្បីកំណត់នូវការវិវត្ត និងការរៀបចំផែនការនាពេលអនាគត។

[27] ប្រការ១១,១២,១៣ នៃសេក្តីសម្រេចលេខ០៤១ សសរ, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤, ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំទិន្នន័យ និងព័ត៌មានទៅតាមលំដាប់លំដោយ និងតាមប្រភេទនីមួយៗ បន្ទាប់មកធ្វើការវិភាគតាមវិធីសាស្ត្រវិភាគបែបការរៀបចំសេចក្តីព្រាងបរិមាណ និងវិភាគតាមគុណភាព។

**គ. ការបិទផ្សាយជាសាធារណៈ**

ការបិទផ្សាយជាសាធារណៈ គឺជាការផ្សព្វផ្សាយនូវលទ្ធផលបឋម នៃការរៀបចំប្លង់គោលប្រើប្រាស់ដី ដើម្បីទទួលសំណើរ ព្រមទាំងការតវ៉ាផ្សេងៗ។ មន្ត្រីជំនាញដែលប្រចាំការនៅទីតាំងបិទផ្សាយមានភារកិច្ចពន្យល់នូវសំណួរ និងការឆ្លើយឆ្លងទាំងឡាយ របស់សាធារណៈជន ចំពោះសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី ដែលនឹងត្រូវអនុម័តក្រោយពេលបិទផ្សាយរួច។

**ឃ. ការកែសម្រួលចុងក្រោយ**

ការកែសម្រួលចុងក្រោយ ត្រូវធ្វើឡើងនៅពេលទទួលបានការសម្រេចពីគណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុងជាតិ ដោយយោងទៅលើរបាយការណ៍របស់គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងមតិយោបល់របស់គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងដោយផ្អែកទៅលើទិដ្ឋភាពបច្ចេកទេស ច្បាប់ សេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងប្រពៃណីរស់នៅរបស់ប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌ។

ក្រោយពីការកែសម្រួលចុងក្រោយរួចហើយ គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនឯកសារទៅគណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ តាមរយៈគណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ដើម្បីសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ឯកសារខាងលើនេះត្រូវផ្ញើជូន៖

-គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ នៃសាមីប្លង់គោលប្រើប្រាស់ដី ដើម្បីអនុវត្តន៍

-គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានទីតាំងជាប់ព្រំក្រុង ស្រុក ខណ្ឌ សាមីប្លង់គោលប្រើប្រាស់ដី ដើម្បីសហការអនុវត្ត

-គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ដើម្បីតាមដានការអនុវត្ត

-រក្សាទុកមួយច្បាប់នៅគណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីតាមដានការអនុវត្ត

-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីជូនជ្រាប និងរក្សាទុកជាឯកសារ។

**ខ. ការរៀបចំគម្រោងអទិភាព**

ការអនុវត្តគម្រោងត្រូវធ្វើទៅតាមលំដាប់អាទិភាពដែលបានសម្រេចជាផ្លូវការ។

គម្រោងអាទិភាព ជាប្រភេទនៃប្លង់លម្អិតនគរូបនីយកម្មដែលមានសារៈសំខាន់សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដី និងបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមូលដ្ឋានក្នុងការបញ្ចូលគម្រោងទាំងនេះក្នុងផែនការស្នើសុំថវិកា ដើម្បីអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនទៅតាមលំដាប់អាទិភាព។

គម្រោងអាទិភាព ត្រូវបែងចែកឲ្យបានច្បាស់រវាងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់គ្រោងថ្មី។ ចំពោះហេដ្ឋារចនាសម្ព័ន្ធគ្រោងថ្មី ត្រូវបង្ហាញនៅលើប្លង់ដែលងាយស្រួលយល់ ហើយធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលត្រូវកសាងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង (គម្រោងថ្មីអាចរៀបចំនៅលើទីតាំង ឬអាចរៀបចំកែលម្អនៅលើទីតាំងចាស់)។ បន្ទាប់មកយកគម្រោងនីមួយៗរៀបតាមលំដាប់អាទិភាពនៅក្នុងបញ្ជីមួយ ដោយភ្ជាប់ជាមួយនឹងការបរិយាយ ពីមូលហេតុនៃការធ្វើចំណាត់ថ្នាក់នេះ ព្រមទាំងតម្លៃប៉ាន់ស្មាន់នៃគម្រោងនីមួយៗ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ច. ការសម្រេចលើប្លង់គោលប្រើប្រាស់ដី**

ការសម្រេចលើសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី មានអត្ថប្រយោជន៍ក្នុងការធ្វើឲ្យមានតម្លៃជាផ្លូវការ និងជាមូលដ្ឋានបង្អែក ក្នុងការអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី ព្រមទាំងសំណុំឯកសារពាក់ព័ន្ធ (របាយការណ៍បច្ចេកទេស ប្លង់នានា គម្រោងអាទិភាពឯកភាពឧបសម្ព័ន្ធនានា...) ក្នុងរយៈពេលយ៉ាងយូរ១៥ (ដប់ប្រាំ)ថ្ងៃ ដើម្បីដាក់ជូនៈ

១. ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យ និងឯកភាពក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប) ថ្ងៃ។

២. គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យ និងឯកភាព ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ។

៣. ក្រុមប្រឹក្សារាជធានី ខេត្ត ពីនិត្យ និងឯកភាពក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃ។

៤. គណៈកម្មធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ពិនិត្យ និងសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃ។

## ២.២. ការគ្រប់គ្រងការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង និងការកសាងទីក្រុង

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងកិច្ចការនគរូបនីយកម្ម និងសំណង់ ដើម្បីធានាបាននូវការអភិវឌ្ឍ និងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព តុល្យភាព ចីរភាព សមធម៌ សុខដុមនីយកម្ម និងសមាហរណកម្ម។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើប្រតិភូកម្មការគ្រប់គ្រង កិច្ចការបច្ចេកទេសនគរូបនីយកម្មនិងសំណង់ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ទៅតាមតម្រូវការ និងស្ថានភាពសមត្ថភាពស្របតាមបទប្បញ្ញត្តិជាធរមាន។ អគ្គនាយកដ្ឋាបរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកសំណង់ ជាសេនាធិការផ្ទាល់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះការងារនេះ។

ទីក្រុងត្រូវបានអនុវត្តតាមរយៈគម្រោងសាងសង់ គម្រោងអភិវឌ្ឍន៍ទីក្រុង និងគម្រោងអភិរក្សក្នុងទីក្រុង ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ដី ការកែលម្អ និងបំពេញបន្ថែមហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងបរិស្ថានល្អស្អាត ដើម្បីធានាបាននូវការអភិវឌ្ឍ និងអភិរក្ស ប្រកបដោយចីរភាព សមធម៌ និងការធ្វើសមាហរណកម្ម។ ការអភិវឌ្ឍទីក្រុងត្រូវគិតអំពីតម្រូវការខាងលំនៅឋានសមស្រប និងមានតុល្យភាពរវាងលទ្ធភាពដែលគ្រួសារក្រីក្រ និងអ្នកមានប្រាក់ចំណូលទាប អាចរកបានលំនៅឋានសមរម្យ និងតម្រូវការសេដ្ឋកិច្ចរបស់រដ្ឋ និងផ្នែកឯកជន។

### ២.២.១. ក្រសួងមានសមត្ថកិច្ចគ្រប់គ្រងកិច្ចការនគរូបនីយកម្ម និងសំណង់

យោងតាមមាត្រា៥៦ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងកិច្ចការនគរូបនីយកម្ម និងសំណង់ដើម្បីធានាបាននូវការអភិវឌ្ឍ និងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព សមធម៌ សុខដុមនីយកម្ម និងសមាហរណកម្ម។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើប្រតិភូកម្មការគ្រប់គ្រងកិច្ចការបច្ចេកទេសនគរូបនីយកម្ម និងសំណង់ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ទៅតាមតម្រូវការ និងស្ថានភាពសមត្ថភាពស្របតាមបទបញ្ញត្តិជាធរមាន។ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់ ជាសេនាធិការផ្ទាល់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះការងារនេះ។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតនៅក្រោមការសម្របសម្រួលរបស់អភិបាលរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ។

អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ មានសិទ្ធិ និងភារកិច្ចដូចខាងក្រោមៈ

-ត្រូវពិនិត្យការអភិវឌ្ឍអចលនវត្ថុ និងសុវត្ថិភាពការងារនៅខាងក្នុង និងជុំវិញបរិវេណការដ្ឋានសំណង់

-តម្រូវឲ្យម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍន៍អចលនវត្ថុផ្តល់ព័ត៌មាន និងបង្ហាញគ្រប់លិខិតដែលពាក់ព័ន្ធ និងការអភិវឌ្ឍអចលនវត្ថុ

-បញ្ជាឲ្យកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍន៍ចលនវត្ថុ

-ផ្អាក់ការដ្ឋានសាងសង់ជាបណ្តោះអាសន្ន

-ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រ ប្រកបអាជីវកម្មសាងសង់

-ហាមឃាត់ជាបណ្តោះអាសន្ននូវការប្រើប្រាស់អាគារ ឬការធ្វើអាជីវកម្មលើអាគារ

-បំពេញភារកិច្ចផ្សេងទៀតដែលបានប្រគល់ជូនដោយអាជ្ញាធរធម្មានរូប។

### ២.២.២. នីតិវិធីនៃការស្នើសុំការអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ

សំណុំលិខិតស្នើសុំការអនុញ្ញាតអភិវឌ្ឍន៍អចលនវត្ថុទាំងអស់ ត្រូវសរសេរជាភាសាខ្មែរដែលជាភាសាផ្លូវការ។ ភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាបរទេសផ្សេងទៀត អាចសរសេរនៅខាងក្រោមភាសាខ្មែរ ដែលមានទំហំអក្សរតូចជាងភាសាខ្មែរ។ សំណុំលិខិតស្នើសុំការអភិវឌ្ឍអចលនវត្ថុ ត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេលកំណត់មួយមុនការសម្រេចផ្តល់លិខិតអនុញ្ញាតជូន ដើម្បីទទួលបណ្តឹងតវ៉ានិងធានាទប់ស្កាត់ទំនាស់នៃការប្រើប្រាស់ដី។

នីតិវិធី និងសំណុំឯកសារសម្រាប់ការស្នើសុំការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និង/ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ដើម្បីធានាបាននូវការគ្រប់គ្រងកិច្ចការបច្ចេកទេសនគរូបនីយកម្ម និងសំណង់និងជាគ្រឹះនៃភាពស្របច្បាប់ ការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទ ត្រូវមានការស្នើសុំលិខិតអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងក្រសួង ស្ថាប័នមានសមត្ថកិច្ច។ ការអភិវឌ្ឍអចលនវត្ថុដែលត្រូវមានលិខិតអនុញ្ញាតរួមមាន៖

១. ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការពង្រីកអគារ និងការសង់បន្ថែមពីលើអគារដែលមានស្រាប់ ការប្តូរមុខងារប្រើប្រាស់អគារ ការប្តូរទ្រង់ទ្រាយអគារ ការបង្កើនផ្ទៃក្រឡាកម្រាលសំណង់ និងការកែប្រែទិដ្ឋភាពខាងក្រៅនៃអាគារដែលមានស្រាប់ ការជួសជុល និងរុះរើ។

២. ការសាងសង់ ឬការប្តូរទ្រង់ទ្រាយអគារដែលអាចបង្កគ្រោះថ្នាក់អគ្គីភ័យ ដូចជាការដាក់ស៊ីទែន កន្លែងស្តុកផលិតផលតេលសិលា រោងជាងផលិតគ្រឿងផ្ទុះ។ល។

៣. ការដាក់ស្លាកសញ្ញាផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍និងទូរគមនាគមន៍ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ក៏ដូចជាការដាក់រចនាសម្ព័ន្ធនៅលើដី និងអគារ។

៤. ការអភិវឌ្ឍដី (ការកែប្រែរចនាសម្ព័ន្ធដើមនៃដី ការចាក់ដីបំពេញ ការជីកយកដីចេញ ការបង្រួមក្បាលដី ការបំបែកក្បាលដី ការប្តូរប្រភេទនៃការប្រើប្រាស់ដី និងការប្តូរមុខងារតំបន់ប្រើប្រាស់ដី។ល។

៥. គម្រោងអភិវឌ្ឍទីក្រុង ដូចមានចែងក្នុងជំពូកទី៧ នៃអនុក្រឹត្យនេះ។

៦. ការផ្លាស់ប្តូរលក្ខណៈគតិយុត្តផ្សេងៗទៀត មានជាអាទិ៍ ការពន្យារសុពលភាពនៃលិខិតអនុញ្ញាតដែលហួសសុពលភាព ការផ្ទេរឈ្មោះក្នុងលិខិតអនុញ្ញាត។ល។

ដើម្បីឲ្យប្រជាពលរដ្ឋមានភាពងាយស្រួល ការសាងសង់ថ្មីឬការជួសជុលលំនៅឋានតូចតាច និងពុំមានលក្ខណៈជាការធ្វើពាណិជ្ជកម្មមិនតម្រូវឲ្យស្នើសុំលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋាន និងបិទការដ្ឋានឡើយ ហើយដែលត្រូវកំណត់នៅក្នុងអនិក្រឹត្យដោយឡែក[28]។

ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍន៍អចលនវត្ថុដែលមិនសុខចិត្តចំពោះវិធានការបញ្ជាឲ្យកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍន៍អចលនវត្ថុ ផ្អាក់ការដ្ឋានសាងសង់ជាបណ្តោះអាសន្ន ឃាត់ទុកជាបណ្តោះអាសន្ននូវសម្ភារៈ

[២៨] មាត្រា៥៧ នៃអនុក្រឹត្យលេខ៤២អនក្រ.បក, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

ឧបករណ៍ គ្រឿងចក្រ មធ្យោបាយផ្សេងៗដែលមាននៅក្នុងការដ្ឋានសាងសង់ ដកហូតជាបណ្ដោះអាសន្ន នូវលិខិតអនុញ្ញាត សាងសង់ បើកដ្ឋានសាងសង់ ឬវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ ហាមឃាត់ជាបណ្ដោះអាសន្ននូវការប្រើប្រាស់ អាគារ ឬការធ្វើអាជីវកម្មលើអាគាររបស់អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ អាចធ្វើបណ្ដឹងតវ៉ា ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈ អភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេចខាងលើ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល៣០ ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្ដឹង។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល៣០ ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃ ទទួលបណ្ដឹង។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល៣០ ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃទទួលបណ្ដឹង[29]។

នីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ២.៣. ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្ដល់សេវាសាធារណៈជូនសាធារណៈជន

### ២.៣.១. ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គឺជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានជាអាទិ៍ បណ្ដាញផ្លូវសាធារណៈ បរិក្ខារសាធារណៈ (ប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្ដាញអគ្គិសនី បណ្ដាញទូរគមនាគមន៍...) ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ (ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម អាងប្រព្រឹត្តកម្មទឹកកខ្វក់...) ប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ និងហានិភ័យផ្សេងៗ។ល។

ទំហំសមាមាត្រដីសម្រាប់បម្រើឲ្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវកំណត់យ៉ាងតិច២៥(ម្ភៃប្រាំ) ភាគរយនៃប្រភេទដីអាចសាងសង់បាន។

**ហេដ្ឋារចនាសម្ព័ន្ធសាធារណៈរួមមានៈ**

---

[២៩] មាត្រា៦៤ នៃអនុក្រឹត្យលេខ៤២អនក្រ.បក, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

- បណ្តាញផ្លូវសាធារណៈ
- បរិក្ខារសាធារណៈ ដូចជាប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍។ល។
- ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ ដូចជា ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម ប្រព័ន្ធលូ អាងប្រព្រឹត្តកម្មទឹកកខ្វក់។ល។
- ប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ និងហានិភ័យផ្សេងៗ។

**២.៣.២. សំណង់ផ្តល់សេវាសាធារណៈជូនសាធារណៈជន**

ការរៀបចំផែនការរូបវន្តទីក្រុង ត្រូវរៀបចំឲ្យមានអគារបម្រើសេវាសាធារណៈគ្រប់គ្រាន់ទៅតាមតម្រូវការចាំបាច់ដូចជាសាលារៀន មណ្ឌលសុខភាព អគាររដ្ឋបាលជាដើម ដើម្បីធានាការផ្តល់នូវសេវាសាធារណៈប្រកបដោយប្រសិទ្ធិភាព និងមានសមធម៌។ គ្រប់អគារបម្រើសេវាសាធារណៈ ត្រូវមានការរៀបចំសម្រាប់មនុស្សទាំងអស់គ្នារួមទាំងជនពិការ និងជនចាស់ជរាផង ក្នុងនោះរួមមាន៖

- អគាររដ្ឋបាលសាធារណៈ អគារសិក្សាសាធារណៈ មន្ទីរពេទ្យសាធារណៈ
- ចំណតរថយន្តសាធារណៈ ចំណតរថយន្តក្រុង ចំណតរថយន្តឈ្នួល ស្ថានីយរថភ្លើងសម្រាប់អ្នកដំណើរ ស្ថានីយចែកចាយទំនិញ ផែស្ងួត មជ្ឈមណ្ឌលផ្គត់ផ្គង់ភស្តុភាកម្ម។ល។ ត្រូវរៀបចំសម្រាប់មនុស្សទូទៅនិងជនពិការ និងមិនត្រូវមានសំណង់ដែរស្ថិតនៅលើចិញ្ចើមផ្លូវសាធារណៈសម្រាប់អ្នកថ្មើរជើងឡើយ។

**២.៣.៣. អំពីលំហរសាធារណៈ**

សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា ទីលានកម្សាន្ត។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណៈជននិងលំហសាធារណៈត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការនិងជនងាយរងគ្រោះ។ នៅពេលដំណើរការការអនុវត្តគម្រោងអភិវឌ្ឍន៍នានាដើម្បីផលប្រយោជន៍សាធារណៈដែលប៉ះពាល់ដល់កម្មសិទ្ធិឯកជនស្របច្បាប់ ការដកហូតកម្មសិទ្ធិមួយផ្នែក ឬទាំងស្រុង ត្រូវអនុវត្តតាមច្បាប់អស្សាមិករណ៍។

## ២.៤. សកម្មភាពអភិវឌ្ឍន៍បន្ត និងវិនិយោគសាធារណៈ

ក្រោមកិច្ចអភិវឌ្ឍន៍ដែរមានការរីកដុះដាលជាច្រើនបែបនេះរដ្ឋគួរមានវិធានការ និងគោលនយោបាយច្បាស់លាស់ក្នុងការទាញប្រយោជន៍ពីការអភិវឌ្ឍនៃទីក្រុងរណបឲ្យបានទាន់ពេលវេលា។ ពេលវេលានេះជាឳកាសដ៏

ល្អដែររដ្ឋាភិបាលគួរតែចូររួមចំណែកក្នុងការវិនិយោគជាមួយក្រុមហ៊ុននៃម្ចាស់គម្រោងតាមរយៈការផ្តល់នូវសេវាសាធារណៈរបស់រដ្ឋទៅកាន់ប្រជាជន ដូចជាវិស័យដឹកជញ្ជូនជាដើម។

### ២.៤.១. ការកសាង និងការអភិវឌ្ឍបន្តទីក្រុងរណបនានាដូចជា កោះពេជ្រ ជ្រោយចង្វារ និងបឹងកក់

ការបង្កើតទីក្រុងរណបនៅតាមបណ្តាជាយក្រុង គឺជាការចូររួមចំណែកយ៉ាងប្រសើរជាមួយរាជរដ្ឋាភិបាល ដែលអាចជួយសម្រួល និងលើកកម្ពស់ដល់នគរូបនីយកម្មបានមួយចំណែកធំ។ គម្រោងបង្កើតទីក្រុងរណប ដែលស្របទៅតាមប្លង់គោលប្រើប្រាស់ដីរបស់រាជធានីភ្នំពេញ គឺជាការអភិវឌ្ឍប្រកបដោយភាពត្រឹមត្រូវ ដែលក្រៅពីអាចទាក់ទាញមនុស្សឲ្យចាប់អារម្មណ៍ជាមួយគម្រោង ថែមទាំងអាចចូររួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការបែងចែកល្បាយនៃការរស់នៅ ក៏ដូចជាការប្រកបអាជីវកម្មរបស់មនុស្សទូទៅយ៉ាងប្រសើរ។ ផ្ទុយទៅវិញបើគម្រោងនៃការបង្កើតទីក្រុងរណប មិនស្របតាមប្លង់គោលប្រើប្រាស់ដីរបស់រាជធានីភ្នំពេញទេវាបែរជាបង្កើតទៅជាបញ្ហានាពេលអនាគត ហើយក៏អាចធ្វើឲ្យគម្រោងទាំងមូលជួបភាពបង់ខាតផងដែរ។ ការរៀបចំប្លង់គោល ដើម្បីងាយស្រួលក្នុងដំណើរការអភិវឌ្ឍនៅតំបន់ណាមួយប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដែលស្របទៅនឹងបរិបទនៃការរស់នៅដូចជាតំបន់លំនៅដ្ឋាន តំបន់សេដ្ឋកិច្ច ក៏ដូចជាតំបន់ឧស្សាហកម្មជាដើម។ ជាទូទៅរដ្ឋាភិបាលតែងតែលើកទឹកចិត្ត និងគាំទ្ររាល់គម្រោងទាំងឡាយណាដែលបានចូររួមចំណែកក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនកំណើនសេដ្ឋកិច្ចកម្ពុជា។

គ្រប់គម្រោងនៃការអភិវឌ្ឍទីក្រុងរណបទាំងអស់ គឺសុទ្ធតែមានផលវិជ្ជមានច្រើនជាងផលអវិជ្ជមាន។ វត្តមាននៃទីក្រុងរណបមានចំណុចល្អច្រើនស្ទើរតែទាំងអស់ ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលចូររួមអភិវឌ្ឍន៍ជាមួយរដ្ឋាភិបាលបានមួយផ្នែកធំ ការចូររួមលើកកម្ពស់នៅក្នុងវិស័យសំណង់ និងអចនទ្រព្យ ក៏ដូចជាការចូររួមទៅលើផ្នែកបច្ចេកវិទ្យានៃសំណង់សម័យថ្មីផងដែរ។ នៅពេលដែលមានការបែងចែកតំបន់ក្រុង ផ្សេងគ្នាកាន់តែច្រើន វានឹងចូររួមសម្រួលដល់សង្គមកាន់តែច្រើន ជាក់ស្តែងដូចជាបញ្ហាកកស្ទះចរាចរណ៍ត្រូវបានកាន់បន្ថយច្រើន ដោយសារតែនៅក្នុងទីក្រុងរណបភាគច្រើនសុទ្ធតែមានការបង្កើតជាតំបន់ពាណិជ្ជកម្មទាំងអស់ដែលអ្នករស់នៅអាចធ្វើការបង្វែរគោលដៅទីតាំងអាជីវកម្ម ក៏ដូចជាកន្លែងការងារជាដើម។

ដូចដែលបានលើកឡើងកន្លងមក រាល់បើទោះបីជាគម្រោងនៃការអភិវឌ្ឍមានរហូតទៅដល់៨ក៏ដោយ ក៏ប៉ុន្តែគម្រោងកោះពេជ្រ ជ្រោយចង្វារ និងបឹងកក់ហាក់មានសន្ទុះខ្លាំងជាងគេ។ ដោយបូកសរុបបញ្ចូលគ្នាមានរហូតដល់ជាង ៣០០០លានដុល្លារអាមេរិក ក្រៅពីទុនវិនិយោគជាច្រើននេះហើយ គម្រោងទាំងនោះបានគៀងគរនូវការវិ

និយោគមកបណ្តាក់ទុនក្នុងគម្រោងរបស់ពួកគេរាប់រយពាន់លានដុល្លារបន្ថែមទៀត ដែរធ្វើអោយសេដ្ឋកិច្ចមានការកើនឡើង ហើយចំណូលជាតិក៏មានការកើនឡើងខ្ពស់ផងដែរតាមរយៈការប្រមូលពន្ធពីការវិនិយោគទាំងនោះ។

**២.៤.២. ជម្រុញឲ្យមានការអភិវឌ្ឍទីក្រុងរណបកាន់តែច្រើនឡើងៗ**

ស្របតាមកំណើននៃការអភិវឌ្ឍ និងការកើនឡើងនៃចំនួនប្រជាជនមករស់នៅរាជធានីភ្នំពេញ គិតមកត្រឹមដើមឆ្នាំ២០២០នេះ គម្រោងទីក្រុងរណបបានកើនឡើងមានរហូតដល់៨គម្រោង ក្រោមកិច្ចសហការវិនិយោគពីសំណាក់ក្រុមហ៊ុនជាតិ និងអន្តរជាតិ ដែលគាំទ្រដោយរាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយនូវភាពកកកុញនៃចំនួនមនុស្សដែលរស់នៅផ្តុំគ្នានូវរាជធានីភ្នំពេញ។ គម្រោងអភិវឌ្ឍន៍ទីក្រុងរណបនីមួយ បានបង្កើតឡើងក្នុងគោលបំណងបង្កើនភាពទាក់ទាញ និងការចាប់អារម្មណ៍ឲ្យមានមនុស្សចូរទៅរស់នៅកាន់តែច្រើន ក្រៅពីមានលក្ខណៈប្រសើរនៃហេដ្ឋារចនាសម្ព័ន្ធ មានជាសុខភាពខ្ពស់ក្នុងការរស់នៅជាមួយធម្មជាតិនៅក្នុងគម្រោងក៏បានរួមបញ្ចូល នៅការអភិវឌ្ឍតំបន់ពាណិជ្ជកម្ម អគាររដ្ឋបាល តំបន់កម្សាន្ត មជ្ឈមណ្ឌលពាណិជ្ជកម្ម ផ្សារទំនើប ក្លឹបហាត់ប្រាណ សួនឧស្សាហកម្ម សាលារៀន មន្ទីរពេទ្យ និងសេវាសាធារណៈផ្សេងៗទៀត។

កន្លងមកដោយមើលឃើញពីសក្តានុពលនៃការអភិវឌ្ឍទីក្រុងរណប បានធ្វើអោយរដ្ឋាភិបាលមានការយកចិត្តទុកដាក់ជាខ្លាំង ទន្ទឹមនឹងនោះរាល់គម្រោងនៃការអភិវឌ្ឍត្រូវបានគាំពារដោយច្បាប់ និងមានការលើកទឹកដោយរាជរដ្ឋាភិបាលតាមរយៈការសម្រួលនីតិវិធីនៃការចុះបញ្ជីជាមួយឯកសារតាមផ្លូវច្បាប់ផ្សេងៗទៀត។

# ជំពូកទី៣

# ផលប៉ះពាល់ដែលកើតចេញពីការអភិវឌ្ឍទីក្រុងរណប

# ជំពូកទី៣
# ផលប៉ះពាល់ដែលកើតចេញពីការអភិវឌ្ឍទីក្រុងរណបនៅរាជធានីភ្នំពេញ

## ៣.១. ផលប៉ះពាល់

ការរៀបចំក្រុង គឺជាបញ្ហាដែលពាក់ព័ន្ធជាមួយការរៀបចំ រូបរាងនិងមុខងារ តំបន់ជាយក្រុង ទីប្រជុំជន ឬក្រុងដែរមានស្រាប់ ឬមិនទាន់មាន ឲ្យមានសោភណភាព និងសណ្តាប់ធ្នាប់។ វាក៏ជាអភិក្រម និងលទ្ធផលនៃការបង្កើតឲ្យមាននូវមូលដ្ឋានមួយដែលមានមនុស្សអាចរួមរស់ជាមួយគ្នា ប្រាស្រ័យទាក់ទងគ្នាដោយងាយក្នុងតំបន់នោះផងដែរ។ ការអភិវឌ្ឍទីក្រុងមិនថានៅក្នុងប្រទេសកម្ពុជា ឬក៏ប្រទេសនានាក្នុងសកលលោកនោះទេ រមែងតែងតែមានផលប៉ះពាល់ទាំងដោយផ្ទាល់ និងដោយប្រយោល ក្នុងនោះមានទាំងបរិស្ថាន និងទំនាស់ដីធ្លីជាមួយប្រជាជននៅទីតាំងដែរត្រូវអភិវឌ្ឍន៍។

### ៣.១.១. បរិស្ថាន

គម្រោងនៃការអភិវឌ្ឍទីក្រុងរណបនៅរាជធានីភ្នំពេញសព្វថ្ងៃនេះ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើបរិស្ថានដោយហេតុថារាល់គម្រោងនៃការអភិវឌ្ឍស្ទើរតែទាំងអស់សព្វថ្ងៃសុទ្ធសឹងតែធ្វើឡើងដោយការចាក់លុបបឹង និងទន្លេ។ ជាក់ស្តែងគម្រោងអភិវឌ្ឍទីក្រុងរណបកោះពេជ្រ និងទីក្រុងរណបកោះនាររបស់ក្រុមហ៊ុនសាជីវកម្មវិនិយោគក្រៅប្រទេសកម្ពុជាOCIC ដែរគ្រប់គ្រងដោយអ្នកឧកញ៉ា ពុង ឃាវសែ។ ក្រុមអ្នកជំនាញថាគម្រោងនៃការលុបទឹកទន្លេនេះគឺជាហានិភ័យធ្ងន់ធ្ងរដែរទំនងធ្វើអោយពលរដ្ឋគេចមិនផុតពីផលប៉ះពាល់បរិស្ថាន និងសង្គមរយៈពេលខ្លីនិងរយៈពេលវែង អ្នកជំនាញបរិស្ថានសង្កេតឃើញថាបច្ចុប្បន្ននេះត្រីមិនសូវផ្លាស់ទីឯលំហូរទឹកក៏មិនសូវហូរច្រោះចេញពីទន្លេមេគង្គចាក់ចូរទន្លេសាបនោះទេ ព្រោះដោយសារការចាក់ដីចូរទន្លេដើម្បីអភិវឌ្ឍន៍ទីក្រុងរណប ផលប៉ះពាល់ទាំងនេះបណ្តាលអោយត្រីរាប់រយប្រភេទមិនអាចបង្កកំណើតបាន។ ទាំងនេះសុទ្ធសឹងតែជាផលប៉ះពាល់ដោយបផ្ទាល់ក្នុងនោះក៏នៅមានផលប៉ះពាល់ដោយប្រយោលមួយចំនួនទៀតដែរពុំអាចមើលរំលងបាននោះគឺ ការទាញយកធនធានធម្មជាតិដើម្បីបម្រើអោយការអភិវឌ្ឍទីក្រុងរណបមានដូចជា ការបូមយកខ្សាច់យ៉ាងច្រើនសន្ធឹកសន្ធាប់ពីបាតទន្លេនៅតាមបណ្តាកន្លែងផ្សេងៗគ្នានៅទន្លេមេគង្គព្រមទាំងនៅទន្លេសាប ដើម្បីយកមកចាក់បំពេញនូវទីតាំងមួយដែរក្រុមហ៊ុនវិនិយោគចង់អភិវឌ្ឍន៍អោយក្លាយទៅជាទីក្រុងថ្មីមួយ។ គួរយល់ដឹងថាការយកខ្សាច់យ៉ាងច្រើនសន្ធឹកសន្ធាប់នេះពុំគ្រប់គ្រាន់នោះទេ ពោលតម្រូវការធនធានផ្សេងៗជាច្រើនទៀតក៏ជាតុផ្សំចាំបាច់ដែរមិនអាចខ្វះបាន

ឡើយ ដែររួមមានតម្រូវការថ្ម ដីភ្នំ និងស៊ីម៉ង់ ដែរទាមទារអោយមានការវាយកម្ទេចភ្នំជាច្រើន ដើម្បីទាញយកនូវដី និង ថ្មទាំងនោះមកសាងសង់។

បើក្រឡេកទៅមើលគម្រោងនៃការអភិវឌ្ឍធំមួយទៀតនៅឯភាគខាងត្បូងរាជធានីភ្នំពេញ នៅឆ្នាំ២០០៤ក្រុមហ៊ុនអភិវឌ្ឍន៍ អាយ អិន ជី ហូលឌីង (ING Holdings) ទទួលបានសិទ្ធិអភិវឌ្ឍន៍នៅតំបន់នោះ ក្រោមគម្រោងនៃការអភិវឌ្ឍរបស់ក្រុមហ៊ុនបានធ្វើការលុបបឹងដ៏ធំមួយគឺបឹងទំពុន ឬបឹងជើងឯក។ ការលុបបឹងនេះមានការប្រតិកម្មជាច្រើនពីសំណាក់អង្គការសង្គមស៊ីវិល តាមរបាយការណ៍របស់អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ បានលើកឡើងថា ក្រុមហ៊ុន អាយ អិន ជី ហូលឌីង (ING Holdings) បានអភិវឌ្ឍន៍គម្រោងទីក្រុងរណប ដែលគ្របដណ្តាប់លើផ្ទៃដី ២.៥៧២ ហិកតា នៅក្នុងតំបន់បឹងទំពុន ឬជើងឯកតាំងពីឆ្នាំ២០០៤ ក៏ប៉ុន្តែកិច្ចសន្យាជួល មិនត្រូវបានបង្ហាញជាសាធារណៈឡើយ។ តំបន់បឹងទំពុនត្រូវបានចាត់ទុកថា ជាតំបន់ដីសើមដែរត្រូវបានសាធារណៈជនប្រើប្រាស់ និងផ្តល់ប្រយោជន៍ជាសាធារណៈតាមរយៈការការពារទឹកជំនន់ និងការប្រព្រឹត្តកម្មទឹកកខ្វក់តាមធម្មជាតិ[30]។ ស្រដៀងគ្នានេះ ក្រុមហ៊ុនអភិវឌ្ឍន៍ ស៊ូកាគូអ៊ិន ដែរបានធ្វើការអភិវឌ្ឍទៅលើបឹងកក់ក៏មានសភាពប្រហាក់ប្រហែលនឹងក្រុមហ៊ុន អាយ អិន ជី ហូលឌីង ដែរ គឺដោយការធ្វើសម្បទានសេដ្ឋកិច្ចទៅលើបឹងកក់ក្នុងគោលបំណងយកមកបង្កើតឲ្យទៅជាទៅក្រុងរណបថ្មីមួយដែរស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញ។

### ៣.១.២. ទំនាស់ដីធ្លីជាមួយប្រជាជននៅទីតាំងដែរត្រូវអភិវឌ្ឍន៍

ក្រោមកិច្ចការអភិវឌ្ឍទីក្រុងរណបនៅរាជធានីភ្នំពេញ ក្រុមហ៊ុនវិនិយោគធំៗតែងតែបានជួបនូវបញ្ហាទំនាស់ដីធ្លីជាមួយប្រជាជនដែរបានតាំងលំនៅឋាននៅលើដីទាំងនោះ ទាំងដែរក្រុមហ៊ុនទទួលបានសិទ្ធិអភិវឌ្ឍន៍ឲ្យទៅជាទីក្រុងរណបពីសំណាក់រាជរដ្ឋាភិបាលរួចទៅហើយ។ ក្រុមហ៊ុនវិនិយោគមួយចំនួនធំបានជួបបញ្ហាបែបនេះក៏ពិតមែន តែវាក៏មានលក្ខណៈតិចតួចបើធៀបនឹងទំហំនៃការវិនិយោគរបស់ពួកគេ តែក៏មានក្រុមមួយចំនួនតូចដែរជួបបញ្ហាដែរមានសភាពស្មុគស្មាញ និងពិបាកដោះស្រាយមិនត្រឹមតែប៉ុណ្ណោះបញ្ហារបស់ពួកគេបានហួសបន្ទាយរយៈវែង។ ជាក់ស្តែងក្រុមហ៊ុនអភិវឌ្ឍន៍ ស៊ូកាគូអ៊ិន នៅតំបន់បឹងកក់ បានកើតមានជម្លោះដីធ្លីជាមួយនឹងប្រជាពលរដ្ឋដែររស់នៅទីនោះចាប់តាំងតែពីឆ្នាំ២០០៧ រហូតដល់ ឆ្នាំ២០២០ ទើបជម្លោះទាំងអស់ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរនេះ បើតាមការប្រកាសជាសាធារណៈរបស់លោកអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញនាថ្ងៃទី១៦ មិថុនា

[30] របាយការណ៍របស់អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ, ស្តីពីការបាត់បង់បឹងទំពុន, ចេញផ្សាយខែកក្កដា ឆ្នាំ២០២០

២០២០។ មូលហេតុដែរនាំឲ្យមានភាពហួសបន្លាយបែបនេះ ដោយសារភាពមិនត្រូវរ៉ូវគ្នានៃតម្លៃសំណងរវាងអ្នកផ្តល់សំណង និងអ្នកដែរត្រូវទទួលបានសំណងខូចខាត។

**គ. ប្រជាជនរស់នៅទីតាំងដែលត្រូវអភិវឌ្ឍន៍ប៉ុន្តែគ្មានប័ណ្ណកម្មសិទ្ធិ**

គ្រប់ក្រុមហ៊ុនដែរបានបោះទុនវិនិយោគក្នុងការបង្កើតទីក្រុងរណបនៅរាជធានីភ្នំពេញ គឺធ្វើឡើងតាមរយៈសម្បទានសេដ្ឋកិច្ច ដែរស្ថិតក្រោមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល។ ដែរភាគច្រើនទីតាំងទាំងនោះជាទន្លេ និងបឹងធម្មជាតិនៅក្នុងរដ្ឋធម្មនុញ្ញនព្រះរាជាណាចក្រកម្ពុជាក៏បានចែងដែរថា "ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្ទ បាតសមុទ្ទ ក្រោមបាតសមុទ្ទ ឆ្នេរសមុទ្ទ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែរបានថាជារបស់រដ្ឋ[31]។ នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ក៏បានចែងដែរថា ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែរនាវាឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេ ដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាននិងត្រើយសមុទ្រ ត្រូវបានរាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋនិងនីតិបុគ្គសាធារណៈ[32]។ បើយោងតាមច្បាប់ទាំងពីនេះបានសបញ្ជាក់យ៉ាងច្បាស់ថា ប្រជាពលរដ្ឋដែរបានធ្លាប់តាំងទីលំនៅនៅតាមច្រាំងទន្លេឬបឹងធម្មជាតិទោះក្នុងរយៈពេលយូរក៏ពិតមែន តែការអាស្រ័យនៅរបស់ពួកគាត់ពុំមែនជាទីដែរស្របនឹងច្បាប់នោះទេ ទាំងនេះហើយដែរជាហេតុនាំឲ្យពួកគាត់ពុំអាចទទួលបាននូវប័ណ្ណកម្មសិទ្ធិទៅលើដីធ្លីទាំងនោះ។

វិវាទបែបនេះបានធ្លាប់បានកើតឡើងរួចមកហើយ គឺនូវក្នុងគម្រោងអភិវឌ្ឍន៍ទីក្រុងរណបបឹងកក់ដែរជាករណីជាក់ស្តែងបានបង្ហាញឲ្យឃើញថា ប្រជាពលរដ្ឋបាននាំគ្នាមកសាងសង់លំនៅឋានរបស់គេដោយគ្មានច្បាប់អនុញ្ញាត និងពុំមានប័ណ្ណសម្គាល់ដីកម្មសិទ្ធិនោះឡើយ ការរស់នៅកាន់យូទៅៗបែបនេះបានធ្វើអោយពួកគាត់មានការភាន់ច្រឡំថាពួកគាត់រស់នៅដោយស្របច្បាប់។ បន្ទាប់ពីមានការអភិវឌ្ឍនូវលើទីតាំងទាំងនោះ ដោយតម្រូវឲ្យប្រជាពលរដ្ឋរើចេញពីទីដែរពួកគាត់ធ្លាប់អាស្រ័យនូវ បែរជាពួកគាត់យល់ថាជាការបំពានសិទ្ធិ និងរងនូវភាពអយុត្តិធម៌ ដើម្បីជាថ្នូរនៃការរើចេញប្រជាពលរដ្ឋទាំងនោះបានទាមទារនូវសំណងខូចទៅវិញ។ ការដោះស្រាយជាមួយប្រជាជនទាក់ទិននឹងបញ្ហាដីធ្លីនេះបានក្លាយទៅជាកង្វល់របស់ក្រុមហ៊ុនអភិវឌ្ឍន៍ និងរដ្ឋាភិបាលដែរត្រូវផ្តល់សំណងជូនប្រជាជនទាំងនោះ តាមយន្តការនៃការផ្តល់សំណងទៅលើប្រជាជនមានគ្រួសារខ្លះក៏ព្រមទទួល ហើយក៏

---

[31] មាត្រា៥៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា, ឆ្នាំ១៩៩៣

[32] កថាខណ្ឌទី១ មាត្រា១៥, ច្បាប់ភូមិបាល ឆ្នាំ២០០១

មានគ្រួសារមួយចំនួនដែរនូវមិនព្រមទទួលយក ដោយលើកឡើងថាសំណងនៃការខូចខាតនូវមិនសមស្របនឹងទំហំនៃការខូចខាត។ ភាពមិនចុះសម្រុងទាំងនេះ បានធ្វើឲ្យបញ្ហាកាន់តែហូសបន្លាយឡើងរហូតដល់រាប់សិនឆ្នាំ អំឡុងពេលនៃការទាមទារប្រជាជនដែរតាំងខ្លួនជាជនរងគ្រោះបានធ្វើបាតុកម្ម និងដាក់ពាក្យបណ្ដឹងទៅតុលាការជាច្រើនបណ្ដឹងផ្សេងៗគ្នា ដើម្បីឲ្យតុលាការជួយរកយុត្តិធម៌។

## ខ. កិច្ចអន្តរាគមន៍ក្នុងការដោះស្រាយវិវាទដីធ្លីជូនប្រជាជន

ជាយន្តការ នៃការដោះស្រាយទាក់ទិននឹងបញ្ហាដីធ្លីដែលស្ថិតក្រោមការអភិវឌ្ឍទីក្រុងរណបដែរបានចោទឡើង យើងអាចសង្កេតឃើញបានថាវាមានលក្ខណៈទម្រង់តែមួយប៉ុណ្ណោះ គឺការផ្ដល់នូវសំណងជូនគ្រួសារដែរប៉ះពាល់ជាថវិការ ឬជាការរកទីតាំងសមរម្យថ្មីជូនគ្រួសារទាំងនោះជាមួយការផ្ដល់នូវប័ណ្ណកម្មសិទ្ធិស្របច្បាប់។ កន្លងមកក៏ធ្លាប់មានកិច្ចអន្តរាគមន៍របស់សាលារាជធានីភ្នំពេញ ចំពោះទំនាស់ដីធ្លីរបស់ប្រជាជនជាមួយនឹងក្រុមហ៊ុនអភិវឌ្ឍន៍ទីក្រុងរណបនៅរាជធានីភ្នំពេញរួចហើយ កាលពីឆ្នាំ២០១១ លោក កែប ជុតិមា ដែលជាអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានអនុញ្ញាតឲ្យតំណាងក្រុមអ្នកភូមិបឹងកក់ចូលជួបពិភាក្សាលើករណីជម្លោះដីបឹងកក់ក្រោយពីមានការតវ៉ានៅក្រៅរបងសាលាក្រុងជាបន្តបន្ទាប់ ដំបូងឡើយក្រុមអ្នកតវ៉ាស្នើសុំដីចំនួន១៥ហិកតាតែក៏ត្រូវបានបដិសេដចោលក្រោមហេតុផលវាហួសពីលទ្ធភាពរបស់សាលាក្រុងដែលអាចធ្វើបានជាការផ្ដល់ជម្រើសពីសំណាក់អាជ្ញាធរទៅកាន់អ្នកភូមិបឹងកក់នូវជម្រើស៣គឺ ទី១សំណង៨៥០០ដុល្លារអាមេរិក ទី២សំណងផ្ទះល្វែងនៅជាយក្រុង និងទី៣ការអភិវឌ្ឍនៅនឹងកន្លែងជាផ្ទះល្វែងដែរអាជ្ញាធរជាអ្នករៀបចំដូចនៅបុរីកីឡា។

## គ. លទ្ធផលក្រោយវិវាទដីធ្លីត្រូវបានបញ្ចប់

រាល់ទំនាស់ដីធ្លីដែរបានកើតឡើងក្រោមការអភិវឌ្ឍនៃទីក្រុងរណបនូវរាជធានីភ្នំពេញ ទោះបីជាមានបញ្ហាជាច្រើនយ៉ាងណាក្ដី និងបានចំនាយពេលវេលាជាច្រើនឆ្នាំក៏ដោយតែវាក៏បានបិទបញ្ចប់បានទាំងស្រុងបើគិតមកដល់នាពេលបច្ចុប្បន្ន។ ឆ្លងកាត់តាមការទាមទាររបស់ជនរងគ្រោះដែរមានផងប៉ះពាល់ដោយសារការអភិវឌ្ឍ ក្រុមហ៊ុនវិនិយោគមួយចំនួនធំបានផ្ដល់សំណងខូចខាតតាមរយៈការផ្ដល់ជាកញ្ចប់ថវិការ និងក្រុមហ៊ុនខ្លះបានធ្វើការដោះដូជាមួយលំនៅឋានថ្មីជូនគ្រួសារជនរងគ្រោះ ជាក់ស្ដែងដូចជាចំណាត់ការរបស់ក្រុមហ៊ុន ស៊ូកាគូអ៊ីន។ យោងទៅតាមប្រសាសន៍របស់ ឯឧត្ដម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញបានមានប្រសាសន៍ថា ទំនាស់ដីធ្លី

ដែលបានកើតឡើងជាច្រើនឆ្នាំមកនេះបានបិទបញ្ចប់ទាំងស្រុងត្រឹមឆ្នាំ២០២០ ហើយគ្រួសារដែរមានទំនាស់ក៏ត្រូវបានសាលារាជធានីភ្នំពេញរៀបចំអោយមានលំនៅឋានរួចអស់ហើយ[33]។

## ៣.២. បញ្ហាផ្សេងៗត្រូវបានចោទឡើង

គិតត្រឹមចុងឆ្នាំ២០២០នេះ គម្រោងនៃការអភិវឌ្ឍទីក្រុងរណបនៅរាជធានីភ្នំពេញមានចំនួន៨ រាល់គម្រោងនីមួយៗបានចំណាយទុនវិនិយោគរាប់រយពាន់លានដុល្លារអាមេរិក។ ជាការដែរគួរឲ្យកត់សម្គាល់ ទីក្រុងរណបដែរបានសាងសង់រួច និងកំពុងសាងសង់នាពេលបច្ចុប្បន្នបានបង្កើតឡើងជាមួយគោលដៅចម្បងមិនដូចគ្នានោះទេ ដោយទីក្រុងខ្លះមានមុខងារចម្បងរបស់គេគឺផ្តោតទៅលើសំណង់លំនៅឋានដូចជាទីក្រុងរណបប្រេក្ខនភ្នំពេញ និងទីក្រុងរណបមួយចំនួនបានដើរតួនាទីជាកន្លែងធ្វើពាណិជ្ជកម្មនិងបង្កើតការងារជូនប្រជាជនដូចជាទីក្រុងរណបកោះពេជ្រ។ ជាការពិតការអភិវឌ្ឍទៅលើវិស័យនេះបាននាំមកនូវសន្ទុះសេដ្ឋកិច្ចឲ្យកើនឡើងខ្លាំងក៏ពិតមែន តែវាបាននាំមកនូវជាមួយបញ្ហាមកជាមួយផងដែរ។

### ៣.២.១. ភត្តាភូមិសាស្ត្រ

ទីក្រុងរណបនៅរាជធានីភ្នំពេញ ត្រូវបានការអនុញ្ញាជាមុនដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែរជាចក្ខុវិស័យរបស់រដ្ឋាភិបាលបានសម្លឹងឃើញថាការអភិវឌ្ឍទីក្រុងរណបនឹងជួយសម្រួលបន្ទុកដល់ទីក្រុងចាស់។ ជាការដែរគួរឲ្យចាប់អារម្មណ៍ ទីតាំងដែរធ្វើការអភិវឌ្ឍឲ្យក្លាយទៅជាទីក្រុងរណបហាក់មិនសូវជាសមស្របនឹងគោលបំណងរបស់រាជរដ្ឋាភិបាលនោះទេ ពោលគឺទីក្រុងថ្មីៗដែរបានបង្កើតឡើងនេះមានគម្រោងខ្លះបានធ្វើនៅកៀកនឹងកណ្តាយរាជធានីភ្នំពេញ និងមានទីក្រុងរណបខ្លះទៀតបែរជាសាងសង់នៅចំកណ្តាលរាជធានីភ្នំពេញ(បឹងកក់)ទៅវិញ ហើយមួយចំនួនធំទៀតដែរទើបទទួលបានសិទ្ធិក្នុងការអភិវឌ្ឍបានសាងសង់ឡើងដោយការទន្ទ្រានចូបឹងឬទន្លេ ដែរវាបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន ហើយទីក្រុងដែរសាងសង់ឡើងដោយការលុបបឹងនោះមានដូចជា៖ ទីក្រុងរណបអ៊ឹងស៊ីធីដែរបានលុបចូរបឹងទំពុន ឬបឹងជើងឯក ទីក្រុងរណបអភិវឌ្ឍន៍បឹងកក់ដែរបានលុបចូរបឹងកក់ និងទីក្រុងរណបកាំកូស៊ីធីដែរបានលុបចូរបឹងពោងពាយ។ ក្រៅពីការលុបចូរបឹងមានគម្រោងមួយចំនួនបានចាក់ដីចូលទន្លេដើម្បីយកដីមកធ្វើជាទីក្រុងរណបក្នុងនោះរួមមាន៖ ទីក្រុងរណបកោះពេជ្រស៊ីធី និងទីក្រុងរណបកោះនរាដែរទីក្រុងទាំងពីនេះបានចាក់ដីចូលទន្លេមួយផ្នែកដើម្បីយកដីមកសាងសង់ឲ្យទៅជាទីក្រុងរណប។

[៣៣] ប្រសាសន៍ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ, ថ្លែងក្នុងវិទិការបូកសរុបការងារជូនរដ្ឋាភិបាល, ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០២០

### ៣.២.២. ប្រជាជនក្នុងតំបន់អភិវឌ្ឍន៍

ប្រជាជនជាច្រើនដែររស់នៅតំបន់អភិវឌ្ឍន៍ទីក្រុងរណប ហាក់មិនអាចសម្របខ្លួនបានជាមួយសន្ទុះនៃការអភិវឌ្ឍយ៉ាងឆាប់រហ័សបែបនេះ ប្រជាជនភាគច្រើនដែរជីវភាពរបស់ពួកគាត់នៅមានកម្រិតជាមួយចំណូលដែរនៅទាបនៅឡើយ។ ទីក្រុងរណបបានបង្កើតឡើងជាមួយនឹងភាពទំនើប ដែរទាមទារឲ្យការចំណាយនៅក្នុងទីក្រុងនោះក៏ត្រូវមានការចំណាយខ្ពស់ជាមួយគ្នាដែរ ការចំណាយខ្ពស់បែបនេះវាក៏មិនសមស្របជាមួយចំណូលប្រជាជនដែររស់នៅទីនោះទេ ទីក្រុងមួយដែរពោលពេញដោយសក្កដានុពលនិងភាពជឿនលឿនហើយវាក៏មិនមែនជារឿងចម្លែកនោះទេដែរធ្វើឲ្យតម្លៃក្នុងតំបន់ទីនោះមានការកើនឡើងខ្លាំង តែការកើនឡើងបែបនេះអាចថាជាចំណុវិជ្ជមានចំពោះប្រជាជនដែរមានដីស្រាប់ផ្ទុយទៅវិញវាបែរជាជះផលប៉ះពាល់យ៉ាងខ្លាំងចំពោះអ្នកដែរមិនទាន់មានដីកាន់កាប់ស្របច្បាប់ស្របជាមួយជីវភាពនៅមានកម្រិតទៀតនឹងធ្វើឲ្យពួកគាត់ពុំមានលទ្ធភាពក្នុងការរកទិញដើម្បីធ្វើជាម្ចាស់កម្មសិទ្ធិ ដែរវាបានលើសពីសមត្ថភាពរបស់ពួកគេ។

## ៣.៣. គុណភាពនៃសំណង់នានាក្នុងទីក្រុងរណប

### ៣.៣.១. ការត្រួតពិនិត្យ និងការផ្តល់សិទ្ធិសាងសង់ទៅម្ចាស់គម្រោងដោយមន្ត្រីមានសមត្ថកិច្ច

យោងតាមមាត្រា៥ នៃច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩ បានចែងថា រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់។ រដ្ឋមន្ត្រីក្រសួងដែនដី នគរូនបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ដើម្បីបញ្ចៀសគ្រោះថ្នាក់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យ តាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ហើយកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។

### ៣.៣.២. ការទទួលខុសត្រូវលើគុណភាពសំណង់ដែលបានសាងសង់រួច

ដូចដែលយើងទាំងអស់គ្នាបានដឹងរួចហើយថា វិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន រីកលូតលាស់ និងអភិឌ្ឍន៍ខ្លាំងមែនទែន។ ហើយព្រះរាជាណាចក្រកម្ពុជាយើងក៏មិនមែនថាមិនទាន់មានច្បាប់សំណង់នោះទេ វត្តមាននៃច្បាប់សំណង់របស់យើងគឺមានមកយូណាស់មកហើយ ដែរពីមុនគេហៅថាច្បាប់ស្តីពីការរៀបចំទឹកដី

នគរូបនីយកម្ម និងសំណង់ក្នុងឆ្នាំ១៩៩៤។ ប៉ុន្តែកន្លងមកនេះក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ ក៏មានការបង្កើតឡើងនូវច្បាប់ថ្មីនោះគឺ ច្បាប់ស្តីពីសំណង់ មែនទែនទៅច្បាប់មួយនេះបានដើរតួនាទីយ៉ាងសំខាន់សម្រាប់គ្រប់គ្រងរាល់វិស័យសំណង់ទាំងអស់ដែរមាននៅកម្ពុជា កន្លងមកសំណង់នូវកម្ពុជាដែរបានសាងសង់រួចភាពច្រើនពុំគោរពតាមបទដ្ឋានត្រឹមត្រូវដែរធ្វើឲ្យគុណភាពនៃសំណង់ក៏ពុំសូវជាមានគុណល្អនោះឡើយ។

**ក. សំណង់អគារសាងសង់រួចតែគ្មានគុណភាព**

សំណង់នានាដែរបានសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍ទីក្រុងរណបនូវភ្នំពេញនាពេលបច្ចុប្បន្ន ត្រូវបានសាងសង់ឡើងក្នុងទឹកដីដែរមានលក្ខណៈទន់ជ្រាយនូវឡើង ព្រោះគម្រោងទាំងនោះតែងតែអភិវឌ្ឍន៍ទៅលើដីដែរទើបធ្វើការចាក់បំពេញថ្មីដូចជាការចាក់លុបបឹង និងទន្លេជាដើមក្នុងនោះមានដូចជាគម្រោងបឹងកក់ គម្រោងអ៊ឹងហួលឌីងកោះពេជ្រ និងកោះនរា។ ក្រៅពីការលុបបឹង និងទន្លេគម្រោងនៃការអភិវឌ្ឍបានចាក់ដីដែរមានសភាពទន់ជ្រាយខ្លាំងហើយសម្បូរដោយល្បាប់ភក់ ដែរវាមិនមានអំណោយផលចំពោះការសាងសង់សំណង់អគារនោះទេ កត្តាដូចដែរបានលើកឡើងខាងលើនេះជាមូលហេតុមួយ ក្នុងនោះការមិនយកចិត្តទុកដាក់សាងសង់សំណង់អគារដែរស្របតាមបច្ចេកទេសក៏ជាមូលហេតុសំខាន់។ ក្នុងករណីដែរបណ្តោយឲ្យការសាងសង់ចេះតែមានបែបនេះ វានឹងចោទជាបញ្ហាធំសម្រាប់កែលម្អឡើងវិញ ហើយរឹងរឹតតែពិបាកក្នុងការរកអ្នកដែរត្រូវទទួលខុសត្រូវចំពោះសំណង់ដែរបានសាងសង់រួចទាំងនោះ។

**ខ. អ្នកដែរត្រូវចូររួមទទួលខុសត្រូវចំពោះសំណង់ទាំងនោះ**

ការទទួលខុសត្រូវចំពោះសំណង់ដែរសាងសង់រួចនូវទីនេះត្រូវបានសង្កត់ធ្ងន់ទៅលើសំណង់ដែរកំពុងសាងសង់ និងបានសាងសង់រួចតែមានបញ្ហាមិនប្រក្រតីត្រង់ចំណុចណាមួយ ហើយភាគីពាក់ព័ន្ធដែរត្រូវចូររួមក្នុងការទទួលខុសត្រូវមានទាំងម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ អ្នកសិក្សាប្លង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងអ្នកម៉ៅការសាងសង់ផងដែរ។ មុនទទួលបានការសាងសង់ឬរុះរើ អ្នកម៉ៅការសាងសង់ឬរុះរើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ ដើម្បីផ្តល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារ និងតតិយជន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបានធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឲ្យបើកការដ្ឋាន[34]។ ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ ឬ

[៣៤] មាត្រា៧២ នៃច្បាប់ស្តីពីសំណង់, ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

រុះរើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានគឺជាបន្ទុករបស់អ្នកម៉ៅការសាងសង់ឬរុះរើនោះ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្តប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ឬរុះរើបន្តទាំងនោះ។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើជាមួយអ្នកម៉ៅការសាងសង់ឬរុះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ឬរុះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ឬរុះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។ ក្នុងករណីប្រតិបត្តិការការងារសាងសង់ឬរុះរើរបស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ អ្នកអភិវឌ្ឍន៍អចលនវត្ថុត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។ ចំពោះទំហំសំណង់ដែលត្រូវធានារ៉ាប់រងចំពោះការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ ស្តីពីច្បាប់សំណង់។ រីឯអ្នកដែលត្រូវទទួលខុសត្រូវមានដូចតទៅ៖

- អ្នកសិក្សាគម្រោងប្លង់ត្រូវបានទទួលខុសត្រូវការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃប្រសិនបើគម្រោងប្លង់នៃសំណង់នោះមានវិការៈលើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងរបស់ខ្លួនបានអនុលោមតាមបទបញ្ញត្តិតម្រូវជាធរមាន។
- នៅក្នុងពេលអនុវត្តការងារសាងសង់ឬរុះរើ ម្ចាស់សំណង់និងអ្នកសាងសង់ឬរុះរើត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការងារសាងសង់ឬរុះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ។
- អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃដោយសារវិការៈនៃការងារត្រួតពិនិត្យនិងការបញ្ជាក់របស់ខ្លួន។
- ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១. រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលជនរងគ្រោះឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារ ឬ

២. រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូចខាតបានកើតឡើង។

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូតខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោម៖

១. នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ឬចែកចាយចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឲ្យមានការខូតខាត។

២. សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទបញ្ញត្តិបច្ចេកទេស។

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១. រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងខូចខាត ឬ

២. រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឲ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។

# សេចក្តីសន្និដ្ឋាន

ជាសេចក្តីសន្និដ្ឋាន ការរៀបចំ និងបង្កើតទីក្រុងរណបនូវរាជធានីភ្នំពេញគឺជាបញ្ហាដែលពាក់ព័ន្ធជាមួយការរៀបចំ និងការថែរក្សាទីក្រុងចាស់ នូវរូបរាងនិងមុខងារ របស់តំបន់ជាយក្រុង ទីប្រជុំជនដែលមានស្រាប់ ឬមិនទាន់មាន ឲ្យមានសោភណភាព សណ្តាប់ធ្នាប់ ព្រោះការរៀបចំអោយមានទីក្រុងរណបវាប្រាកដជាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅកាន់ទីក្រុងចាស់ជាក់ជាមិនខាន។ ផងដែរនោះ វាក៏ជាអភិក្រមនិងលទ្ធផលនៃការបង្កើតឲ្យមាននូវមូលដ្ឋានមួយដែរមានមនុស្សអាចរួមរស់ជាមួយគ្នាប្រាស្រ័យទាក់ទងជាមួយគ្នាដោយងាយនូវក្នុងតំបន់នោះផងដែរ។ ការរៀបចំបង្កើតទីក្រុងរណប ដែលប្រកបដោយប្រសិទ្ធិភាពជាមួយសោភណភាពនិងសណ្តាប់ធ្នាប់នេះ ទាមទារឲ្យមានការចូលរួមពីវិស័យពាក់ព័ន្ធជាច្រើន តួរយ៉ាងមានដូចជា៖ ការធ្វើផែនការ ការអភិវឌ្ឍស្ថាបត្យកម្ម វិស្វកម្មលើទេសភាពច្បាប់ និងពិសេសលើហិរញ្ញវត្ថុជាដើម។ ស្ថិតក្នុងន័យនេះ ការរៀបចំក្រុងបានធ្វើប្រតិបត្តិការពីខ្នាតម៉ាក្រូ នៃរចនាសម្ព័ន្ធ តាមទីក្រុង (ការធ្វើផែនការ ការកំណត់តំបន់ ការកំណត់ការដឹកជញ្ជូន និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធ តភ្ជាប់) រហូតដល់ទ្រង់ទ្រាយខ្នាតតូច ដល់គ្រឿងបំពាក់តាមចិញ្ចើមផ្លូវ និងបំភ្លឺភ្លើង។ នៅពេលដែរមានការរួមបញ្ចូលគ្នាយ៉ាងពេញលេញរវាងប្រព័ន្ធគោលនយោបាយដែលបានដាក់ចេញ និងការធ្វើផែនការដែលបានគ្រោង, ការរៀបចំក្រុងនឹងអាចផ្តល់ពត៌មានជាមូលដ្ឋាននៃការប្រើប្រាស់ដីធ្លី ការធ្វើផែនការអភិវឌ្ឍន៍, ពត៌មានទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ និងសំណុំបែបបទផ្សេងៗ និងសូម្បីតែការលាយផ្សំនៃសង្គម ប្រជាសាស្ត្រ នៃកន្លែងមួយក៏អាចឲ្យយើងដឹងផងដែរ។ ទោះជាយ៉ាងនេះក្តី ការរៀបចំក្រុង និងការបង្កើតឲ្យមានការបង្កើតទីក្រុងរណបពុំមែនជាគម្រោងនៃដំណើរការមួយដែលមានរយៈពេលខ្លីនោះទេបផ្ទុយទៅវិញជាអភិក្រមការងារ មួយដែលទាមទារឲ្យមានការយកចិត្តទុកដាក់គ្រប់ពេលវេលា និងជាបន្តបន្ទាប់ឥតដាច់ដើម្បីធានាថាការរៀបចំក្រុងនេះ ត្រូវបានធ្វើឡើងចំគោលដៅដែលមនុស្សគ្រប់គ្នាក្នុងសង្គមចង់បាន និងទាន់ពេលវេលាយ៉ាងមានប្រសិទ្ធិភាពបានពិតប្រាកដ។

# វាយតម្លៃនិងអនុសាសន៍

ឆ្លងកាត់តាមការសិក្សា និងពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃប្រធានបទខាងលើរួចមក យើងខ្ញុំយល់ឃើញថា ការបង្កើតឲ្យមានការបង្កើតឲ្យមានទីក្រុងរណបនៅរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន ជាអនុសាសន៍គប្បីលើកយកមកគិតគូពិចារណាគឺ ការបង្កើតនិងការដាក់ឲ្យប្រើប្រាស់នូវទីក្រុងរណប និងដំណើរការនគរូបនីយកម្មឲ្យក្លាយជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ ប្រកបដោយប្រសិទ្ធិភាពស្របតាមបរិបថនៃសង្គមពិតប្រាកដត្រូវធ្វើតាមរយៈ៖

**ក. ការបង្កើតឡើងនៃគោលនយោបាយទីក្រុងជាតិ**

វិធីសាស្ត្រសម្របសម្រួលដែលឈានដល់ការធ្វើឲ្យមានកំណើន នគរូបនីយកម្មត្រូវបានកំណត់ឡើងទៅតាមកម្រិតថ្នាក់ជាតិ ក្នុងគោលបំណងដើម្បីសម្របសម្រួលតំបន់ផ្សេងៗគ្នារបស់រដ្ឋាភិបាល ទៅលើបញ្ហាផ្លូវថ្នល់ប្រព័ន្ធគមនាគមន៍ ការអភិវឌ្ឍសេដ្ឋកិច្ច និងយុទ្ធសាស្ត្រទាក់ទងទៅនឹងអគ្គីសនី។ ចក្ខុវិស័យជាយុទ្ធសាស្ត្ររបស់ទីក្រុងជាតិ គឺត្រូវបានធ្វើឡើងជាមួយនឹងការសង្កត់ធ្ងន់ជាពិសេសទៅលើ ទំហំនគរូបនីយកម្មតូច និងមធ្យម។ ការកើនឡើងនៃនគរូបនីយកម្ម គួរតែផ្តល់អទិភាពចំពោះការដឹកជញ្ជូនបែបធម្មតា និងការដឹកជញ្ជូនតាមផ្លូវរបៀងជាលក្ខណៈថាមពល ដើម្បីបង្រួមនៃចំងាយយ៉ាងលាតសន្ធឹង និងការបង្កើននូវស្ថេរភាព។

**ខ. ត្រលប់ទៅរៀបចំផែនការមូលដ្ឋាននៅក្នុងទីក្រុង៖ ទីកន្លែងសាធារណៈ គឺជាអាទិភាពចម្បង ( លើស៣០%នៃផ្ទៃដី )**

- រៀបចំផែនការទុកជាមុន (៣០ឆ្នាំ)
- រៀបចំផែនការពិនិត្យទៅលើមាត្រដ្ឋានឬទំហំ (ចំនួនប៉ុន្មានដែលធ្វើឲ្យមាមភាពខុសគ្នា)
- ត្រូវរៀបចំផែនការបន្តបន្ទាប់ (ការវិនិយោគសេវាសាធារណៈ)
- ត្រូវរៀបចំផែនការដើម្បីសមាហរណកម្មសង្គម (គោលនយោបាយការពារជនក្រីក្រ)
- ត្រូវពិនិត្យរៀបចំផែនការដង់ស៊ីតេ (ពិនិត្យទៅលើការកើនឡើងដង់ស៊ីតេ)
- ត្រូវរៀបចំផែនការលើបណ្តាញតភ្ជាប់ (ដោយផ្អែកទៅតាមតំបន់ ឬវិស័យ)
- ត្រូវរៀបចំផែនការសម្រាប់ប្រសិទ្ធិភាពថាមពល និងការការពារហានិភ័យ។

**គ. ដង់ស៊ីតេកើនឡើងនិងការកាត់បន្ថយការកកស្ទះ គឺត្រូវបំពេញចន្លោះដែលខ្វះខាតនៅទីក្រុងនិងរៀបចំផែនការពង្រីកទីក្រុង សេវាមូលដ្ឋានមានដូចជា ប្រព័ន្ធទឹក និងអនាម័យជាដើម**

ត្រូវមានការរៀបចំក្រុងជាមុនពីព្រោះ នៅពេលខាងមុខយើងដឹងច្បាស់ថានឹងមានកំណើនប្រជាជនមានការកើនឡើង ហើយនៅពេលមានប្រជាជនកើនឡើងតំបន់ដែលយើងបានរៀបចំផែនការនោះចាំបាច់វានឹងបំពេញចន្លោះទៅដោយប្រជាជន។ ដង់ស៊ីតេដែលល្អ និងមានលក្ខណៈត្រឹមត្រូវនោះគឺ តម្រូវឲ្យមាន (១២,៥០០នាក់/គីឡូម៉ែត្រការ៉េ) ហើយបើគ្មានការរចនាដោយល្អទេ ឬការរៀបចំអោយល្អនោះទេ ដង់ស៊ីតេប្រជាជននឹងក្លាយទៅជាបញ្ហាស្មុគស្មាញ និងការកកស្ទះ។ ការពង្រីកទីក្រុងគួរតែត្រូវបានរៀបចំគម្រោងផែនការជាមុន នៅពេលណាដែលគ្មានសមត្ថភាពក្នុងការបំពេញនូវចន្លោះខ្វះខាត ឬក៏រៀបចំដង់ស៊ីតេឲ្យបានត្រឹមត្រូវនោះទេវានឹងធ្វើឲ្យប៉ះពាល់ដល់ស្នូលទាំងមូលនៃទីក្រុង និងសេវាមូលដ្ឋាន ស្របជាមួយគ្នានោះការរៀបចំផែនការសម្រាប់បញ្ចូលការប្រើប្រាស់កន្លែងទំនេរនៅក្នុងទីក្រុង និងធ្វើការទទួលខុសត្រូវចំពោះការប្រើប្រាស់របស់សង្គមដែលសម្បូរបែប។ ការពង្រីកទីក្រុងគួរតែត្រូវរៀបចំផែនការនៅក្នុងទំហំឲ្យបានត្រឹមត្រូវ និងនៅក្នុងចក្ខុវិស័យវែងឆ្ងាយ ដើម្បីជៀសវាងនូវភាពផ្តាច់មុខរបស់អ្នកវិនិយោគទុន និងការប្រែប្រួលនូវតម្លៃដីនៅក្នុងទីក្រុងដែលមិនសមហេតុផល អ្វីដែរគួរយកចិត្តទុកដាក់ជាពិសេស គឺគួរតែបានផ្តល់ឲ្យនូវយុទ្ធសាស្ត្រទាំងនោះដោយផ្អែកទៅលើប្រព័ន្ធនៃតំបន់ទីក្រុងធំៗ ទីក្រុងធម្មតា និងតំបន់ទីផ្សារក្នុងទីក្រុង៕

## ឯកសារយោង

### ១. ឯកសារជាភាសាខ្មែរ


- រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពី សំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
- ច្បាប់ ភូមិបាល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១
- វិសោធនកម្មច្បាប់ស្តីពីការវិនិយោគ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- អនុក្រឹត្យលេខ១៨១ អនក្រ.បក ស្តីពី ការដាក់ឲ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នា២០១៥
- អនុក្រឹត្យលេខ៤២/អនក្រ.បក ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥
- សេចក្តីសម្រេចលេខ០៤១ សសរ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នា២០១៤
- សៀវភៅជំរឿនទូទៅនៃប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩
- របាយការណ៍របស់អង្គការសម្ព័ន្ធខ្មែរជំរឿនសិទ្ធិមនុស្សលីការដូ ស្តីពីការបាត់បង់បឹងទំពុន ចេញផ្សាយខែកក្កដា ឆ្នាំ២០២០
- ទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩
- សៀវភៅស្តីពី ថវិការសង្ខេបឆ្នាំ២០១៩ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សៀវភៅនីតិនគរូបនីយវិទ្យា របស់លោកបណ្ឌិត អ៊ុនសក្កដា ឆ្នាំសិក្សា២០១៩-២០២០
- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត
- ប្រសាសន៍ឯឧត្តម ជា សុផារ៉ា ក្នុងវេទិការសាធារណៈឯកជនលើកទី១ ស្តីពីការអភិវឌ្ឍនគរូបនីយកម្មកម្ពុជា-ជប៉ុន ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩
- ប្រសាសន៍សម្តេចតេជោ ហ៊ុន សែន ក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានបេតុងពីផ្លូវជាតិលេខ១ ទៅកាន់តំបន់អភិវឌ្ឍន៍កោះនរា និងស្ពានបេតុងខ្សែកាបពីតំបន់អភិវឌ្ឍន៍កោះនរាទៅកាន់ទីក្រុងកោះពេជ្រ
- ប្រសាសន៍ឯកឧត្តម ឃួង ស្រេង ថ្លែងក្នុងវេទិការបូកសរុបការងារជូនរដ្ឋាភិបាលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

## ២. ឯកសារបរទេស


- WORLD HISTORY ENCYCLOPEDIA
- Joshua J. Mark, World history encyclopedia
- UN POPULATION DIVISON ISSUES `WORLD POPULATION PROSPECTS: THE 2000 REVISION
- Sajor, 2001
- Brookfield and Bryon, 1993
- Habitat, 1996

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងធានា៖

- គុណភាព ប្រសិទ្ធភាព ចីរភាព និងសមធម៌នៃនគរូបនីយកម្ម
- ការការពារសិទ្ធិនិងផលប្រយោជន៍សាធារណៈនិងឯកជន ក្នុងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់
- ការលើកកម្ពស់តម្លៃវប្បធម៌ ការអភិវឌ្ឍបៃតង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល ព្រមទាំងបង្កើនការបង្ការនិងការទប់ស្កាត់គ្រោះមហន្តរាយ
- ការយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួល សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរា និងកុមារ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន នៅព្រះរាជាណាចក្រកម្ពុជា ឲ្យមាន៖

- មុខងារសមស្របសម្រាប់ការស្នាក់នៅ ការផ្តល់ការងារ ការសិក្សា កន្លែងលំហែកម្សាន្ត និងការធ្វើចរាចរណ៍ ប្រកបដោយសុខភាព សោភណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ និងភាពងាយស្រួល
- ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កិច្ចការពារបរិស្ថាន ការពារជាតិ សន្តិសុខសៀង និងការថែរក្សា សម្បត្តិវប្បធម៌
- ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈរាជធានី ក្រុង និងទីប្រជុំជន
- តុល្យភាពនៃការអភិវឌ្ឍនិងការអភិរក្ស ព្រមទាំងទំនាក់ទំនងរវាងទីក្រុងនិងជនបទ ដោយផ្អែកលើធាតុភូមិសាស្ត្រនិងលក្ខណៈពិសេសនៃតំបន់នីមួយៗ
- ការតម្រង់ទិសច្បាស់លាស់ដែលអាចដឹងមុនបាននូវការអភិវឌ្ឍនៅរាជធានី ក្រុង និងទីប្រជុំជន។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ ព្រមទាំងដីរបស់បុគ្គលឯកជនក្នុងរាជធានី ក្រុង និងទីប្រជុំជន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់អភិរក្សពិសេសដែលមានចែងដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា៤ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានពន្យល់ក្នុងសទ្ទានុក្រមភ្ជាប់ជាឧសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២
## គោលការណ៍

**មាត្រា៥ .-**

កិច្ចការនគរូបនីយកម្មត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ
- គោរពតាមឋានានុក្រមនិងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តទីក្រុងជាមូលដ្ឋានបង្អែក សម្រាប់ការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់គ្រប់ប្រភេទ ព្រមទាំងការធ្វើសមាហរណកម្ម ដើម្បីធ្វើឲ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានតុល្យភាព និងមានសមធម៌។

## ជំពូកទី៣
## យន្តការ សមត្ថកិច្ច និងភារកិច្ច

**មាត្រា៦ .-**

យន្តការសម្រាប់ធ្វើផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានដូចតទៅ៖

១- នៅថ្នាក់ជាតិ មានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដែលត្រូវផ្ដួចផ្ដើមរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិនិងនៅតាមតំបន់។

២- នៅថ្នាក់ក្រោមជាតិ រួមមាន៖

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ដែលត្រូវផ្ដួចផ្ដើមរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ដែលត្រូវផ្ដួចផ្ដើមរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ដែលត្រូវផ្ដួចផ្ដើមរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ស្រុក ដែលត្រូវផ្ដួចផ្ដើមរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខណ្ឌ ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវផ្តួចផ្តើមរៀបចំផែនការប្រើប្រាស់ដីឃុំ សង្កាត់។

យន្តការនៅថ្នាក់ក្រោមជាតិដែលបានរៀបរាប់ខាងលើត្រូវធ្វើការសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការរៀបចំផែនការរូបវន្តទីក្រុង។

**មាត្រា៧ .-**

យន្តការ សមត្ថកិច្ច និងភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិបានកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិនិងព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា៨ .-**

យន្តការ សមត្ថកិច្ច និងភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ដោយអនុក្រឹត្យលេខ៧៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩ .-**

យន្តការ សមត្ថកិច្ច ភារកិច្ច និងនីតិវិធី សម្រាប់រៀបចំផែនការប្រើប្រាស់ដី ឃុំ សង្កាត់ បានកំណត់ដោយអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

## ជំពូកទី៤
## ផែនការរូបវន្តនិងនីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង
### ផ្នែកទី១
### ផែនការរូបវន្តទីក្រុង

**មាត្រា១០ .-**

ផែនការរូបវន្តទីក្រុងរួមមាន៖

១- ប្លង់គោលប្រើប្រាស់ដី
២- ផែនការប្រើប្រាស់ដី
៣- ប្លង់លម្អិតនគរូបនីយកម្ម។

**មាត្រា១១ .-**

ប្លង់គោលប្រើប្រាស់ដីត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : ត្រូវប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គមកិច្ច ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ។
២- ការកំណត់ចក្ខុវិស័យ : ត្រូវសិក្សានិងកំណត់ចក្ខុវិស័យអភិវឌ្ឍនិងអភិរក្ស សម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំចំពោះថ្នាក់ក្រុង ស្រុក ខណ្ឌ និងយ៉ាងតិច២០(ម្ភៃ)ឆ្នាំចំពោះថ្នាក់រាជធានី។

៣- ការកំណត់យុទ្ធសាស្ត្រៈ ត្រូវសិក្សានិងកំណត់យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្ស ដើម្បីសម្រេចបាននូវចក្ខុវិស័យមានៈ

- យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សទីក្រុង
- យុទ្ធសាស្ត្រប្រើប្រាស់ដី
- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច
- យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច
- យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងកាកសំណល់
- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ។

៤- គំនូសប្លង់សម្រាប់ប្លង់គោលប្រើប្រាស់ដីមានដូចជាៈ

៤.១- ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

- ប្លង់បង្ហាញទីតាំង
- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់និន្នាការនៃការពង្រីកនៃទីក្រុង
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ។

៤.២- ប្លង់អនាគតកាល ស្របតាមចក្ខុវិស័យ មានដូចជាៈ

- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់បែងចែកប្រភេទប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់គម្រោងពង្រីកទីក្រុង
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ។

៥- សេចក្តីណែនាំអនុវត្តនិងគ្រប់គ្រងការអភិវឌ្ឍ : ត្រូវរៀបចំបញ្ជីគម្រោងនិងផែនការសកម្មភាពតាមលំដាប់អាទិភាព សម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងសេចក្តីណែនាំសម្រាប់ការអនុវត្តនិងការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់។

៦- ឯកសារឧបសម្ព័ន្ធ។

៧- ឯកសារទាំងអស់ ត្រូវចងក្រងជារបាយការណ៍បច្ចេកទេស។

ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុង ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

ប្លង់គោលប្រើប្រាស់ដីរាជធានី ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយអនុក្រឹត្យ។

ប្លង់គោលប្រើប្រាស់ដីក្រុងនិងទីប្រជុំជន ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១២ .-**

ផែនការប្រើប្រាស់ដីត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : មានជាអាទិ៍ទិន្នន័យរូបវន្ត នគរូបនីយកម្ម ការប្រើប្រាស់ដី សំណង់លំនៅឋាន សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ធនធានធម្មជាតិ ផែនទី និងរូបភាព។

២- ការកំណត់យុទ្ធសាស្ត្រ : ត្រូវកំណត់យុទ្ធសាស្ត្រឲ្យស្របតាមប្លង់គោល។

៣- គំនូសប្លង់ក្នុងផែនការប្រើប្រាស់ដីមានដូចជា៖

៣.១- ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

- ប្លង់បង្ហាញទីតាំង
- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
- ប្លង់កំណត់តំបន់ប្រើប្រាស់ដី
- ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ឆ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់។

៣.២- ប្លង់អនាគតកាលមានដូចជា៖

- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់បែងចែកតំបន់ប្រើប្រាស់ដី
- ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់បង្ហាញពីទិសដៅប្រើប្រាស់ដី
- ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ឆ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់។

៤- បទបញ្ជាប្រើប្រាស់ដី ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់គ្រប់ប្រភេទ។

៥- ឯកសារនិងឧបសម្ព័ន្ធ។

ផែនការប្រើប្រាស់ដីរាជធានី ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយអនុក្រឹត្យ។

ផែនការប្រើប្រាស់ដីក្រុង ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៣ .-**

ប្លង់លម្អិតនគរូបនីយកម្មមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : ផ្អែកតាមទិន្នន័យប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។

២- គំនូសប្លង់លម្អិតនគរូបនីយកម្មមានដូចជា៖

- ប្លង់បង្ហាញពីទីតាំង
- ប្លង់សរុប ដោយមានកំណត់ព្រំប្រទល់
- ប្លង់លម្អិតការប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ផ្លាគម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់
- ប្លង់គំហើញសំណង់និងរចនាសម្ព័ន្ធ
- ប្លង់នេត្រាទស្សន៍ឬគំរូសំណាក។

ប្លង់លម្អិតនគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

## ផ្នែកទី២
## នីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង

**មាត្រា១៤ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៦០(ហុកសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ និង ផ្តល់យោបល់ ដើម្បីធ្វើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិពិនិត្យនិង ផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល ៣០(សាបសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃ ធ្វើការ ស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើ សំណើសុំការសម្រេចចុងក្រោយពីរាជរដ្ឋាភិបាល ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើ ការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប) ថ្ងៃ

ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេល ស្របតាមទំហំការងារជាក់ស្តែងដែលត្រូវបាន កំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៥ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុងនិងប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ព្រមទាំងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៦ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្ត ដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការនិងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត ពិនិត្យ និងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយ

រយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះអាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន ត្រូវសម្រេចដាក់ឲ្យប្រើប្រាស់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៧ .-**

ការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវស្ថានភាពវិវត្តរបស់ទីក្រុង ដើម្បីងាយស្រួលក្នុងការរៀបចំជាសេចក្តីព្រាងសំណើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី សម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈដូចដំណើរការធ្វើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីនៅទីក្រុងដែរ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅទីក្រុងមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។ ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីដែលបានកែសម្រួលរួច ត្រូវស្នើសុំការសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការតាមនីតិវិធីដូចការសម្រេចប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីដែរ។

ក្នុងករណីដែលទីប្រជុំជនមានទីតាំងស្ថិតនៅលើតំបន់ប្រសព្វរវាងរដ្ឋបាលថ្នាក់ក្រោមជាតិពីរឬច្រើន រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះត្រូវសហការគ្នារៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅតំបន់នោះ។

**មាត្រា១៨ .-**

សេចក្តីណែនាំបច្ចេកទេសនិងនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង និងប្លង់លម្អិតនគរូបនីយកម្ម ព្រមទាំងវិធីដោះស្រាយការតវ៉ាផ្សេងៗ ត្រូវកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## ជំពូកទី៥
## បទប្បញ្ញត្តិនៃការប្រើប្រាស់ដី

**មាត្រា១៩ .-**

ប្រព័ន្ធផែនការប្រើប្រាស់ដីនៅទីក្រុងនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជា២ប្រភេទ រួមមាន៖

១- ប្រភេទដីអាចសាងសង់បាន

២- ប្រភេទដីកម្រិតការសាងសង់។

## ផ្នែកទី១
## អំពីប្រភេទដីអាចសាងសង់បាន

**មាត្រា២០ .-**

ប្រភេទដីអាចសាងសង់បាន ត្រូវបានបែងចែកជាតំបន់ ដូចខាងក្រោម៖

១- តំបន់លំនៅឋាន រួមមាន៥(ប្រាំ)ប្រភេទ៖

- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប(ផ្ទះ ភូមិគ្រឹះ ឬពាក់កណ្តាលភូមិគ្រឹះ)
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប(ផ្ទះល្វែងឬផ្ទះជាប់គ្នា)
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យម
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់
- តំបន់លំនៅឋានចម្រុះ។

២- តំបន់ពាណិជ្ជកម្ម រួមមាន២(ពីរ)ប្រភេទ៖

- តំបន់ពាណិជ្ជកម្ម
- តំបន់ពាណិជ្ជកម្មចម្រុះ។

៣- តំបន់ឧស្សាហកម្ម រួមមាន៣(បី)ប្រភេទ៖

- តំបន់ឧស្សាហកម្ម
- តំបន់ឧស្សាហកម្មស្រាល
- តំបន់ឧស្សាហកម្មចម្រុះ។

៤- តំបន់ចម្រុះ

៥- តំបន់ដឹកជញ្ជូន

៦- តំបន់ទេសចរណ៍

៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ

៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង

៩- តំបន់វប្បធម៌និងសាសនា

១០- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

ការបែងចែកតំបន់ក្នុងប្រភេទដីអាចសាងសង់បាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២១ .-**

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយសម្រាប់ប្រភេទដីអាចសាងសង់បាននៅទីក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

១- តំបន់លំនៅឋាន៖

- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប មិនឲ្យលើសពី៧៥%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋាន ដែលមានកម្ពស់មធ្យម មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋាន ដែលមានកម្ពស់ខ្ពស់ មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋានចម្រុះ មិនឲ្យលើសពី៦៥%នៃផ្ទៃដីឡូត៍

| | |
|---|---|
| ២- តំបន់ពាណិជ្ជកម្ម៖ | |
| - តំបន់ពាណិជ្ជកម្ម | មិនឲ្យលើសពី៧៥%នៃផ្ទៃដីឡូត៍ |
| - តំបន់ពាណិជ្ជកម្មចម្រុះ | មិនឲ្យលើសពី៧០%នៃផ្ទៃដីឡូត៍។ |
| ៣- តំបន់ឧស្សាហកម្ម៖ | |
| - តំបន់ឧស្សាហកម្ម | មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍ |
| - តំបន់ឧស្សាហកម្មស្រាល | មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍ |
| - តំបន់ឧស្សាហកម្មចម្រុះ | មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។ |
| ៤- តំបន់ចម្រុះ | មិនឲ្យលើសពី៧០%នៃផ្ទៃដីឡូត៍។ |
| ៥- តំបន់ដឹកជញ្ជូន | មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។ |
| ៦- តំបន់ទេសចរណ៍ | មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។ |
| ៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ | មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។ |
| ៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង | មិនឲ្យលើសពី១០%នៃផ្ទៃដីឡូត៍។ |
| ៩- តំបន់វប្បធម៌និងសាសនា | មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។ |
| ១០- តំបន់ផ្សេងៗមួយចំនួនទៀត | មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។ |

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ខាងលើនេះ មិនយកមកអនុវត្តនៅតំបន់លំនៅឋានណាមានផែនការប្រើប្រាស់ដីអនុម័តជាផ្លូវការរួចហើយមុនអនុក្រឹត្យនេះចូលជាធរមាន។ ក្នុងស្ថានភាពនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តតាមផែនការប្រើប្រាស់ដីនោះ។

ចំពោះករណីសំណង់ថ្មី សាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ ត្រូវរៀបចំឲ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០(សាមសិប)ភាគរយនៃផ្ទៃដីដែលនៅសល់ពីការសាងសង់នេះ។

បន្ថែមលើសួនច្បារជ្រាបទឹក គ្រប់ដីឡូត៍ស្នើសុំការសាងសង់ ត្រូវកំណត់ឲ្យដាំដើមឈើស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីបង្កើនផ្ទៃក្រឡាបៃតងក្នុងទីក្រុង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល។

ផ្ទៃក្រឡាដីឡូត៍១៥០(មួយរយហាសិប)ម៉ែត្រក្រឡា ត្រូវដាំដើមឈើឲ្យបានយ៉ាងតិច១(មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនដើមឈើត្រូវកំណត់យកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ការកំណត់និងការគណនាផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍និងបទដ្ឋានលម្អិតនៃការរៀបចំផ្ទៃបៃតង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍នៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើម រៀបចំដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនិងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា២២ .-**

សន្ទស្សន៍ប្រើប្រាស់ដីត្រូវកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការនិងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ទស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមានៅក្នុងប្រភេទដីអាចសាងសង់បាននៅទីក្រុង ត្រូវកំណត់ដូចខាងក្រោម៖

| | |
|---|---|
| ១- តំបន់លំនៅឋាន : | |
| - តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប | មិនឲ្យលើសពី១,៥ |
| - តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប | មិនឲ្យលើសពី១,៥ |
| - តំបន់លំនៅឋាន ដែលមានកម្ពស់មធ្យម | មិនឲ្យលើសពី៣,០ |
| - តំបន់លំនៅឋាន ដែលមានកម្ពស់ខ្ពស់ | មិនឲ្យលើសពី៥,០ |
| - តំបន់លំនៅឋានចម្រុះ | មិនឲ្យលើសពី៥,០។ |
| ២- តំបន់ពាណិជ្ជកម្ម : | |
| - តំបន់ពាណិជ្ជកម្ម | មិនឲ្យលើសពី១២ |
| - តំបន់ពាណិជ្ជកម្មចម្រុះ | មិនឲ្យលើសពី១០។ |
| ៣- តំបន់ឧស្សាហកម្ម : | |
| - តំបន់ឧស្សាហកម្ម | មិនឲ្យលើសពី៣,០ |
| - តំបន់ឧស្សាហកម្មស្រាល | មិនឲ្យលើសពី៣,០ |
| - តំបន់ឧស្សាហកម្មចម្រុះ | មិនឲ្យលើសពី៣,០។ |
| ៤- តំបន់ចម្រុះ | មិនឲ្យលើសពី១០។ |
| ៥- តំបន់ដឹកជញ្ជូន | មិនឲ្យលើសពី៣,០។ |
| ៦- តំបន់ទេសចរណ៍ | មិនឲ្យលើសពី៥,០។ |
| ៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ | មិនឲ្យលើសពី៥,០។ |
| ៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង | មិនឲ្យលើសពី០,៣។ |
| ៩- តំបន់វប្បធម៌និងសាសនា | មិនឲ្យលើសពី២,០។ |
| ១០- តំបន់ផ្សេងៗ មួយចំនួនទៀត | មិនឲ្យលើសពី៥,០។ |

ការកំណត់សន្ទស្សន៍ប្រើប្រាស់ដីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ .-**

ដើម្បីធានាការរៀបចំផែនការរូបវន្តទីក្រុង ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ការពង្រីកទីក្រុង និងការប្រើប្រាស់ដីក្នុងទីក្រុងប្រកបដោយប្រសិទ្ធភាព ដង់ស៊ីតេប្រជាជនអតិបរមាសម្រាប់ការពង្រីកប្រភេទដីអាចសាងសង់បានត្រូវកំណត់យ៉ាងតិច១២០(មួយរយម្ភៃ)នាក់ក្នុងមួយហិកតា។

## ផ្នែកទី២
## ប្រភេទដីកម្រិតការសាងសង់

**មាត្រា២៤ .-**

ប្រភេទដីកម្រិតការសាងសង់ ត្រូវបានបែងចែកជាតំបន់ ដូចខាងក្រោម៖

១- តំបន់កសិកម្ម

២- តំបន់ព្រៃឈើ

៣- តំបន់ធនធានទឹក

៤- តំបន់ការពារ។

៥- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

គម្រោងអភិវឌ្ឍនិងការសាងសង់នៅក្នុងតំបន់នេះត្រូវគោរពតាមនីតិវិធីនិងក្របខណ្ឌគតិយុត្តជាធរមាននិងតម្រូវឱ្យមានលិខិតអនុញ្ញាតប្តូរប្រភេទនៃការប្រើប្រាស់ដីឱ្យទៅជាប្រភេទដីអាចសាងសង់បានជាមុន។

មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឱ្យសាងសង់សំណង់លំនៅឋានផ្ទាល់ខ្លួនបានដែលពុំមានលក្ខណៈអាជីវកម្ម និងអាចសាងសង់រោងសិប្បកម្ម រោងចក្រសម្រាប់គោលដៅកសិកម្មបានដោយមិនបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

ការកំណត់ប្រភេទដីកម្រិតការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៥ .-**

ផលធៀបរវាងផ្ទៃក្រឡាបាតសំណង់និងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយ នៅក្នុងប្រភេទដីកម្រិតការសាងសង់នៅទីក្រុង ត្រូវកំណត់៣០(សាមសិប)ភាគរយ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ ត្រូវរៀបចំឱ្យមានសួនច្បារដែលអាចជ្រាបទឹកយ៉ាងតិច៥០(ហាសិប)ភាគរយនៃផ្ទៃដីដែលនៅសល់ពីការសាងសង់នេះ។

ផ្ទៃក្រឡាដីឡូត៍១០០(មួយរយ)ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១(មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។ ក្នុងការគណនាបើលទ្ធផលជាចំនួនទសភាគ ចំនួនដើមឈើត្រូវកំណត់យកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

**មាត្រា២៦ .-**

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាសម្រាប់ប្រភេទដីកម្រិតការសាងសង់នៅទីក្រុង ត្រូវកំណត់ត្រឹម១,៥(មួយកន្លះ)។

កាលណាសំណង់ថ្មីមួយ ត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ទស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

## ផ្នែកទី៣
## អំពីបទប្បញ្ញត្តិរួមសម្រាប់ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់

**មាត្រា២៧ .-**

លក្ខណ្ឌបរិស្ថាននៃការងារនគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា២៨ .-**

ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ មិនគិតបញ្ចូលផ្ទៃក្រឡាកម្រាលសំណង់ជាន់ក្រោមដី ជាន់ផ្ទាល់ដីដែលមានតែសរសរឥតមានរៀបជញ្ជាំង ផ្ទៃក្រឡាកម្រាលសំណង់គម្របជណ្តើរ ផ្ទៃក្រឡាកម្រាលសំណង់លំហក្រោមដំបូលដែលមានកម្ពស់តិចជាង១,៨០(មួយក្បៀសប្រាំបី)ម៉ែត្រ ផ្ទៃក្រឡាលំហផ្តល់ពន្លឺ សួនច្បារខាងក្នុងអគារ និងផ្ទៃក្រឡាកម្រាលសំណង់ដែលបម្រើសុខុមាលភាពសហគមន៍ក្នុងអគារលំនៅឋាន។

ការគណនាសន្ទស្សន៍ប្រើប្រាស់ដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូនីយកម្ម និងសំណង់។

ប្លង់សន្ទស្សន៍ប្រើប្រាស់ដីនៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា២៩ .-**

ក្នុងករណីដែលម្ចាស់សំណង់ស្នើសុំសាងសង់លើសពីកម្រិតអតិបរមានៃសន្ទស្សន៍ប្រើប្រាស់ដីដូចបានចែងក្នុងមាត្រា២២និងមាត្រា២៦នៃអនុក្រឹត្យនេះ ម្ចាស់សំណង់ត្រូវបង់ប្រាក់ជូនរដ្ឋជាមុន។ ថវិកាដែលបានមកពីការបង់ប្រាក់ពីការសាងសង់លើសសន្ទស្សន៍នៃការប្រើប្រាស់ដីនេះមួយចំណែកត្រូវបង់ចូលថវិការដ្ឋ មួយចំណែកទៀតត្រូវផ្តល់ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមួយចំណែកទៀតត្រូវផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលសំណង់នោះតាំងនៅ។

ចំនួនទឹកប្រាក់ដែលត្រូវបង់ជូនរដ្ឋនិងការបែងចែកថវិកា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការស្នើសុំសាងសង់លើសពីកម្រិតអតិបរមានៃសន្ទស្សន៍ប្រើប្រាស់ដីដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ មិនត្រូវបានអនុញ្ញាតជូនឡើយ ក្នុងករណីការស្នើសុំសាងសង់នោះមានផលប៉ះពាល់ជាអវិជ្ជមានដល់សុវត្ថិភាព សុខុមាលភាព សោភណភាព សណ្តាប់ធ្នាប់សាធារណៈ សុខដុមនីយកម្ម និងបរិស្ថាន។

**មាត្រា៣០ .-**

កម្ពស់អគារនៅទីក្រុង ត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានតំបន់ ប្រភេទអគារ ទំហំដីឡូត៍ ទំហំទទឹងផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលសំណង់នោះតាំងនៅ និងលើលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ភូមិសាស្ត្រ វប្បធម៌ ជាសុកភាព សុខភាព និងសោភណភាព ស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែងរបស់ខ្លួន និងអនុវត្តតាមវិធីសាស្ត្រណាមួយ ដូចខាងក្រោម៖

១- វិធីសាស្ត្រទី១ : ការកំណត់កម្ពស់ជាម៉ែត្រ ឬ

- អគារកម្ពស់ទាប ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី១១
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី១២ឡើងទៅ។

២- វិធីសាស្ត្រទី២ : ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ឬ

- ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ដូចមានចែងនៅក្នុងមាត្រា២២ មាត្រា២៦ និងមាត្រា២៧ នៃអនុក្រឹត្យនេះ។

៣- វិធីសាស្ត្រទី៣ : ការកំណត់កម្ពស់តាមប្លង់ទ្រេត ឬ

- អគារកម្ពស់ទាប ត្រូវបានអនុវត្តក្នុងករណីដែលទំហំទទឹងផ្លូវតូចជាងឬស្មើ៩(ប្រាំបួន)ម៉ែត្រ ដោយកម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ក)
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ខ)
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (គ)។

៤- វិធីសាស្ត្រទី៤ : ការកំណត់កម្ពស់អគារ ដោយប្រើប្រាស់វិធីសាស្ត្រខាងលើពីរឬបីរួមគ្នា។

កម្ពស់អតិបរមានិងអប្បបរមាតាមជាន់នីមួយៗនៃអគារ ត្រូវកំណត់ក្នុងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ស្របទៅតាមប្រភេទនៃការប្រើប្រាស់អគារ និងតាមទីតាំងភូមិសាស្ត្រ។ ទោះជាយ៉ាងណាកម្ពស់អគារអប្បបរមាសម្រាប់មួយជាន់ៗកំណត់ត្រឹម២,៨ម៉ែត្រ សម្រាប់អគារស្នាក់នៅ។

ប្លង់កម្ពស់អគារនៃរាជធានី និងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ចំនួន (ក) (ខ) និង(គ) នឹងត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ការកំណត់កម្ពស់នៃអគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣១ .-**

ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះទីតាំងដែលមានប្លង់ធ្លាគម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមប្លង់តម្រង់ជួរមានស្រាប់ស្របច្បាប់ ឬតាមផែនការប្រើប្រាស់ដីដែលបានធ្វើការព្យាករសម្រាប់លទ្ធភាពពង្រីកផ្លូវ នាពេលអនាគត។

ចំពោះទីតាំងដែលពុំមានប្លង់ធ្លាគម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមបទដ្ឋានដូចខាងក្រោម៖

១- អគារកម្ពស់ទាប

- ធ្លាគម្លាតខាងមុខយ៉ាងតិច៤(បួន)ម៉ែត្រ។ គម្លាតនេះ អាចកំណត់យ៉ាងតិច២(ពីរ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំង និងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ធ្វើរជើងសាធារណៈ
- ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២(ពីរ)ម៉ែត្រ។

២- អគារកម្ពស់មធ្យម

- ប្រភេទទី១ : អគារមានកម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី៨
    - ធ្លាគម្លាតខាងមុខយ៉ាងតិច៤(បួន)ម៉ែត្រ។ គម្លាតនេះអាចកំណត់យ៉ាងតិច២(ពីរ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំង និងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ធ្វើរជើងសាធារណៈ
    - ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២(ពីរ)ម៉ែត្រ។

-ប្រភេទទី២ : អគារមានកម្ពស់ចាប់ពីជាន់ទី៩ដល់ជាន់ទី១១

- ធ្លាគម្លាតខាងមុខយ៉ាងតិច៥(ប្រាំ)ម៉ែត្រ។ គម្លាតនេះ អាចកំណត់យ៉ាងតិច២,៥(ពីរម៉ែត្រកន្លះ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ
- ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥(ពីរម៉ែត្រកន្លះ)ម៉ែត្រ។

ក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ ត្រូវរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្របឬក្នុងអគារសម្រាប់សាធារណៈ ដែលមានទំហំទទឹងយ៉ាងតិច២(ពីរ)ម៉ែត្រ ដើម្បីលើកទឹកចិត្តដល់ថ្មើរជើង។

បទដ្ឋានបច្ចេកទេសកំណត់គម្លាតអប្បបរមាក្នុងដីឡូត៍បន្ថែមពីការកំណត់ខាងលើ សម្រាប់ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់ធ្លាគម្លាតអគារនៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ និងសម្រេចដាក់ឱ្យប្រើប្រាស់ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។

**មាត្រា៣២ .-**

បទដ្ឋានទំហំដីឡូត៍បច្ចេកទេស ត្រូវបានកំណត់ឡើង ដើម្បីធានាការរៀបចំផែនការរូបវន្តទីក្រុង ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធ និងការអភិវឌ្ឍដី ឱ្យមានសោភណភាព មានសណ្តាប់ធ្នាប់ និងមានប្រសិទ្ធភាព។

ទំហំដីឡូត៍បច្ចេកទេសអប្បបរមា សម្រាប់តំបន់លំនៅឋាន ត្រូវបានកំណត់តាមប្រភេទ ដូចខាងក្រោម៖

១- តំបន់លំនៅឋានមានកម្ពស់ទាប
- តំបន់លំនៅឋានដាច់ពីគ្នា(ភូមិគ្រឹះឬពាក់កណ្តាលភូមិគ្រឹះ) មានទំហំដីយ៉ាងតិច១០ម x ២០ម
- តំបន់លំនៅឋានជាប់គ្នា(ផ្ទះល្វែងឬផ្ទះជាប់គ្នា) មានទំហំដីយ៉ាងតិច៤ម x ១៥ម។

២- តំបន់លំនៅឋានមានកម្ពស់មធ្យម
- ប្រភេទទី១(ពីជាន់ទី៣ដល់ជាន់ទី៨) មានទំហំដីយ៉ាងតិច១៥ម x ២៥ម
- ប្រភេទទី២(ពីជាន់ទី៩ដល់ជាន់ទី១១) មានទំហំដីយ៉ាងតិច២០ម x ៣០ម។

៣- តំបន់លំនៅឋានមានកម្ពស់ខ្ពស់
- ប្រភេទទី១(ពីជាន់ទី១២ដល់ជាន់ទី១៨) ទំហំដីឡូត៍ចាប់ពី១៥០០ម$^{២}$ឡើងទៅ
- ប្រភេទទី២(ពីជាន់ទី១៩ឡើងទៅ) ទំហំដីឡូត៍ចាប់ពី៣០០០ម$^{២}$ឡើងទៅ

ការកំណត់ទំហំដីឡូត៍បច្ចេកទេសខាងលើនេះ មិនយកមកអនុវត្តចំពោះទំហំដីឡូត៍ដែលមានរួចហើយ និងដែលមានទំហំតូចជាងការកំណត់ខាងលើនេះ។

ទំហំដីឡូត៍បច្ចេកទេសអប្បបរមា សម្រាប់តំបន់លំនៅឋានផ្សេងទៀត តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម និងតំបន់កសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

ការប្តូរប្រភេទនៃការប្រើប្រាស់ដីពីប្រភេទដីកម្រិតការសាងសង់ទៅជាប្រភេទដីអាចសាងសង់បាន ត្រូវធ្វើតាមរយៈ៖

- ការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតឱ្យមានទីក្រុងឬទីប្រជុំជនថ្មី និងផែនការអភិវឌ្ឍក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

- ការផ្ដួចផ្ដើមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងទស្សនៈជំនាញ ដើម្បីបំពេញតម្រូវការនៃកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកិច្ច
- ការផ្ដួចផ្ដើមរបស់អាជ្ញាធររាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត អាស្រ័យតាមតម្រូវការនៃកំណើនប្រជាជន ដែលមានដង់ស៊ីតេប្រជាជនក្នុងប្រភេទដីអាចសាងសង់បាន លើសពីកម្រិតអតិបរមា ដូចមានចែងក្នុងមាត្រា២៣
- ការស្នើសុំរបស់ម្ចាស់ដីឬអ្នកវិនិយោគ ក្នុងគោលបំណងធ្វើការអភិវឌ្ឍដីពិតប្រាកដ និងស្របតាមលក្ខណៈបច្ចេកទេសនៃនគរូបនីយកម្ម។

ការស្នើសុំប្ដូរប្រភេទនៃការប្រើប្រាស់ដី ពីប្រភេទដីកម្រិតការសាងសង់មកជាប្រភេទដីអាចសាងសង់បាន អាចធ្វើទៅបាន លុះត្រាតែមានការធ្វើផែនការប្រើប្រាស់ដីសម្រាប់ដីដែលសុំប្ដូរ និងផែនការរចនាសម្ព័ន្ធរូបវន្តសាធារណៈឲ្យបានច្បាស់លាស់និងបានយល់ព្រមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ដើម្បីស្នើសុំប្ដូរប្រភេទនៃការប្រើប្រាស់ដី សាមីសំណើត្រូវរៀបចំគម្រោងផែនការមេអភិវឌ្ឍ និងសាងសង់ឲ្យមានផ្ទៃដីសម្រាប់បណ្ដាញផ្លូវថ្នល់ ឲ្យបានយ៉ាងតិច២៥(ម្ភៃប្រាំ)ភាគរយនៃផ្ទៃដីសរុបក្នុងប្រភេទដីអាចសាងសង់បាន និងផ្ទៃក្រឡាលំហសាធារណៈនិងផ្ទៃបៃតង១០(ដប់)ភាគរយនៃផ្ទៃដីសរុបឬ១០(ដប់)ម៉ែត្រក្រឡា សម្រាប់មនុស្សម្នាក់។

ការប្ដូរប្រភេទនៃការប្រើប្រាស់ដីដែលទាក់ទងនឹងដីរដ្ឋ ត្រូវអនុវត្តតាមច្បាប់ នីតិវិធី និងបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីនិងបែបបទនៃការរៀបចំឯកសារស្នើសុំប្ដូរប្រភេទនៃការប្រើប្រាស់ដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវមានគ្រប់គ្រាន់តាមតម្រូវការនៃប្រភេទអគារនីមួយៗ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ និងទីតាំងសាធារណៈ។

ចំនួនចំណតរថយន្តអប្បបរមាសម្រាប់អគារក្នុងដីឡូត៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អគារលំនៅឋានរួមមាន៖

| | | |
|---|---|---|
| - លំនៅឋានដាច់(ភូមិគ្រឹះ និង ពាក់កណ្ដាលភូមិគ្រឹះ) | ផ្ទៃក្រឡាកម្រាល១០០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - លំនៅឋានជាប់(ផ្ទះល្វែង និង ផ្ទះជាប់គ្នា) | ផ្ទៃក្រឡាកម្រាល១២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទប្រណីត | ផ្ទៃក្រឡាកម្រាល១០០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទមធ្យម | ផ្ទៃក្រឡាកម្រាល១២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទធម្មតា | ផ្ទៃក្រឡាកម្រាល១៥០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង។ |

២- អគារពាណិជ្ជកម្ម រួមមាន៖

| | | |
|---|---|---|
| - ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន និងក្លឹបកម្សាន្ត | ផ្ទៃក្រឡាកម្រាល២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| | និងផ្ទៃក្រឡាកន្លែងរាំ១ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - ផ្សារទំនើប | ផ្ទៃក្រឡាកម្រាល៥០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - ផ្សារ ឬ កន្លែងលក់ដូរ | ផ្ទៃក្រឡាកម្រាល៥០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |

- អគារពាណិជ្ជកម្មផ្សេងៗ ផ្ទៃក្រឡាកម្រាល៥០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង។

៣- អគារឧស្សាហកម្ម រួមមាន៖

- អគាររោងចក្រ ផ្ទៃក្រឡាកម្រាល២៥០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង និងក្រឡាផ្ទៃកម្រាល១២៥០ម$^{២}$ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាកម្រាល៤០០ម$^{២}$ត្រូវមានចំណតរថយន្តតូច១កន្លែង និង ផ្ទៃក្រឡាកម្រាល២០០០ម$^{២}$ត្រូវមានចំណតរថយន្តធំ១កន្លែង។

៤- អគារសិក្សាធិការ អប់រំ និងកីឡា រួមមាន៖

- អគារគ្រឹះស្ថានឧត្តមសិក្សា ផ្ទៃក្រឡាកម្រាល១០០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានមធ្យមសិក្សា ផ្ទៃក្រឡាកម្រាល២០០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានបឋមសិក្សា ផ្ទៃក្រឡាកម្រាល៣០០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង
- មជ្ឈមណ្ឌលកីឡា ផ្ទៃក្រឡាកម្រាល១០០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង។

៥- អគារសុខភាព រួមមាន៖

- អគារមន្ទីរពេទ្យ ផ្ទៃក្រឡាកម្រាល១០០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង
- ក្លឹបហាត់ប្រាណនិងសុខភាព ផ្ទៃក្រឡាកម្រាល១២០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង។

៦- អគារសាលមហោស្រព សាលប្រជុំ ពិធី និងរោងភាពយន្ត រួមមាន៖

- អគារមហោស្រព រោងភាពយន្ត សាលជួបជុំ និងពិធី ផ្ទៃក្រឡាកម្រាល៣០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៣០០ម$^{២}$ត្រូវមានចំណតរថយន្តធំ១កន្លែង។

៧- អគារសណ្ឋាគារនិងផ្ទះសំណាក់ រួមមាន៖

- អគារសណ្ឋាគារ ចំនួនបន្ទប់៥បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារផ្ទះសំណាក់ ចំនួនបន្ទប់១០បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង។

៨- អគារការិយាល័យសាធារណៈនិងការិយាល័យឯកជន រួមមាន៖

- អគាររដ្ឋបាលនិងការិយាល័យឯកជន ផ្ទៃក្រឡាកម្រាល ១០០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង។

៩- ស្ថានីយប្រេងឥន្ធនៈ រួមមាន៖

- ស្ថានីយប្រេងឥន្ធនៈ ផ្ទៃក្រឡាកម្រាល១០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល១០០ម$^{២}$ត្រូវមានចំណតរថយន្តធំ១កន្លែង។

១០- អគារការិយាល័យដឹកជញ្ជូន រួមមាន៖

- អគារការិយាល័យដឹកជញ្ជូន ផ្ទៃក្រឡាកម្រាល១០០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម$^{២}$ត្រូវមានចំណតរថយន្តធំ១កន្លែង។

១១- អគារផ្សេងៗរួមមាន៖

- អគារផ្សេងៗ ផ្ទៃក្រឡាកម្រាល១៥០ម$^{២}$ ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម$^{២}$ត្រូវមានចំណតរថយន្តធំ១កន្លែង។

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ដែលបានកំណត់ខាងលើនេះ ជាចំនួនអប្បបរមាដែលត្រូវមានជាចាំបាច់ សម្រាប់ការអភិវឌ្ឍនិងការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនចំណតនេះត្រូវយកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ក្នុងករណីអគារបម្រើមុខងារចម្រុះ ការគណនាចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវគណនាតាមប្រភេទមុខងារនីមួយៗ ហើយបូកសរុបបញ្ចូលគ្នា ទើបទទួលបានចំនួនចំណតសរុប សម្រាប់អគារទាំងមូល។

ការរៀបចំចំណតយានយន្តនៅទីសាធារណៈនិងឯកជនត្រូវមានចំណតសម្រាប់ជនពិការនិងជនងាយរងគ្រោះ។

បទដ្ឋានចំណតយានយន្ត ទំហំចំណត និងលក្ខណៈបច្ចេកទេសសម្រាប់ចំណតក្នុងដីឡូត៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះបទដ្ឋានកំណត់ទីតាំងចំណតយានយន្តនិងទំហំចំណតសម្រាប់ចំណតសាធារណៈក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការចេញលិខិតអនុញ្ញាតសាងសង់ណាមួយចំពោះប្រភេទអគារខាងលើ ត្រូវគោរពតាមបទប្បញ្ញត្តិចំនួនចំណតអប្បបរមានៃមាត្រា៣៣នេះ។

## ជំពូកទី៦

## ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈ

**មាត្រា៣៥ .-**

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈមានដូចខាងក្រោម៖

១- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ រួមមាន៖

- បណ្តាញផ្លូវសាធារណៈ
- បរិក្ខារសាធារណៈ ដូចជាប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍។ល។
- ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ ដូចជា ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម ប្រព័ន្ធលូអាងប្រព្រឹត្តកម្មទឹកកខ្វក់។ល។
- ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យនិងហានិភ័យផ្សេងៗ។

២- សំណង់សម្រាប់ផ្តល់សេវាជូនសាធារណជនរួមមាន៖

- អគាររដ្ឋបាលសាធារណៈ អគារសិក្សាសាធារណៈ មន្ទីរពេទ្យសាធារណៈ
- ចំណតយានយន្តសាធារណៈ ចំណតរថយន្តក្រុង ចំណតរថយន្តឈ្នួល ស្ថានីយរថភ្លើងសម្រាប់អ្នកដំណើរ ស្ថានីយចែកចាយទំនិញ ផែស្ងួត មជ្ឈមណ្ឌលផ្គត់ផ្គង់ភស្តុភារកម្ម។ល។ ត្រូវរៀបចំសម្រាប់មនុស្សទូទៅនិងជនពិការ និងមិនត្រូវស្ថិតនៅលើចិញ្ចើមផ្លូវសាធារណៈសម្រាប់ថ្មើរជើងឡើយ។

៣- លំហសាធារណៈរួមមាន៖

- សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា ទីលានកម្សាន្ត។

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជននិងលំហសាធារណៈ ត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការនិងជនងាយរងគ្រោះ។

នៅពេលដំណើរការអនុវត្តគម្រោងអភិវឌ្ឍនានា ដើម្បីផលប្រយោជន៍សាធារណៈដែលប៉ះពាល់ដល់កម្មសិទ្ធិឯកជនស្របច្បាប់ ការដកហូតកម្មសិទ្ធិមួយផ្នែកឬទាំងស្រុង ត្រូវអនុវត្តតាមច្បាប់អស្សាមិករណ៍។

# ផ្នែកទី១
## អំពីហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

**មាត្រា៣៦ .-**

ទំហំសមាមាត្រដីសម្រាប់បម្រើឲ្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវកំណត់យ៉ាងតិច២៥(ម្ភៃប្រាំ) ភាគរយនៃប្រភេទដីអាចសាងសង់បាន។

រាល់គម្រោងអភិវឌ្ឍន៍ទីក្រុងត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រានេះ។

**មាត្រា៣៧ .-**

បណ្តាញផ្លូវនៅទីក្រុង ត្រូវបានបែងចែកដូចខាងក្រោម៖

- ប្រភេទទី១- មហាវិថី
- ប្រភេទទី២- វិថី
- ប្រភេទទី៣- អនុវិថី
- ប្រភេទទី៤- ផ្លូវបម្រើឱ្យការដឹកជញ្ជូនសំខាន់ៗ
- ប្រភេទទី៥- ផ្លូវថ្មើរជើង។

**មាត្រា៣៨ .-**

គម្លាតចន្លោះរវាងមហាវិថីមួយទៅមហាវិថីមួយ ឬពីវិថីមួយទៅវិថីមួយ ឬពីផ្លូវមួយទៅផ្លូវមួយ និងទំហំផ្លូវនីមួយៗដូចមានចែងក្នុងមាត្រា៣៦ខាងលើ ត្រូវគោរពតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនិងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៣៩ .-**

ការរៀបចំផែនការរូបវន្តទីក្រុងត្រូវរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈនិងផ្ទៃបៃតងអប្បបរមាមានជាអាទិ៍ បណ្តាញផ្លូវ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធបង្ហូរទឹកកខ្វក់ ប្រព័ន្ធបង្ហូរទឹកភ្លៀង អាងស្តុកទឹក អាងប្រព្រឹត្តកម្មទឹកកខ្វក់ ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ ក្បាលបំពង់ទឹកសម្រាប់ពន្លត់អគ្គិភ័យ បណ្តាញអគ្គិសនី ព្រមទាំងបណ្តាញទូរគមនាគមន៍។

**មាត្រា៤០ .-**

ការរៀបចំផែនការរូបវន្តទីក្រុង ត្រូវកំណត់ឲ្យបានច្បាស់អំពីផែនការបន្សាំនិងកាត់បន្ថយនៃការប្រែប្រួលអាកាសធាតុ ដើម្បីកំណត់ទីតាំងដែលងាយបង្កឲ្យមានគ្រោះអគ្គិភ័យ និងហានិភ័យផ្សេងៗជាយថាហេតុ ដើម្បីរៀបចំឲ្យមានការការពារច្បាស់លាស់ចំពោះសុវត្ថិភាពសាធារណៈ សុខុមាលភាពសាធារណៈ បរិស្ថាន ធនធានធម្មជាតិ វប្បធម៌ និងជីវិតមនុស្ស។

សេចក្តីពិពណ៌នាលម្អិតអំពីគ្រោះអគ្គិភ័យនិងហានិភ័យផ្សេងៗជាយថាហេតុ ត្រូវចែងក្នុងរបាយការណ៍បច្ចេកទេសនៃការរៀបចំផែនការរូបវន្តទីក្រុង។

**មាត្រា៤១ .-**

បទដ្ឋានទំហំដីសម្រាប់អភិវឌ្ឍបណ្តាញផ្លូវក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

បទដ្ឋានបច្ចេកទេសលម្អិតអំពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងបរិក្ខារសាធារណៈក្នុងទីក្រុងមានជាអាទិ៍ ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង ប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ និងការគ្រប់គ្រងគ្រោះអគ្គិភ័យ និងហានិភ័យផ្សេងៗ។ល។ ត្រូវកំណត់ដោយក្រសួង ស្ថាប័នជំនាញ។

## ផ្នែកទី២
## សំណង់ផ្តល់សេវាជូនសាធារណជន

**មាត្រា៤២ .-**

ការរៀបចំផែនការរូបវន្តទីក្រុង ត្រូវរៀបចំឲ្យមានអគារបម្រើសេវាសាធារណៈគ្រប់គ្រាន់ទៅតាមតម្រូវការចាំបាច់ដូចជាសាលារៀន មណ្ឌលសុខភាព អគាររដ្ឋបាលជាដើម ដើម្បីធានាការផ្តល់នូវសេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងមានសមធម៌។ គ្រប់អគារបម្រើសេវាសាធារណៈ ត្រូវមានរៀបចំសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ និងជនចាស់ជរាផង។

**មាត្រា៤៣ .-**

ដើម្បីធានាបាននូវការអប់រំប្រកបដោយប្រសិទ្ធភាពនិងមានសមធម៌ ការរៀបចំផែនការរូបវន្តទីក្រុងត្រូវរៀបចំឲ្យមានសាលារៀនតាមបទដ្ឋាន ដូចខាងក្រោម៖

- សាលាមត្តេយ្យសិក្សា ត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៥០០(ប្រាំរយ)ម៉ែត្រ ឬភូមិមួយត្រូវមានសាលាមត្តេយ្យសិក្សាមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។
- សាលាបឋមសិក្សាត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៥០០(ប្រាំរយ)ម៉ែត្រ ឬភូមិមួយត្រូវមានសាលាបឋមសិក្សាមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។
- អនុវិទ្យាល័យត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៣ ០០០(បីពាន់)ម៉ែត្រ ឬឃុំមួយត្រូវមានអនុវិទ្យាល័យមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។
- វិទ្យាល័យត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៥ ០០០(ប្រាំពាន់)ម៉ែត្រ ឬស្រុកមួយត្រូវមានវិទ្យាល័យមួយយ៉ាងតិចឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។

**មាត្រា៤៤ .-**

បទដ្ឋានបច្ចេកទេសលម្អិតអំពីការរៀបចំអគាររដ្ឋបាលសាធារណៈ អគារសេវាសុខភាពសាធារណៈ ចំណតសាធារណៈ អគារស្ថានីយអ្នកដំណើរសាធារណៈ អគារប្រៃសណីយ៍។ល។ ត្រូវកំណត់ដោយក្រសួង ស្ថាប័នជំនាញ។

## ផ្នែកទី៣
## អំពីលំហសាធារណៈ

**មាត្រា៤៥ .-**

ការរៀបចំលំហសាធារណៈនិងផ្ទៃបៃតងក្នុងប្រភេទដីអាចសាងសង់បាន ត្រូវកំណត់១(មួយ)ហិកតា សម្រាប់មនុស្ស១ ០០០(មួយពាន់)នាក់ ឬមានទំហំយ៉ាងតិច៥(ប្រាំ)ភាគរយ នៃផ្ទៃដីសរុបក្នុងប្រភេទដីអាចសាងសង់បាន។ លំហសាធារណៈ ត្រូវមានរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់មនុស្សទាំងអស់គ្នារួមទាំងជនពិការជនចាស់ជរា និងជនអសមត្ថភាព។

**មាត្រា៤៦ .-**

លំហសាធារណៈនិងផ្ទៃបៃតង មានជាអាទិ៍៖

១- សួនកុមារសម្រាប់វ័យមត្តេយ្យសិក្សានិងបឋមសិក្សាលេងនិងហាត់កីឡា បំពាក់ដោយឧបករណ៍និងសម្ភារៈដែលមានសុវត្ថិភាព និងជួយដល់ការរីកចម្រើននៃការវិវត្តរបស់កុមារ ចំពោះភាពឆ្លាតវៃ

សុខភាពល្អ។ សួននេះអាចមានទំហំ២ ០០០(ពីរពាន់)ម៉ែត្រក្រឡា និងត្រូវមានរបងការពារសុវត្ថិភាព ហើយត្រូវមានចម្ងាយពីសួនមួយទៅសួនមួយយ៉ាងច្រើន១(មួយ)គីឡូម៉ែត្រ ឬនៅជាប់នឹងសាលាមត្តេយ្យសិក្សា ឬបឋមសិក្សា។

២- សួនច្បារភូមិសម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងសហគមន៍ឬតំបន់លំនៅឋាននីមួយៗដែលអាចប្រើប្រាស់ដោយផ្ទាល់និងមិនផ្ទាល់។ សួននេះអាចមានទំហំ៥ ០០០(ប្រាំពាន់)ម៉ែត្រក្រឡា និងត្រូវមានចម្ងាយពីសួនមួយទៅសួនមួយយ៉ាងច្រើន២(ពីរ)គីឡូម៉ែត្រ។

៣- សួនច្បារសង្កាត់សម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងសង្កាត់និងតំបន់ជិតខាងនូវសកម្មភាពសម្រាកកម្សាន្ត លំហែ និងកីឡា។ សួននេះអាចមានទំហំ៥(ប្រាំ)ហិកតា។

៤- សួនច្បារទីក្រុងសម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងទីក្រុងនូវសកម្មភាពសម្រាកកម្សាន្ត លំហែ និងកីឡា។ សួននេះអាចមានទំហំ១០(ដប់)ហិកតា។

៥- សួនតំបន់ជាសួនខ្នាតធំដែលប្រើប្រាស់សម្រាប់តំបន់ឬទីក្រុងច្រើន ក្នុងគោលបំណងថែរក្សាទេសភាព និងសោភណភាពធម្មជាតិ ដែលប្រើប្រាស់សម្រាប់ការធ្វើដំណើរនិងការបោះជំរុំទេសចរណ៍ និងកម្សាន្ត របស់ប្រជាពលរដ្ឋក្នុងទីក្រុង។ សួននេះ អាចមានទំហំ៥០(ហាសិប)ហិកតា។

៦- ឧទ្យានរុក្ខសាស្ត្ររៀបចំដាំដុះរុក្ខជាតិដ៏សំបូរបែប ក្នុងគោលបំណងការសិក្សាស្រាវជ្រាវ ការកម្សាន្ត និងការទស្សនា។ ឧទ្យាននេះត្រូវបានប្រជាពលរដ្ឋចូលចិត្តធ្វើដំណើរ ទេសចរណ៍ និងកម្សាន្តជាលក្ខណៈគ្រួសារ ហើយចំណាយពេលវេលាស្ទើរពេញមួយថ្ងៃ។ ឧទ្យាននេះមានទំហំអាស្រ័យតាមភូមិសាស្ត្រជាក់ស្តែង។

៧- ឧទ្យានសួនសត្វរៀបចំចិញ្ចឹមសត្វព្រៃដ៏សំបូរបែប ក្នុងគោលបំណងការសិក្សាស្រាវជ្រាវ ការកម្សាន្ត និងការទស្សនា។ ឧទ្យាននេះត្រូវបានប្រជាពលរដ្ឋចូលចិត្តធ្វើដំណើរទេសចរណ៍ និងកម្សាន្តជាលក្ខណៈគ្រួសារ។ ឧទ្យាននេះមានទំហំអាស្រ័យតាមភូមិសាស្ត្រជាក់ស្តែង។

៨- សួនតាមដងផ្លូវ បណ្តាញបៃតងដែលរៀបចំដាំដើមឈើលើសួនច្បារនិងតាមដង ផ្លូវដើម្បីតភ្ជាប់បណ្តាញបៃតងនៅក្នុងទីក្រុង។ ទំហំបណ្តាញបៃតងនេះអាស្រ័យតាមភូមិសាស្ត្រជាក់ស្តែង។

**មាត្រា៤៧ .-**

ក្នុងករណីចាំបាច់ សួនច្បារទាំង៨ប្រភេទខាងលើអាចមានទំហំតូចជាងទំហំកំណត់ខាងលើ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទំហំនោះត្រូវមានលក្ខណៈសមស្របសម្រាប់ឲ្យសាធារណជននិងសហគមន៍អាចប្រើប្រាស់បាន ហើយដែលមានចែងក្នុងនីតិវិធីបច្ចេកទេសលម្អិតអំពីការរៀបចំលំហសាធារណៈនិងផ្ទៃបៃតង។

បទដ្ឋានបច្ចេកទេសអំពីការរៀបចំលំហសាធារណៈនិងផ្ទៃបៃតង ត្រូវកំណត់ដោយក្រសួងឬស្ថាប័នជំនាញ។

ការរៀបចំផែនការរូបវន្តទីក្រុង គម្រោងអភិវឌ្ឍន៍ទីក្រុង និងការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃជំពូកនេះ។

## ជំពូកទី៧

## ការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង និងការសាងសង់ទីក្រុង

**មាត្រា៤៨ .-**

ទីក្រុងត្រូវបានអនុវត្តតាមរយៈគម្រោងសាងសង់ គម្រោងអភិវឌ្ឍក្នុងទីក្រុង និងគម្រោងអភិរក្សក្នុងទីក្រុង ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ដី ការកែលម្អ និងបំពេញបន្ថែមហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈនិងបរិស្ថានល្អស្អាត ដើម្បីធានាបាននូវការអភិវឌ្ឍនិងការអភិរក្ស ប្រកបដោយចីរភាព សមធម៌

និងការធ្វើសមាហរណកម្ម។ ការអភិវឌ្ឍទីក្រុងត្រូវគិតអំពីតម្រូវការខាងលំនៅឋានសមស្រប និងមានតុល្យភាពរវាងលទ្ធភាពដែលគ្រួសារក្រីក្រនិងអ្នកមានប្រាក់ចំណូលទាប អាចរកបានលំនៅឋានសមរម្យ និងតម្រូវការសេដ្ឋកិច្ចរបស់រដ្ឋនិងផ្នែកឯកជន។

**មាត្រា៤៩ .-**

គម្រោងអភិវឌ្ឍក្នុងទីក្រុង រួមមាន៖

១- គម្រោងអភិវឌ្ឍដី

១.១- គម្រោងប្តូរប្រភេទនៃការប្រើប្រាស់ដី

១.២- គម្រោងបង្រួមក្បាលដី

១.៣- គម្រោងបំបែកក្បាលដី។

២- គម្រោងកែសម្រួលក្បាលដី

៣- គម្រោងអភិវឌ្ឍទីក្រុងឡើងវិញ

៤- គម្រោងអភិវឌ្ឍទីតាំងថ្មី

៥- គម្រោងអភិវឌ្ឍលំនៅឋាន

៦- គម្រោងអភិវឌ្ឍសួនឧស្សាហកម្ម

៧- គម្រោងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

៨- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង

៩- គម្រោងអភិវឌ្ឍតំបន់ទេសចរណ៍

១០-គម្រោងចែករំលែកដី

១១-គម្រោងអភិវឌ្ឍផ្សេងៗ។

គម្រោងអភិរក្សក្នុងទីក្រុង រួមមាន៖

១-គម្រោងអភិរក្សតំបន់បៃតង

២-គម្រោងអភិរក្សសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រ

៣-គម្រោងអភិរក្សទេសភាពទីក្រុង

៤-គម្រោងអភិរក្សរមណីយដ្ឋានវប្បធម៌

៥-គម្រោងអភិរក្សផ្សេងៗ។

**មាត្រា៥០ .-**

គម្រោងអភិវឌ្ឍក្នុងទីក្រុង រួមមាន៖

១- គម្រោងអភិវឌ្ឍដី ត្រូវបានអនុវត្តក្នុងគោលដៅផ្លាស់ប្តូរប្រភេទនៃការប្រើប្រាស់ដី កែសម្រួលតំបន់ប្រើប្រាស់ដីឡើងវិញ ដើម្បីធ្វើការអភិវឌ្ឍទីក្រុង មានជាអាទិ៍ការបង្រួមក្បាលដីឬការបំបែកក្បាលដី ដោយត្រូវគោរពតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងធានាបាននូវបទដ្ឋានអប្បបរមានៃការប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ព្រមទាំងលក្ខខណ្ឌបរិស្ថាន សេដ្ឋកិច្ច និងសង្គមកិច្ច។

១.១- គម្រោងប្តូរប្រភេទនៃការប្រើប្រាស់ដី ត្រូវបានអនុវត្តដោយការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមមាត្រា៣២នៃអនុក្រឹត្យនេះ។

១.២- គម្រោងបង្រួមក្បាលដី ត្រូវបានអនុវត្តដោយការបូកបញ្ចូលក្បាលដីដែលស្ថិតនៅជាប់គ្នាទាំងអស់ក្នុងក្របខ័ណ្ឌនៃគម្រោង ដើម្បីរៀបចំជាប្លង់ប្រើប្រាស់ដីសមាហរណកម្មមួយសម្រាប់ការអភិវឌ្ឍ

និងការសាងសង់ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

១.៣- គម្រោងបំបែកក្បាលដីត្រូវបានអនុវត្តដោយការបំបែកក្បាលដីមួយជាដីឡូត៍បច្ចេកទេសច្រើន សម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

២- គម្រោងកែសម្រួលក្បាលដី ត្រូវបានអនុវត្តដោយការរៀបចំក្បាលដីឡើងវិញ ដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួម និងការយល់ព្រមបរិច្ចាគដីពីម្ចាស់ដីឡូត៍ទាំងអស់ ព្រមទាំងបង្កើនលទ្ធភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

៣- គម្រោងអភិវឌ្ឍទីក្រុងឡើងវិញ ត្រូវបានអនុវត្តនៅតំបន់ណាមួយនៃទីក្រុង ក្នុងគោលបំណងកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងបង្កើនលទ្ធភាពប្រើប្រាស់ដីឲ្យមានប្រសិទ្ធភាពនិងសោភណភាព តាមរយៈការផ្ទេរសិទ្ធិលើដីនិងអគារទៅជាសិទ្ធិលើផ្ទៃក្រឡាកម្រាលអគារថ្មីដែលមានតម្លៃស្មើនៅក្នុងគម្រោងនេះ ដោយមានការចូលរួមនិងយល់ព្រមពីម្ចាស់ដីឡូត៍ ឬតាមតម្រូវការនៃការអភិវឌ្ឍទីក្រុង ស្របតាមច្បាប់។

៤- គម្រោងអភិវឌ្ឍទីតាំងថ្មី ត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែមនូវតម្រូវការនៃកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ស្របតាមយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវមុខងាររបស់ទីក្រុងសម្រាប់ការរស់នៅ ការសម្រាកលំហែកម្សាន្ត ការមានការងារធ្វើ និងការធ្វើចរាចរប្រកបដោយសុវត្ថិភាពនិងសោភណភាព។

៥- គម្រោងអភិវឌ្ឍន៍លំនៅឋាន ត្រូវបានអនុវត្តក្នុងគោលបំណងធានាបាននូវសុខភាព ផាសុកភាព សោភណភាព និងសុខដុមរមណីយកម្មសម្រាប់ការស្នាក់នៅ ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ដល់ការស្នាក់នៅ។

៦- គម្រោងអភិវឌ្ឍសួនឧស្សាហកម្ម ត្រូវបានអនុវត្តក្នុងគោលដៅធានាបាននូវការឯកភាព និងសុខដុមនីយកម្មសម្រាប់ឧស្សាហកម្ម ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ផ្សេងៗដល់សុខភាព។

៧- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុវត្តស្របតាមស្មារតីនៃអនុក្រឹត្យស្ដីពីការបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥។ ការធ្វើប្លង់គោលនិងផែនការប្រើប្រាស់ដីសម្រាប់តំបន់សេដ្ឋកិច្ចពិសេស ត្រូវតែធានាបាននូវបទដ្ឋានអប្បបរមានៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈ ព្រមទាំងធានាបាននូវការធ្វើសមាហរណកម្មនៃហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់នេះ ទៅនឹងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ឬផែនការថ្មីនៃទីក្រុង ខេត្ត តំបន់ និងជាតិ។

៨- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែម ឬបង្កើតថ្មីនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដើម្បីឲ្យឆ្លើយតបនឹងកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទីក្រុង ខេត្ត តំបន់ និងជាតិ។

៩- គម្រោងអភិវឌ្ឍតំបន់ទេសចរណ៍ត្រូវបានអនុវត្តក្នុងគោលដៅទាក់ទាញការវិនិយោគវិស័យទេសចរណ៍ និងលើកកម្ពស់គុណភាពសេវាទេសចរណ៍ ស្របតាមគោលនយោបាយ ទេសចរណ៍នៅកម្ពុជា

១០-គម្រោងចែករំលែកដី ត្រូវបានអនុវត្តក្នុងគោលដៅកែលម្អស្ថានភាព លក្ខខណ្ឌរស់នៅ និងសោភណភាពនៃសហគមន៍ ឲ្យទទួលបានលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាសាធារណៈ សមស្រប។ គម្រោងចែករំលែកដី ត្រូវធ្វើឡើងដោយមានការឯកភាពពីម្ចាស់ដី និង/ឬ សហគមន៍ និងអ្នកវិនិយោគ ក្នុងការចែករំលែកផលប្រយោជន៍គ្នាទៅវិញទៅមក។

១១-គម្រោងអភិវឌ្ឍផ្សេងៗ ត្រូវបានអនុវត្តដើម្បីបំពេញបន្ថែម និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍទីក្រុង ក្នុងគោលបំណងធានាបាននូវសុខភាព ផាសុកភាព សោភណភាព និងសុខដុមនីយកម្មសម្រាប់ការស្នាក់នៅ។

**មាត្រា៥១ .-**

គម្រោងអភិរក្សក្នុងទីក្រុង រួមមាន៖

១-គម្រោងអភិរក្សតំបន់បៃតង ត្រូវបានអនុវត្តក្នុងគោលបំណងធានាបាននូវគុណភាពបរិស្ថានរស់នៅ សុវត្ថិភាពស្បៀង ប្រព័ន្ធបៃតង និងរួមចំណែកទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។

២-គម្រោងអភិរក្សសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រ ត្រូវបានអនុវត្តក្នុងគោលបំណងរក្សាអត្តសញ្ញាណប្រវត្តិសាស្ត្រ ការវិវត្តនៃទីក្រុង និងផលប្រយោជន៍ជាតិ។

៣-គម្រោងអភិរក្សទេសភាពទីក្រុង ត្រូវបានអនុវត្តក្នុងគោលបំណងរក្សាទេសភាពធម្មជាតិ ពិសេសនៅទីតាំងណាមួយនៃទីក្រុង ដើម្បីលើកកម្ពស់សោភណភាពទីក្រុងនិងទេសចរណ៍។

៤-គម្រោងអភិរក្សរមណីយដ្ឋានវប្បធម៌ ត្រូវបានអនុវត្តក្នុងគោលបំណងរក្សាអត្តសញ្ញាណរមណីយដ្ឋានវប្បធម៌ជាតិ ដើម្បីលើកកម្ពស់វិស័យវប្បធម៌និងទេសចរណ៍។

៥-គម្រោងអភិរក្សផ្សេងៗ ត្រូវបានអនុវត្តក្នុងគោលបំណងបំពេញបន្ថែម និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិរក្សទីក្រុង និងតំបន់ជុំវិញ ដើម្បីធានាបាននូវគុណភាពបរិស្ថានរស់នៅ ទេសភាពធម្មជាតិ អត្តសញ្ញាណប្រវត្តិសាស្ត្រ និងវប្បធម៌ជាតិ។

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំយុទ្ធសាស្ត្រ និងផែនការគម្រោងអភិរក្ស ដោយត្រូវចុះបញ្ជីស្ថាបត្យកម្ម ស្នាដៃស្ថាបត្យកម្ម ទីតាំង ទេសភាព និងការអភិរក្សផ្សេងៗ ស្របតាមគោលការណ៍បច្ចេកទេស ដើម្បីធានាការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព និងមានអត្តសញ្ញាណច្បាស់លាស់។

គោលការណ៍បច្ចេកទេសអភិរក្ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឬ/និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៥២ .-**

គម្រោងសាងសង់ រួមមានការសាងសង់ដែលត្រូវបានស្នើឡើងដោយរូបវន្តបុគ្គលឬនីតិបុគ្គលគ្រប់ប្រភេទនៅលើដីដោយអនុលោមតាមលិខិតអនុញ្ញាតសាងសង់និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**មាត្រា៥៣ .-**

គម្រោងអភិវឌ្ឍក្នុងទីក្រុង ត្រូវគោរពឲ្យបាននូវលក្ខខណ្ឌអប្បបរមានៃបទប្បញ្ញត្តិប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ដូចមានចែងក្នុងជំពូកទី៥និងជំពូកទី៦នៃអនុក្រឹត្យនេះ។

គម្រោងអភិវឌ្ឍក្នុងទីក្រុងដែលពាក់ព័ន្ធនឹងដីរដ្ឋ ត្រូវមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលជាមុនសិន។ រាល់ការងារពាក់ព័ន្ធនឹងផ្នែកបច្ចេកទេសនគរូបនីយកម្មនិងសំណង់នៃគម្រោងអភិវឌ្ឍក្នុងទីក្រុង ត្រូវទទួលបានការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់គម្រោងអភិវឌ្ឍក្នុងទីក្រុងដែលពាក់ព័ន្ធនឹងដីរបស់បុគ្គលឯកជន ត្រូវទទួលការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់គម្រោងអភិវឌ្ឍក្នុងទីក្រុងដែលពាក់ព័ន្ធនឹងប្រព័ន្ធស្ថានីយចម្រោះទឹកកខ្វក់ ទឹកស្អាត អគ្គិសនី ប្រព័ន្ធបង្ហូរទឹកកខ្វក់ បណ្ដាញផ្លូវថ្នល់ ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ។ល។ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងត្រូវមានការចូលរួមយោបល់ពីក្រសួង ឬស្ថាប័នជំនាញពាក់ព័ន្ធ។

**មាត្រា៥៤ .-**

ក្នុងការអនុវត្តគម្រោងអភិវឌ្ឍក្នុងទីក្រុង ម្ចាស់គម្រោងត្រូវទទួលបន្ទុកលើការចំណាយទាំងអស់លើការអភិវឌ្ឍ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈ ចំពោះទីតាំងដីដែលត្រូវធ្វើការកែប្រែប្រភេទដីនៃការប្រើប្រាស់ដីឬមុខងារតំបន់ប្រើប្រាស់ដីជាមុន។ ដោយឡែកចំពោះគម្រោងដែលស្ថិតនៅក្នុងប្រភេទដីអាចសាងសង់បាន អាជ្ញាធរសាធារណៈ ត្រូវទទួលបន្ទុកលើការចំណាយសម្រាប់ការអភិវឌ្ឍ និងការសាងសង់ចាប់ពីមហាវិថីនិងសួនច្បារទីក្រុងឡើងទៅ។ រាល់ការចំណាយចំពោះផ្លូវថ្នល់និងសួនច្បារផ្សេងៗទៀតដែលស្ថិតក្នុងគម្រោងអភិវឌ្ឍក្នុងទីក្រុង ជាបន្ទុករបស់ម្ចាស់គម្រោង។

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈទាំងអស់នៃគម្រោងអភិវឌ្ឍក្នុងទីក្រុង ត្រូវចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ លើកលែងតែផ្លូវច្រកចេញចូល លំហសាធារណៈ សួនច្បារ លំហនៃសេវារួម របងបុរី និងតំបន់ផ្សេងទៀតដែលមានលក្ខណៈជាបុរី ទោះបីមានឈ្មោះអ្វីក៏ដោយ ត្រូវចុះបញ្ជីជាទ្រព្យអវិភាគរបស់កម្មសិទ្ធិករ ដោយអនុលោមតាមស្មារតីនៃអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្ដីពីការគ្រប់គ្រងបុរី។

**មាត្រា៥៥ .-**

នីតិវិធីនៃការអនុវត្តគម្រោងអភិវឌ្ឍក្នុងទីក្រុងនិងគម្រោងអភិរក្សក្នុងទីក្រុងនិងការសាងសង់ទីក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៨
## ការគ្រប់គ្រងការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង និងការសាងសង់ទីក្រុង

**មាត្រា៥៦ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងកិច្ចការនគរូបនីយកម្ម និងសំណង់ ដើម្បីធានាបាននូវការអភិវឌ្ឍ និងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព សមធម៌ សុខដុមនីយកម្ម និងសមាហរណកម្ម។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើប្រតិភូកម្មការគ្រប់គ្រងកិច្ចការបច្ចេកទេសនគរូបនីយកម្មនិងសំណង់ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ទៅតាមតម្រូវការ និងស្ថានភាពសមត្ថភាពស្របតាមបទប្បញ្ញត្តិជាធរមាន។ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់ ជាសេនាធិការផ្ទាល់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះការងារនេះ។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតនៅក្រោមការសម្របសម្រួលរបស់អភិបាលរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា៥៧ .–**

ដើម្បីធានាបាននូវការគ្រប់គ្រងកិច្ចការបច្ចេកទេសនគរូបនីយកម្មនិងសំណង់និងជាគ្រឹះនៃភាពស្របច្បាប់ ការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទ ត្រូវមានស្នើសុំលិខិតអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់និង/ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច។ ការអភិវឌ្ឍអចលនវត្ថុដែលត្រូវមានលិខិតអនុញ្ញាតរួមមាន៖

១- ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការពង្រីកអគារ និងការសង់បន្ថែមពីលើអគារដែលមានស្រាប់ ការប្តូរមុខងារប្រើប្រាស់អគារ ការប្តូរទ្រង់ទ្រាយអគារ ការបង្កើនផ្ទៃក្រឡាកម្រាលសំណង់ និងការកែប្រែទិដ្ឋភាពខាងក្រៅនៃអគារដែលមានស្រាប់ ការជួសជុល និងរុះរើ។

២- ការសាងសង់ឬការប្តូរទ្រង់ទ្រាយអគារដែលអាចបង្កគ្រោះថ្នាក់អគ្គិភ័យ ដូចជា ការដាក់ស៊ីទែន កន្លែងស្តុកផលិតផលតេលសិលា រោងជាងផលិតគ្រឿងផ្ទុះ។ល។

៣- ការដាក់ស្លាកសញ្ញាផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍និងទូរគមនាគមន៍ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ក៏ដូចជាការដាក់រចនាសម្ព័ន្ធនៅលើដីនិងអគារ។

៤- ការអភិវឌ្ឍដី (ការកែប្រែរចនាសម្ព័ន្ធដើមនៃដី ការចាក់ដីបំពេញ ការជីកយកដីចេញ ការបង្រួមក្បាលដី ការបំបែកក្បាលដី ការប្តូរប្រភេទនៃការប្រើប្រាស់ដី និងការប្តូរមុខងារតំបន់ប្រើប្រាស់ដី។ល។)។

៥- គម្រោងអភិវឌ្ឍទីក្រុង ដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។

៦- ការផ្លាស់ប្តូរលក្ខណៈគតិយុត្តផ្សេងៗទៀត មានជាអាទិ៍ ការពន្យារសុពលភាពនៃលិខិតអនុញ្ញាតដែលហួសសុពលភាព ការផ្ទេរឈ្មោះក្នុងលិខិតអនុញ្ញាត។ល។

ដើម្បីឲ្យប្រជាពលរដ្ឋមានភាពងាយស្រួល ការសាងសង់ថ្មីឬការជួសជុលលំនៅឋានតូចតាច និងពុំមានលក្ខណៈជាការធ្វើពាណិជ្ជកម្មមិនតម្រូវឲ្យស្នើសុំលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋាន និងបិទការដ្ឋានឡើយ ហើយដែលត្រូវកំណត់នៅក្នុងអនុក្រឹត្យដោយឡែក។

**មាត្រា៥៨ .–**

សំណុំលិខិតស្នើសុំការអនុញ្ញាតអភិវឌ្ឍអចលនវត្ថុទាំងអស់ ត្រូវសរសេរជាភាសាខ្មែរដែលជាភាសាផ្លូវការ។ ភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាបរទេសផ្សេងទៀត អាចសរសេរនៅខាងក្រោមភាសាខ្មែរ ដែលមានទំហំអក្សរតូចជាងភាសាខ្មែរ។ សំណុំលិខិតស្នើសុំការអភិវឌ្ឍអចលនវត្ថុ ត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេលកំណត់មួយមុនការសម្រេចផ្តល់លិខិតអនុញ្ញាតជូន ដើម្បីទទួលបណ្តឹងតវ៉ានិងធានាទប់ស្កាត់ទំនាស់នៃការប្រើប្រាស់ដី

នីតិវិធីនិងសំណុំឯកសារសម្រាប់ការស្នើសុំការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និង/ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៥៩ .–**

រូបវន្តនិងនីតិបុគ្គលដែលធ្វើអាជីវកម្មលើសេវាបច្ចេកទេស ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែចុះបញ្ជីនិងទទួលការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

នីតិវិធីនិងលក្ខខណ្ឌនៃការវាយតម្លៃនិងការចុះបញ្ជីរូបវន្តបុគ្គលឬនីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្មលើសេវាបច្ចេកទេស ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់

សម្រាប់ការអភិវឌ្ឍដី ការអភិរក្ស និងការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦០ .-**

លិខិតអនុញ្ញាតការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវគោរពតាមផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ដែលបានអនុម័តដាក់ឲ្យប្រើប្រាស់ជាផ្លូវការរួច។

ក្នុងករណីពុំទាន់មានផែនការរៀបចំដែនដី ប្លង់គោលនិងផែនការប្រើប្រាស់ដី ដែលបានអនុម័តដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ការផ្ដល់លិខិតអនុញ្ញាតការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យនេះនិងបទដ្ឋានបច្ចេកទេសនគរូបនីយកម្មនិងសំណង់ពាក់ព័ន្ធ ដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

បទប្បញ្ញត្តិបច្ចេកទេសលម្អិតសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

**មាត្រា៦១ .-**

គោលការណ៍ យន្តការ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតសាងសង់ជួសជុលនិងរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី៩
## អធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ

**មាត្រា៦២ .-**

មន្ត្រីមានសមត្ថកិច្ចដែលចុះធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ ត្រូវអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានគតិយុត្តជាធរមាន ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

**មាត្រា៦៣ .-**

អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ មានសិទ្ធិនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការអភិវឌ្ឍអចលនវត្ថុនិងសុវត្ថិភាពការងារនៅខាងក្នុងនិងជុំវិញបរិវេណការដ្ឋានសំណង់
- តម្រូវឲ្យម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុផ្ដល់ព័ត៌មាននិងបង្ហាញគ្រប់លិខិតដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ
- បញ្ជាឲ្យកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ផ្អាកការដ្ឋានសាងសង់ជាបណ្ដោះអាសន្ន
- ដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- ហាមឃាត់ជាបណ្ដោះអាសន្ននូវការប្រើប្រាស់អគារឬការធ្វើអាជីវកម្មលើអគារ
- បំពេញភារកិច្ចផ្សេងទៀតដែលបានប្រគល់ជូនដោយអាជ្ញាធរជម្មានុរូប។

**មាត្រា៦៤ .-**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលមិនសុខចិត្តចំពោះវិធានការបញ្ជាឲ្យកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ ផ្អាកការដ្ឋានសាងសង់ជាបណ្ដោះអាសន្ន ឃាត់ទុកជាបណ្ដោះអាសន្ននូវសម្ភារៈ ឧបករណ៍ គ្រឿងចក្រ មធ្យោបាយផ្សេងៗដែលមាននៅក្នុងការដ្ឋានសាងសង់ ដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ ហាមឃាត់ជាបណ្ដោះអាសន្ននូវការ

ប្រើប្រាស់អគារ ឬការធ្វើអាជីវកម្មលើអគាររបស់អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ អាចធ្វើបណ្តឹងតវ៉ាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចខាងលើ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០
## ទណ្ឌកម្ម

**មាត្រា៦៥ .-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះ រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការដកហូតលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន
- ការព្យួរ ការដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- ការបង្ខំឲ្យរុះរើនិងស្តាបនាឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ
- ការពិន័យអន្តរការណ៍។

**មាត្រា៦៦ .-**

ទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា៦៦ខាងលើ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធរមានសមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតអភិវឌ្ឍ លិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ លិខិតបើកនិងបិទការដ្ឋាន។

**មាត្រា៦៧ .-**

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យ ចំពោះអំពើល្មើសដូចមានចែងខាងលើត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរំលត់បណ្តឹងអាជ្ញា។

**មាត្រា៦៨ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចចេញលិខិតព្រមានចំពោះម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ក្នុងករណីដែលមានកំហុសមិនធ្ងន់ធ្ងរក្នុងការអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៦៩ ._**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលធ្វើការអភិវឌ្ឍអចលនវត្ថុដោយគ្មានលិខិតអនុញ្ញាតអភិវឌ្ឍឬសាងសង់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៨០ ០០០(ប្រាំបីម៉ឺន)រៀល សម្រាប់ផ្ទៃក្រឡា១ម៉ែត្រក្រឡានៃផ្ទៃក្រឡាសំណង់ដែលបានសាងសង់រួច ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៤០ ០០០(បួនម៉ឺន)រៀល សម្រាប់ផ្ទៃក្រឡា១ម៉ែត្រក្រឡានៃផ្ទៃក្រឡាសំណង់ដែលបានសាង សង់រួច ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០ ០០០(ពីរម៉ឺន)រៀល សម្រាប់ផ្ទៃក្រឡា១ម៉ែត្រក្រឡានៃផ្ទៃក្រឡាសំណង់ដែលបានសាងសង់រួច ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

បន្ថែមលើការពិន័យអន្តរការណ៍ខាងលើនេះ ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់ ដើម្បីឲ្យសំណង់ស្របច្បាប់ ដោយកែសម្រួលតាមបទដ្ឋានបច្ចេកទេស។

ករណីកំហុសធ្ងន់ធ្ងរប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងភាពសុខដុមនីយកម្មនៃតំបន់ឬអចលនទ្រព្យជិតខាង ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុត្រូវធ្វើការកែតម្រូវ ឬអាចត្រូវបង្ខំឲ្យរុះរើចេញទាំងស្រុង ដោយម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុទទួលបន្ទុកលើការចំណាយទាំងអស់។

**មាត្រា៧០ ._**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍដែលធ្វើការអភិវឌ្ឍអចលនវត្ថុដោយខុសពីលិខិតអនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុង០១ម៉ែត្រក្រឡានៃផ្ទៃក្រឡាដែលលើសពីលិខិតអនុញ្ញាតសាងសង់
- ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុងកម្ពស់១ម៉ែត្រដែលលើសនិងចំនួន១០ ០០០(មួយម៉ឺន)រៀលក្នុង១ម៉ែត្រគូបនៃមាឌអគារដែលលើសពីលិខិតអនុញ្ញាតសាងសង់
- ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុងផ្លាគម្លាត១០សង់ទីម៉ែត្រដែលលើស ក្នុងករណីកំហុសដែលខុសផ្លាគម្លាតពីព្រំដីមកអគារពីលិខិតអនុញ្ញាត និង១០ ០០០(មួយម៉ឺន)រៀល ក្នុង១ម៉ែត្រគូបនៃមាឌអគារដែលលើសទាំងអស់ ដោយសារលើសគម្លាត។

បន្ថែមលើការពិន័យអន្តរការណ៍ខាងលើនេះ ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាត ដើម្បីឲ្យសំណង់ស្របច្បាប់ ដោយកែសម្រួលតាមបទដ្ឋានបច្ចេកទេស។

ករណីកំហុសធ្ងន់ធ្ងរប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងភាពសុខដុមនីយកម្មនៃតំបន់ ឬអចលនទ្រព្យជិតខាង ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុត្រូវធ្វើការកែតម្រូវ ឬអាចត្រូវបង្ខំឲ្យរុះរើ ដោយម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុទទួលបន្ទុកលើការចំណាយទាំងអស់។

**មាត្រា៧១ ._**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុឬសាងសង់ ដោយគ្មានលិខិតអនុញ្ញាតបើកការដ្ឋានត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៥០០ ០០០(ប្រាំសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ១០០ ០០០(មួយសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយ ឬច្រើន ដូចខាងក្រោម៖

- ដកហូតលិខិតអនុញ្ញាតសាងសង់
- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- បង្ខំឲ្យរុះរើនិងស្ដាបនាឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ។

**មាត្រា៧២ .-**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុដោយគ្មានលិខិតបិទការដ្ឋានត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៥០០ ០០០(ប្រាំសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ១០០ ០០០(មួយសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ។

**មាត្រា៧៣ .-**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុ ដោយប្រើប្រាស់លិខិតអនុញ្ញាតហួសសុពលភាព ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៥០០ ០០០(ប្រាំសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ១០០ ០០០(មួយសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- បង្ខំឲ្យរុះរើនិងស្ដាបនាឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ។

**មាត្រា៧៤ .-**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែល៖

ក. មិនព្រមបញ្ឈប់ការដ្ឋានសាងសង់តាមបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ចឬមិនប្រើប្រាស់សិទ្ធិប្ដឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៦៥នៃអនុក្រឹត្យនេះ ឬ

ខ. រារាំងឬប្រកែកមិនព្រមឲ្យសមត្ថកិច្ចជំនាញចូលត្រួតពិនិត្យការដ្ឋានសាងសង់ ឬ

គ. ប្រកែកមិនព្រមផ្ដល់ព័ត៌មានឬបង្ហាញលិខិតដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុដល់សមត្ថកិច្ចជំនាញក្នុងពេលចុះពិនិត្យការដ្ឋានសំណង់ ឬ

ឃ. ប្រើប្រាស់មធ្យោបាយណាមួយដើម្បីជាឧបសគ្គដល់ការត្រួតពិនិត្យការដ្ឋានសំណង់របស់អង្គភាពជំនាញមានសមត្ថកិច្ច។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ២ ០០០ ០០០(ពីរលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០០ ០០០(ពីរសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ដកហូតលិខិតអនុញ្ញាតសាងសង់

- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ឬវិញ្ញាបនបត្រអភិវឌ្ឍអចលនវត្ថុ
- បង្ខំឲ្យរុះរើនិងស្ដាបនាឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ។

**មាត្រា៧៥ .-**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុ ដែលបានធ្វើការផ្ទេរលិខិតអនុញ្ញាតសាងសង់ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ២ ០០០ ០០០(ពីរលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០០ ០០០(ពីរសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ដកហូតលិខិតអនុញ្ញាតសាងសង់
- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់។

**មាត្រា៧៦ .-**

ក្រុមហ៊ុនសាងសង់ដែលធ្វើអាជីវកម្មម៉ៅការសាងសង់ ដែលមានវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ផុតសុពលភាពត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត១
- ៤ ០០០ ០០០(បួនលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត២
- ៣ ០០០ ០០០(បីលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត៣។

**មាត្រា៧៧ .-**

ការបង្កឲ្យខូចខាត ប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ ព្រមទាំងសុខដុមនីយកម្មនៃតំបន់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត១
- ៤ ០០០ ០០០(បួនលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត២
- ៣ ០០០ ០០០(បីលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត៣។

ក្រុមហ៊ុនសាងសង់អាចទទួលរងបន្ថែមនូវទណ្ឌកម្មព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់។

ចាត់ទុកជាការបង្កឲ្យខូចខាត ប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ ព្រមទាំងសុខដុមនីយកម្មនៃតំបន់ នូវករណីដូចខាងក្រោម៖

- ការដ្ឋានសាងសង់ ជួសជុល ឬរុះរើដែលគ្មានរបងហ៊ុមព័ទ្ធ គ្មានសំណាញ់ការពារសុវត្ថិភាពបង្កសំឡេងរំខាន និងគ្មានប៉ាន់ណូសម្រាប់សំគាល់ការដ្ឋានសាងសង់
- ការដ្ឋានសាងសង់ពុំមានឧបករណ៍ការពារសុវត្ថិភាពគ្រប់គ្រាន់ដល់បុគ្គលិក អ្នកបច្ចេកទេសគ្រប់គ្រងការដ្ឋាន និងកម្មករ
- ការបំពុលបង្កឡើងពីការដ្ឋានសាងសង់ ជួសជុល ឬរុះរើ និងការបំពុលបណ្ដាលមកពីការធ្វេសប្រហែសធ្វើឲ្យផ្ទុះធ្លាយឃ្លាំងស្តុកឧទង្គារនិងអាងប្រេងឥន្ធនៈ
- ការដ្ឋានសាងសង់ដែលប្រើគ្រឿងចក្រ បរិក្ខារលើកស្ទូច ហើយធ្វើឲ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ឬមិនបានបំពាក់ភ្លើងសញ្ញាសំគាល់នៅពេលយប់។

- ការបង្ហូរទឹកបេតុងពីរថយន្តដឹកបេតុងឬពីរថយន្តបូមបេតុង និងទឹកស៊ីម៉ងត៍ដែលបានបង្ហូរចេញពីការដ្ឋានសាងសង់លើចិញ្ចើមផ្លូវថ្នល់ លូសាធារណៈ និងទីតាំងសាធារណៈ
- ការដ្ឋានសាងសង់ដែលគ្មានអ្នកបច្ចេកទេស ឬវិស្វករ ឬស្ថាបត្យករ ជាអ្នកគ្រប់គ្រងនិងទទួលខុសត្រូវ
- ខកខានមិនបានរុះរើ សំអាតនិងអនុវត្តតាមសេចក្ដីជូនដំណឹងរបស់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៧៨ .-**

ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ដែលមានវិញ្ញាបនបត្រប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ផុតសុពលភាព ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត១
- ៤ ០០០ ០០០(បួនលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត២
- ៣ ០០០ ០០០(បីលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត៣។

**មាត្រា៧៩ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការនិងអាចសុំឲ្យរឹបអូសសម្ភារៈ បរិក្ខារ ឧបករណ៍ផ្សេងៗទៀត ដោយអនុលោមតាមនីតិវិធីជាធរមាន ក្នុងករណីបុគ្គលដែលត្រូវទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មិនព្រមអនុវត្តតាមសេចក្ដីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៨០ .-**

មន្ត្រីមានសមត្ថកិច្ចណាដែលប្រកែកមិនព្រមទទួលពិនិត្យលើសំណុំលិខិតស្នើសុំការអនុញ្ញាតសាងសង់ ជួសជុល រុះរើ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ដោយគ្មានមូលហេតុត្រឹមត្រូវដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ ប្រសិនបើមាន។

សមត្ថកិច្ចជំនាញនគរូបនីយកម្មនិងសំណង់ឬមន្ត្រីដែលមានភារកិច្ចចុះត្រួតពិនិត្យការដ្ឋានសំណង់ ដែលពុំបានជំទាស់ទៅលើការអភិវឌ្ឍអចលនវត្ថុដែលមិនស្របទៅនឹងលិខិតអនុញ្ញាតសាងសង់ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌប្រសិនបើមាន។

ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល ចំពោះមន្ត្រីជំនាញណាដែលចុះទៅត្រួតពិនិត្យការដ្ឋានសាងសង់ ជួសជុល ឬរុះរើ ដោយគ្មានលិខិតបញ្ជាបេសកកម្ម។

## ជំពូកទី១១
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៨១ .-**

រាល់ការផ្ដល់លិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ ការចេញវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវផ្នែកនគរូបនីយកម្ម និងសំណង់ ការចេញលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ការចេញលិខិតបិទការដ្ឋានសាងសង់ និងការផ្ដល់លិខិតអនុញ្ញាតគោលការណ៍បច្ចេកទេសលើការអភិវឌ្ឍអចលនវត្ថុនិងការសាងសង់ សេវាបច្ចេកទេសសាងសង់ ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់ ត្រូវតែបង់កម្រៃសេវានគរូបនីយកម្ម និងសំណង់។

ការគណនាតម្លៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវឈរលើមូលដ្ឋាននៃទំហំផ្ទៃក្រឡាដី ទំហំផ្ទៃក្រឡាសំណង់ និងសន្ទស្សន៍ប្រើប្រាស់ដី និងសំណង់នៃគម្រោងទាំងមូល។

តម្លៃសោហ៊ុយសេវានិងមូលដ្ឋានសម្រាប់គណនា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៨២ .-**

ចំណូលកម្រៃសេវាដូចមានចែងក្នុងមាត្រា៦១ខាងលើនេះ ត្រូវបែងចែកមួយផ្នែកចូលថវិការដ្ឋ មួយផ្នែកសម្រាប់គាំទ្រការងារបច្ចេកទេសនគរូបនីយកម្មនិងសំណង់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង មួយផ្នែកទៀតសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

ការបែងចែកចំណូលបានមកពីកម្រៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា៨៣ .-**

ការប្រើប្រាស់ដីឬអគារដែលកើតមានមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបានអនុញ្ញាតឲ្យបន្តការប្រើប្រាស់តាមលក្ខខណ្ឌមានស្រាប់នាពេលបច្ចុប្បន្ន ក្នុងករណីដែលមិនបង្កគ្រោះថ្នាក់ឬមហន្តរាយដល់សុខុមាលភាពសាធារណៈ សុវត្ថិភាពសាធារណៈ បរិស្ថាន ប្រវត្តិសាស្ត្រ និងវប្បធម៌។

**មាត្រា៨៤ .-**

លក្ខខណ្ឌដែលមានចែងក្នុងអនុក្រឹត្យនេះនឹងត្រូវយកទៅអនុវត្តចំពោះតែប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្មដែលបានរៀបចំក្រោយពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

ចំពោះប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម ដែលកំពុងដំណើរការរៀបចំនិងបានរៀបចំហើយ ប៉ុន្តែមិនទាន់បានអនុម័តដាក់ឲ្យប្រើប្រាស់ ត្រូវបានអនុញ្ញាតឲ្យបន្តរៀបចំបញ្ចប់និងដាក់ស្នើសុំការអនុម័តឲ្យប្រើប្រាស់ជាផ្លូវការ ជាប្លង់បឋមដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវខិតខំជំរុញការរៀបចំបន្តបញ្ចប់ និងដាក់ស្នើសុំការអនុម័ត ឲ្យប្រើប្រាស់ជាផ្លូវការនូវប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូប-នីយកម្ម នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

ចំពោះគម្រោងអភិវឌ្ឍអចលនវត្ថុនិងសាងសង់ដែលបានដាក់ស្នើសុំលិខិតអនុញ្ញាតមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តនីតិវិធីស្នើសុំ ដោយអនុលោមតាមនីតិវិធីដែលបានធ្វើពីមុន។

ចំពោះគម្រោងអភិវឌ្ឍអចលនវត្ថុនិងសាងសង់ដែលកំពុងដំណើរការអភិវឌ្ឍនិងសាងសង់មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តដំណើរការសាងសង់ ស្របតាមលិខិតអនុញ្ញាតដែលបានចេញជូនម្ចាស់សំណើ។

លិខិតអនុញ្ញាតឲ្យអភិវឌ្ឍអចលនវត្ថុ ដែលបានចេញជូនម្ចាស់សំណើមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តសុពលភាពអនុវត្តរហូតដល់អស់សុពលភាព។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា៨៥ .-**

បទប្បញ្ញត្តិដែលមានអានុភាពនៅពេលដែលអនុក្រឹត្យត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងអនុក្រឹត្យនេះ។

**មាត្រា៨៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥
ស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន

## សន្ទានុក្រម

**ការអភិវឌ្ឍដី** សំដៅដល់ការប្ដូរប្រភេទនៃការប្រើប្រាស់ដីទៅជាប្រភេទមួយផ្សេងទៀត តាមរយៈការបង្រួមក្បាលដី ការបំបែកក្បាលដី ការកែទម្រង់ដី និងការបង្កើនដង់ស៊ីតេនៃការប្រើប្រាស់ដី សម្រាប់គោលដៅនៃការសាងសង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

**ការបង្រួមក្បាលដី** សំដៅដល់ការបញ្ចូលក្បាលដីច្រើនដែលជាប់គ្នាឲ្យក្លាយទៅជាក្បាលដីតែមួយ ដើម្បីធ្វើផែនការអភិវឌ្ឍទីក្រុង សម្រាប់ធ្វើសមាហរណកម្មនិងធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សេវាសាធារណៈ សំដៅធានាចីរភាព សមធម៌ តុល្យភាព សុខភាព និងភាពងាយស្រួលនៃទីក្រុង។

**ការបំបែកក្បាលដី** សំដៅដល់ការបំបែកក្បាលដីតែមួយទៅជាក្បាលដីច្រើន សម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

**ការកែសម្រួលក្បាលដី** សំដៅដល់ការរៀបចំក្បាលដីឡើងវិញដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួម ព្រមទាំងបង្កើនលទ្ធភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការប្ដូរប្រភេទនៃការប្រើប្រាស់ដី** សំដៅដល់ការផ្លាស់ប្ដូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**តំបន់លំនៅឋានដាច់គ្នាកម្ពស់ទាប** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដាច់ពីគ្នា ឬជាប់គ្នាមួយចំហៀងដែលមានកម្ពស់ទាប ដូចជា ភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះក្នុងដីឡូត៍ដែលមានធ្លាគម្លាតជុំវិញ អគារស្នាក់នៅ អាគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានជញ្ជាំងជាប់គ្នាដែលមានកម្ពស់ទាប ដូចជា ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំនៅឋានកម្ពស់មធ្យម** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់មធ្យម ដូចជា ភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំនៅឋានកម្ពស់ខ្ពស់** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ ដូចជា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់លំនៅឋានចម្រុះ៖ សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានច្រើនប្រភេទ ដូចជា លំនៅឋានជាប់គ្នា លំនៅឋានពាក់កណ្តាលជាប់គ្នា លំនៅឋានដាច់ពីគ្នា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ពាណិជ្ជកម្ម សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យពាណិជ្ជកម្ម ធុរកិច្ច និងសេវាកម្មនានា ដូចជាអគារការិយាល័យ ធនាគារ រោងកុន រោងល្ខោន ភោជនីយដ្ឋាន សណ្ឋាគារ ហាងលក់ដូរ ទីផ្សារ និងដេប៉ូចែកចាយទំនិញ។ល។ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ពាណិជ្ជកម្មចម្រុះ៖ សំដៅដល់តំបន់ដែលមានមុខងារពាណិជ្ជកម្ម សម្រាប់បម្រើដល់លំនៅឋាននិងការស្នាក់នៅ មានដូចជាហាងលក់ដូរនិងទីផ្សារតូចៗដែលលក់ដូរទំនិញនិងសេវាកម្ម ដើម្បីផ្គត់ផ្គង់និងគាំទ្រដល់ការរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានប្រចាំថ្ងៃ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ឧស្សាហកម្ម សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតធំដែលមានជាតិពុលខ្ពស់ ដូចជារោងចក្រ រោងសិប្បកម្មខ្នាតធំ ឃ្លាំង យានដ្ឋាន ។ល។ ហើយមិនអនុញ្ញាតឲ្យសាងសង់លំនៅឋាននៅតំបន់នេះឡើយ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ឧស្សាហកម្មស្រាល សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតតូចដែលមានជាតិពុលតិច ឬ មធ្យម ដូចជារោងចក្រ រោងសិប្បកម្មខ្នាតតូច ឃ្លាំង យានដ្ឋាន។ល។ ហើយអាចអនុញ្ញាតឲ្យសាងសង់លំនៅឋាននៅតំបន់នេះបាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ឧស្សាហកម្មចម្រុះ៖ សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មនិងសេវាកម្ម។ គ្រប់អគាររោងចក្រទាំងអស់ត្រូវបានអនុញ្ញាតឲ្យសាងសង់ លើកលែងតែអគារដែលមានផលប៉ះពាល់បរិស្ថានខ្ពស់។ តំបន់នេះអាចអនុញ្ញាតឲ្យមានលំនៅឋាននិងអគារពាណិជ្ជកម្ម ដូចជា សាលារៀន មន្ទីរពេទ្យ សាកលវិទ្យាល័យ ភោជនីយដ្ឋាន រោងកុន ឃ្លាំង យានដ្ឋាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ចម្រុះ៖ សំដៅដល់តំបន់ដែលអាចប្រើប្រាស់ពហុមុខងារ សម្រាប់លំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្ម ដោយធានាបានបរិស្ថានរស់នៅ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ដឹកជញ្ជូន សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់អគារហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មបម្រើដល់វិស័យដឹកជញ្ជូននិងគមនាគមន៍ជាអាទិ៍ ស្ថានីយរថភ្លើង ព្រលានយន្តហោះ ស្ថានីយរថយន្ត កំពង់ចម្លង កំពង់ផ កំពង់ផែ ផែស្ងួត ឃ្លាំង មជ្ឈមណ្ឌលចែកចាយទំនិញ និងអគារឧស្សាហកម្ម មជ្ឈមណ្ឌលទូរគមនាគមន៍។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដី កំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ទេសចរណ៍** សំដៅតំបន់សម្រាប់សាងសង់អគារបម្រើដល់វិស័យទេសចរណ៍ និងកម្សាន្ត រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងកម្សាន្ត។ល។

**តំបន់រដ្ឋបាលនិងសេវាសាធារណៈ** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យរដ្ឋបាលនិងសេវាសាធារណៈ ដូចជាទីស្តីការក្រសួង ស្ថាប័ន មន្ទីរ អង្គភាព សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលំហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់ សម្រាប់បម្រើដល់សាធារណជន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់វប្បធម៌និងសាសនា** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ ដែលបម្រើដល់វិស័យប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងសាសនា ដូចជា ប្រាសាទ វត្តអារាម វិហារសាសនា សាលារៀន សារមន្ទីរ ទីលានកីឡា កន្លែងសិប្បកម្មចម្លាក់ សាលាឆទាន ពុទ្ធិកសាកលវិទ្យាល័យ។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់កសិកម្ម** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់វិស័យកសិកម្ម ដូចជាវាលស្រែ ចម្ការ សួនបន្លែ កសិដ្ឋានចិញ្ចឹមសត្វ ថ្នាលបណ្តុះកូនឈើ កន្លែងចិញ្ចឹមត្រី បង្គារ ក្តាម សិប្បកម្មបម្រើដល់កសិកម្ម ។ល។ តំបន់នេះអាចសាងសង់លំនៅឋានរបស់កសិករ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ព្រៃឈើ** សំដៅដល់តំបន់ផ្ទៃព្រៃឈើនិងគម្របព្រៃឈើ ដែលត្រូវការពារ ថែរក្សា និងដាំបន្ថែម ដូចជាព្រៃស្រោង ព្រៃរបោះ ព្រៃការពារ ព្រៃអភិរក្ស ព្រៃលិចទឹក។ល។

**តំបន់ធនធានទឹក** សំដៅដល់តំបន់ផ្ទៃទឹកនិងប្រភពទឹកដែលត្រូវថែរក្សានិងការពារ ដូចជាសមុទ្រ ទន្លេ ព្រែក ស្ទឹង អូរ ប្រឡាយ បឹង ទំនប់ សំណង់ធារាសាស្ត្រ។ល។

**តំបន់ការពារ** សំដៅដល់តំបន់ធម្មជាតិនិងទស្សនីយភាពដែលត្រូវការពារ ដើម្បីបម្រើឲ្យវិស័យបរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ ការអប់រំ និងការកម្សាន្ត ដូចជាឆ្នេរសមុទ្រ ចំណីទន្លេ ភ្នំឧទ្យានជាតិ តំបន់ដីសើម តំបន់ជីវចម្រុះ។ល។

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី(ប្រភេទដីអាចសាងសង់បាន និង ប្រភេទដីកម្រិតការសាងសង់)ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់ មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាព សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវ បានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុងឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយឬ ច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំ ការរចនាទម្រង់ រូបរាង និងសោភណភាព នៃរចនា សម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិត នគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ប្លង់ទ្រេត** សំដៅដល់ប្លង់សម្រាប់កំណត់កម្ពស់អតិបរមានៃសំណង់។ ប្លង់នេះត្រូវបានកំណត់ឡើងដោយ សមាមាត្រនៃទំហំទទឹងផ្លូវនិងការថយថ្លាគម្លាតនៃអគារជាមួយនឹងកម្ពស់អគារដើម្បីធានាឲ្យមានចរន្ត ពន្លឺ ចរន្តខ្យល់ និងបរិស្ថានរស់នៅល្អពីអគារមួយទៅអគារមួយទៀត ព្រមទាំងធានាភាពសុខដុមនីយកម្ម នៃស្ថាបត្យកម្មក្នុងតំបន់ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឲ្យមានការអភិវឌ្ឍនិងការសាងសង់លើ គ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់ លំហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិ សាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដី នេះ ត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេង ៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

**បទដ្ឋានទំហំដីឡូត៍បច្ចេកទេស** សំដៅដល់ទំហំដីឡូត៍ដែលកំណត់ដោយប្រវែងក្បាលដីនិងជម្រៅដី ហើយត្រូវ បានកំណត់ឡើង ដើម្បីធានាការរៀបចំ ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធ និងការអភិវឌ្ឍដី ឲ្យមានសោភណភាព មានសណ្តាប់ធ្នាប់។

**ផែនការរូបវន្តទីក្រុង** សំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីធានាការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ក្នុងទីក្រុងឲ្យមានចីរភាព តុល្យភាព សុខុមាលភាព សោភណភាព និងសមធម៌។ ផែនការរូបវន្តទីក្រុង មានប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល ផែនការ ប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ ដីតំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដី និងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើ

សមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

**ម្ចាស់សំណង់** សំដៅដល់ម្ចាស់សិទ្ធិលើអគារឬសំណង់។

**ដង់ស៊ីតេប្រជាជន** សំដៅដល់អនុបាតរវាងចំនួនប្រជាជននិងផ្ទៃក្រឡាដី ក្នុងវិសាលភាពជាក់លាក់ណាមួយ។

**សំណង់សិល្បការ្យ** សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងទៀត ដែលផ្តល់នូវសុវត្ថិភាព ប្រសិទ្ធភាព និងស្ថិរភាពដល់ផ្លូវថ្នល់។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ ដែលសំណង់នោះតាំងនៅ។

**ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ ដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ ស្របតាមសមត្ថកិច្ច។

**មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

# ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ:...០៤១...សសរ.....

# សេចក្តីសម្រេច

# ស្តីពី

# នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-យោងតាមការចាំបាច់របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

សេចក្តីសម្រេចនេះមានគោលបំណងធានាគុណភាពនិងប្រសិទ្ធភាពនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

សេចក្តីសម្រេចនេះ មានគោលដៅកំណត់គោលការណ៍និងនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៣.-**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ ព្រមទាំងដីរបស់បុគ្គលឯកជននៅក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

វាក្យស័ព្ទមួយចំនួនដែលប្រើក្នុងសេចក្តីសម្រេចនេះ មានន័យដូចតទៅ៖

- **ប្លង់គោលប្រើប្រាស់ដី** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសសម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់អំពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍សំខាន់ៗនៃក្រុង ស្រុក ខណ្ឌ និងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ និងតំបន់ជុំវិញ។ ប្លង់គោលប្រើប្រាស់ដី ត្រូវភ្ជាប់ជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍ និងអភិរក្សក្រុង ស្រុក ខណ្ឌ ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យមនិងវែង។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។
- **ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដី ដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ជានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍ និងការអភិរក្សក្នុងតំបន់នីមួយៗ។ ផែនការប្រើប្រាស់ដីបង្ហាញនូវបណ្តាញគមនាគមន៍ និងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ និងតំបន់ជុំវិញ។ ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។
- **ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើននៃក្រុង ស្រុក ខណ្ឌ ដូចជា ការបង្ហាញអំពីការរៀបចំ ការរចនា ទម្រង់ រូបរាង និងសោភណភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការស្តារឡើងវិញតាមរយៈគំនូរ ឬរូបសំណាក។

- **ចក្ខុវិស័យ** សំដៅដល់ការប្រមើលមើលទៅមុខក្នុងការរៀបចំក្រុង ស្រុក ខណ្ឌទៅអនាគតស្របតាមសក្តានុពលនិងស្ថានភាពជាក់ស្តែងនៃក្រុង ស្រុក ខណ្ឌ (ឧទាហរណ៍ កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ដឹកជញ្ជូន...)។
- **យុទ្ធសាស្ត្រ** សំដៅដល់វិធីសាស្ត្រ ឬ មធ្យោបាយក្នុងការធ្វើឲ្យសម្រេចបាននូវចក្ខុវិស័យខាងលើ។ ចក្ខុវិស័យនិងយុទ្ធសាស្ត្រអាចមានច្រើនទៅតាមសក្តានុពលជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌផ្ទាល់។
- **ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានជាអាទិ៍ បណ្តាញផ្លូវសាធារណៈ បរិក្ខារសាធារណៈ (ប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍...) ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ (ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម អាងប្រព្រឹត្តកម្មទឹកកខ្វក់...) ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យនិងហានិភ័យផ្សេងៗ។ល។
- **សំណង់សម្រាប់ផ្តល់សេវាជូនសាធារណជន** មានជាអាទិ៍ អគាររដ្ឋបាល អគារសិក្សា មន្ទីរពេទ្យ ស្ថានីយរថយន្ត ស្ថានីយរថភ្លើង ព្រលានយន្តហោះ កំពង់ផែ។ល។
- **លំហសាធារណៈ** សំដៅដល់សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា ទីលានកម្សាន្ត។ល។
- **ផែនការរូបវន្ត** សំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីធានាការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់នៅក្នុងក្រុង ស្រុក ខណ្ឌ ឲ្យមានចីរភាព តុល្យភាព សុខុមាលភាព សុខភាព សោភណភាពនិងសមធម៌។ ផែនការរូបវន្តក្រុង ស្រុក ខណ្ឌ មានប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។
- **ទិន្នន័យបឋម** សំដៅដល់ទិន្នន័យដែលបានមកតាមរយៈការចុះទៅធ្វើសម្រង់ផ្ទាល់លើទីតាំងជាក់ស្តែង ការចុះវាស់វែងនិងការជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធ ស្របតាមតម្រូវការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី។
- **ទិន្នន័យទី២** សំដៅដល់ទិន្នន័យដែលបានកសាងរួចដោយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ មានជាអាទិ៍ សៀវភៅទិន្នន័យ កម្រងឯកសារទិន្នន័យ របាយការណ៍ពាក់ព័ន្ធ ឯកសារបណ្ណាល័យ បណ្ណាសារ សារព័ត៌មាន ទស្សនាវដ្តី។ល។

## ជំពូកទី២
## គោលការណ៍

**ប្រការ ៥.-**

ការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ
- គោរពតាមឋានានុក្រមនិងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តក្រុង ស្រុក ខណ្ឌជាមូលដ្ឋានបង្អែកសម្រាប់ការអភិវឌ្ឍ ការអភិរក្ស ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការសាងសង់គ្រប់ប្រភេទក្នុងក្រុង ស្រុក ខណ្ឌ រួមទាំងការធ្វើ

សមាហរណកម្ម ដើម្បីធ្វើឲ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានគុណភាពនិងមានសមធម៌

- រួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកលនិងលើកកម្ពស់ការអភិវឌ្ឍបៃតង
- ត្រូវយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរានិងជនងាយរងគ្រោះ។

## ជំពូកទី៣
## យន្តការ សមត្ថកិច្ចនិងភារកិច្ច

**ប្រការ ៦.-**

យន្តការ សមត្ថកិច្ចនិងភារកិច្ច ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៤
## ផែនការរូបវន្តសម្រាប់ក្រុង ស្រុក ខណ្ឌ

**ប្រការ ៧.-**

ផែនការរូបវន្តសម្រាប់ក្រុង ស្រុក ខណ្ឌ រួមមាន៖

- ថ្នាក់ក្រុង មានប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម
- ថ្នាក់ស្រុក ខណ្ឌ មានប្លង់គោលប្រើប្រាស់ដី។

## ផ្នែកទី១
## នីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដី

**ប្រការ ៨.-**

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១.ការប្រមូលនិងវិភាគទិន្នន័យ : ត្រូវប្រមូលនិងវិភាគទិន្នន័យរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ប្រជាសាស្ត្រ និងការស្រង់មតិ។ល។

២.ការកំណត់ចក្ខុវិស័យ : ត្រូវសិក្សានិងកំណត់ចក្ខុវិស័យអភិវឌ្ឍនិងអភិរក្ស សម្រាប់រយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំ។

៣.ការកំណត់យុទ្ធសាស្ត្រ : ត្រូវសិក្សានិងកំណត់យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សដើម្បីសម្រេចបាននូវចក្ខុវិស័យ មានជាអាទិ៍៖

-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្ស

-យុទ្ធសាស្ត្រប្រើប្រាស់ដី

-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

-យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច

-យុទ្ធសាស្ត្រការពារបរិស្ថាន អភិវឌ្ឍបៃតង និងគ្រប់គ្រងកាកសំណល់

-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ។

៤.គំនូសប្លង់សម្រាប់ប្លង់គោលប្រើប្រាស់ដី មានដូចជា៖

៤.១.ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

-ប្លង់បង្ហាញទីតាំង

-ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់កំណត់ប្រភេទប្រើប្រាស់ដី

-ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ

-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង

-ប្លង់និន្នាការនៃការរីករបស់ក្រុង ស្រុក ខណ្ឌ

-ប្លង់គ្រប់គ្រងកាកសំណល់រឹង

-ប្លង់គ្រប់គ្រងកាកសំណល់រាវ

-ប្លង់សរុប។

៤.២.ប្លង់អនាគតកាល ស្របតាមចក្ខុវិស័យ មានដូចជា៖

-ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់បែងចែកប្រភេទប្រើប្រាស់ដី

-ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ

-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង

-ប្លង់គម្រោងពង្រីកក្រុង ស្រុក ខណ្ឌ

-ប្លង់គ្រប់គ្រងកាកសំណល់រឹង

-ប្លង់គ្រប់គ្រងកាកសំណល់រាវ

-ប្លង់សរុប។

៥.សេចក្តីណែនាំអនុវត្តនិងគ្រប់គ្រងការអភិវឌ្ឍ : ត្រូវរៀបចំបញ្ជីគម្រោងនិងផែនការសកម្មភាពតាមលំដាប់អាទិភាពសម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យមនិងរយៈពេលវែង ព្រមទាំងមានសេចក្តីណែនាំសម្រាប់ការអនុវត្តនិងការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់។

៦.ឯកសារឧបសម្ព័ន្ធ។

៧.ឯកសារទាំងអស់ ត្រូវចងក្រងជារបាយការណ៍បច្ចេកទេស។

**ប្រការ ៩.-**

ការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមនិងរៀបចំដោយគណៈកម្មាធិការ

រៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងសម្របសម្រួលដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

នីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

ជំហានទី១. ការផ្សព្វផ្សាយគម្រោងនិងការចុះសិក្សាបឋមលើទីតាំង

ជំហានទី២. ការចុះប្រមូលទិន្នន័យនិងព័ត៌មាន

ជំហានទី៣. ការវិភាគទិន្នន័យនិងការរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រ

ជំហានទី៤. ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី

ជំហានទី៥. ការប្រមូលធាតុចូលនិងការកែសម្រួលបឋម

ជំហានទី៦. ការបិទផ្សាយជាសាធារណៈ

ជំហានទី៧. ការកែសម្រួលចុងក្រោយ

ជំហានទី៨. ការរៀបចំគម្រោងអាទិភាព

ជំហានទី៩. ការសម្រេចលើប្លង់គោលប្រើប្រាស់ដី។

ក្នុងដំណើរការរៀបចំប្លង់គោលប្រើប្រាស់ដី ត្រូវរៀបចំសិក្ខាសាលានៅទីតាំងគម្រោងដើម្បីទទួលធាតុចូលឱ្យបានយ៉ាងតិច៣(បី)លើក ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ ១០.-**

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវស្ថានភាពវិវត្តរបស់ក្រុង ស្រុក ខណ្ឌ ដើម្បីងាយស្រួលក្នុងការរៀបចំជាសេចក្តីព្រាងសំណើប្លង់គោលប្រើប្រាស់ដីសម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈដូចដំណើរការធ្វើប្លង់គោលប្រើប្រាស់ដីថ្មីដែរ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មុនពេលកំណត់នៃរយៈពេល៥ឆ្នាំ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ ឬតម្រូវការចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ប្លង់គោលប្រើប្រាស់ដីដែលត្រូវបានកែសម្រួលរួច ត្រូវស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមនីតិវិធីដូចការសម្រេចប្លង់គោលប្រើប្រាស់ដីថ្មីដែរ។

## ជំហានទី១

## ការផ្សព្វផ្សាយគម្រោងនិងការចុះសិក្សាបឋមលើទីតាំង

**ប្រការ ១១.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផ្សព្វផ្សាយគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ នៅទីតាំងដែលត្រូវអនុវត្តគម្រោងនេះតាមរយៈ៖

- កិច្ចប្រជុំផ្សព្វផ្សាយឬសិក្ខាសាលាផ្សព្វផ្សាយ នៅទីតាំងដែលត្រូវអនុវត្តគម្រោង
- ការបិទផ្សាយគម្រោងនៅទីតាំងដែលត្រូវអនុវត្តគម្រោង
- ប្រព័ន្ធឃោសនានានា ដូចជាតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងបណ្តាញព័ត៌មានវិទ្យាផ្សេងៗ

ការផ្សព្វផ្សាយខាងលើនេះមានសារៈសំខាន់ណាស់ ដើម្បីឲ្យប្រជាពលរដ្ឋនៅទីតាំងនោះយល់ដឹងអំពីផលប្រយោជន៍ដែលខ្លួននឹងត្រូវទទួលបានពីគម្រោងនេះនិងចូលរួមសហការ ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។ តំណាងប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយនេះ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងដល់អ្នកចូលរួមនិងអ្នកពាក់ព័ន្ធ ឲ្យបានយ៉ាងតិច១(មួយ)សប្តាហ៍ មុនកាលបរិច្ឆេទនៃការប្រជុំផ្សព្វផ្សាយ។

**ប្រការ ១២.-**

ការចុះសិក្សាបឋមលើទីតាំង ត្រូវត្រួតពិនិត្យស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន ចរាចរណ៍ ការប្រើប្រាស់ដីនិងសំណង់ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងព័ត៌មានរូបវន្តមួយចំនួនដែលមានស្រាប់ ដើម្បីជាមូលដ្ឋាននិងដាក់ចេញនូវគោលគំនិតសំខាន់ៗក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី នាពេលអនាគត។

អ្នកជំនាញបច្ចេកទេសចូលរួមក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី មានជាអាទិ៍ នគរូបនីយវិទូ ស្ថាបត្យករ អ្នករៀបចំដែនដី វិស្វករ ប្រជាសាស្ត្រវិទូ អ្នកច្បាប់ សង្គមវិទូ ភូមិសាស្ត្រិន បរិស្ថានវិទូ សេដ្ឋកិច្ចវិទូ និងអ្នកជំនាញផ្សេងៗទៀត ដែលមានការពាក់ព័ន្ធ។ល។ អ្នកជំនាញទាំងនេះត្រូវសហការគ្នាលើកឡើងនូវគំនិតច្នៃប្រឌិតខ្ពស់ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី។ អ្នកជំនាញទាំងនេះត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួនស្របតាមវិសាលភាពការងារ ថវិកានិងពេលវេលាដែលបានកំណត់តាមជំហាននីមួយៗ។

ជំហានទី១នេះ មានរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃប្រជុំផ្សព្វផ្សាយជាសាធារណៈនូវគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

## ជំហានទី២
## ការចុះប្រមូលទិន្នន័យនិងព័ត៌មាន

**ប្រការ ១៣.-**

ការចុះប្រមូលទិន្នន័យ ដែលរួមមានទិន្នន័យបឋមនិងទិន្នន័យទី២ ត្រូវបានធ្វើឡើងក្នុងក្របខណ្ឌនៃដែនដីដែលត្រូវរៀបចំប្លង់គោលប្រើប្រាស់ដី ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ ទិន្នន័យមានសារៈសំខាន់ជាមូលដ្ឋានគ្រឹះសម្រាប់សិក្សាវិភាគស្វែងយល់អំពីស្ថានភាពបច្ចុប្បន្នក្នុងគោលដៅរៀបចំប្លង់គោលប្រើប្រាស់ដីនាពេលអនាគត។

ទិន្នន័យនិងព័ត៌មានដែលត្រូវប្រមូលមានជាអាទិ៍ ទិន្នន័យរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ការប្រើប្រាស់ដីនិងសំណង់ ប្រជាសាស្ត្រ គម្រោងអភិវឌ្ឍ។ល។ ទិន្នន័យនិងព័ត៌មានទាំងនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើរបាយការណ៍បច្ចេកទេសនិងប្លង់។

ជំហានទី២នេះ មានរយៈពេលចំនួន១៥០(មួយរយហាសិប)ថ្ងៃ។

## ជំហានទី៣
## ការវិភាគទិន្នន័យនិងការរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រ

**ប្រការ ១៤.-**

ការវិភាគទិន្នន័យមានគោលបំណងវិភាគពីលក្ខខណ្ឌមានស្រាប់ដើម្បីស្វែងរកបញ្ហាដែលធ្លាប់កើតមាន និងសក្តានុពលរបស់តំបន់។ លទ្ធផលនៃការវិភាគទិន្នន័យខាងលើនេះ ត្រូវបង្ហាញនៅលើប្លង់និងផ្សេងៗដោយធ្វើចំណោល (ប្រមើលមើលឬព្យាករណ៍) ដើម្បីកំណត់នូវការវិវឌ្ឍនិងការរៀបចំផែនការនាពេលអនាគត។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំទិន្នន័យនិងព័ត៌មានទៅតាមលំដាប់លំដោយនិងតាមប្រភេទនីមួយៗ បន្ទាប់មកធ្វើការវិភាគតាមវិធីសាស្ត្រ វិភាគបែបបរិមាណ និងវិភាគបែបគុណភាព។

**ប្រការ ១៥.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រតាមស្ថានភាពនិងសក្តានុពលរបស់តំបន់នីមួយៗ។ ការរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្រនេះធ្វើឡើងក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ ការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាពនិងសមធម៌ ដោយធានាថា ក្រុង ស្រុក ខណ្ឌ ជាកន្លែងផ្តល់នូវសុខដុមនីយកម្មសម្រាប់ការរស់នៅ ការផ្តល់ការងារ ការរៀនសូត្រ និងការលំហែកម្សាន្ត។

បន្ទាប់ពីបានកំណត់នូវចក្ខុវិស័យនិងយុទ្ធសាស្ត្រ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបង្ហាញតាមរយៈគំនូសបំព្រួញនិងសេចក្តីព្រាងប្លង់ដែលងាយស្រួលក្នុងការពិនិត្យ បកស្រាយ និងពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធ។

ជំហានទី៣នេះ មានរយៈពេល៩០(កៅសិប)ថ្ងៃ។

## ជំហានទី៤
## ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី

**ប្រការ ១៦.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគិតគូរពិចារណាលើចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុបសម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់អំពីប្រភេទនៃការប្រើប្រាស់ដី ដែលក្នុងនោះមានប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់ ព្រមទាំងបង្ហាញអំពីទម្រង់ បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍សំខាន់ៗនៃក្រុង ស្រុក ខណ្ឌព្រមទាំងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ ជាមួយតំបន់ជុំវិញសម្រាប់ពេលអនាគតដែលមានលក្ខណៈសមស្របតាមស្ថានភាពនិងសក្តានុពលជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌ។

ជំហាននេះ គឺជាជំហានមានសារៈសំខាន់ណាស់ក្នុងការជំរុញការអភិវឌ្ឍ ត្រូវបង្ហាញពីអត្តសញ្ញាណនិងវប្បធម៌ក្រុង ស្រុក ខណ្ឌ ដែលជាកន្លែងរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានយូរអង្វែង។ ការអភិវឌ្ឍត្រូវដើរទន្ទឹមនឹងការរក្សានូវកេរមរតកដ៏ថ្លៃថ្លារបស់ក្រុង ស្រុក ខណ្ឌ ការពារបរិស្ថាន និងការធានាស្ថេរភាពនៃធនធានធម្មជាតិឲ្យគង់វង្សយូរអង្វែងសម្រាប់មនុស្សជំនាន់ក្រោយ។

ការពិចារណាអំពីការបែងចែកតំបន់ប្រើប្រាស់ដីនិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវផ្អែកទៅលើលទ្ធផលនៃការសិក្សាអំពីកំណើនប្រជាសាស្ត្រ និងតម្រូវការនៃសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន។ល។ ដែលអាចគណនាឬព្យាករណ៍បានតាមរយៈរូបមន្ត ឬទិន្នន័យ ឬការសិក្សាតាមបែបវិទ្យាសាស្ត្រផ្សេងៗទៀតដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ។

**ប្រការ ១៧.-**

ក្នុងជំហាននេះ ការរៀបចំប្លង់គោលប្រើប្រាស់ដី ត្រូវសម្របសម្រួលជាមួយគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធជាធរមាន និងគម្រោងផែនការដែលមានស្រាប់។

រាល់ការប្រើប្រាស់ពណ៌និងនិមិត្តសញ្ញាដែលប្រើប្រាស់ក្នុងសន្លឹកប្លង់ទាំងអស់ត្រូវផ្អែកតាមសេចក្តីសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការដាក់ឲ្យប្រើប្រាស់បទដ្ឋានតំណាងពណ៌និងនិមិត្តសញ្ញា

សម្គាល់សម្រាប់អនុវត្តក្នុងគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីនៅកម្ពុជា ដែលត្រូវបានកំណត់ដោយសេចក្តីសម្រេចដោយឡែក។

ជំហានទី៤នេះ មានរយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ។

## ជំហានទី៥
## ការប្រមូលធាតុចូលនិងការកែសម្រួលបឋម

**ប្រការ ១៨.-**

ការប្រមូលធាតុចូលត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំ ឬសិក្ខាសាលា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

ធាតុចូលដែលទទួលបានពីភាគីពាក់ព័ន្ធ ត្រូវយកមកពិនិត្យ ពិចារណា កែសម្រួល និងបំពេញបន្ថែមស្របតាមលក្ខណៈបច្ចេកទេសនិងស្ថានភាពជាក់ស្តែងនៃភូមិសាស្ត្រនីមួយៗ ក្នុងគោលបំណងរៀបចំប្លង់គោលប្រើប្រាស់ដីឲ្យកាន់តែចំទិសដៅ និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

ជំហានទី៥នេះ មានរយៈពេល៩០(កៅសិប)ថ្ងៃ។

## ជំហានទី៦
## ការបិទផ្សាយជាសាធារណៈ

**ប្រការ ១៩.-**

ការបិទផ្សាយជាសាធារណៈគឺជាការផ្សព្វផ្សាយនូវលទ្ធផលបឋមនៃការរៀបចំប្លង់គោលប្រើប្រាស់ដី ដើម្បីទទួលសំណើ ព្រមទាំងការតវ៉ាផ្សេងៗ។ មន្ត្រីជំនាញដែលប្រចាំការនៅទីតាំងបិទផ្សាយមានភារកិច្ចពន្យល់នូវសំណួរ និងការងឿងឆ្ងល់ទាំងឡាយរបស់សាធារណជនចំពោះសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីដែលនឹងត្រូវអនុម័តក្រោយពេលបិទផ្សាយរួច។

**ប្រការ ២០.-**

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបិទផ្សាយជាសាធារណៈនៅសាលាក្រុង ឬ ស្រុក ឬ ខណ្ឌ ផ្សព្វផ្សាយតាមគេហទំព័រផ្លូវការ និងតាមរយៈទូរទស្សន៍ វិទ្យុ។ល។ នៅទីកន្លែងបិទផ្សាយ ត្រូវមានក្រុមការងារនៅប្រចាំការដើម្បីពន្យល់និងកត់ត្រារាល់មតិ សំណើ និងការតវ៉ាផ្សេងៗរបស់សាធារណជន។ ការបិទផ្សាយជាសាធារណៈត្រូវធ្វើក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានបញ្ចប់ការបិទផ្សាយជាសាធារណៈ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសំណុំឯកសាររួមមាន៖ របាយការណ៍បូកសរុបលទ្ធផលនៃការបិទផ្សាយ មតិយោបល់របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី ដើម្បីផ្ញើជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យ ផ្តល់យោបល់ និងបញ្ជូនមកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីពិនិត្យនិងផ្តល់អនុសាសន៍មុននឹងធ្វើការកែសម្រួលចុងក្រោយ។

ក្នុងករណីមានបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធដល់សេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី មន្ត្រីជំនាញដែលនៅប្រចាំការនៅទីកន្លែងបិទផ្សាយនោះ ត្រូវខិតខំសម្រុះសម្រួលនិងពន្យល់ដល់សាមីអ្នកប្តឹងតវ៉ានោះឲ្យបានច្បាស់។

ក្នុងករណីដែលមិនអាចសម្រុះសម្រួលបាន មន្ត្រីជំនាញត្រូវធ្វើរបាយការណ៍ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីសម្រុះសម្រួលនិងពន្យល់បន្ថែមដល់សាមីអ្នកប្តឹងតវ៉ា ដោយ

លើកហេតុផលបច្ចេកទេស ច្បាប់ សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ ដើម្បីផលប្រយោជន៍របស់ប្រជាជនភាគច្រើននៅក្រុង ស្រុក ខណ្ឌ។

ក្នុងករណីដែលអ្នកប្តឹងតវ៉ានៅតែមិនព្រមទទួលយកនូវការសម្រុះសម្រួលខាងលើនេះ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ដោយភ្ជាប់នូវជម្រើសនៃដំណោះស្រាយជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងសម្រេចបញ្ជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដើម្បីពិនិត្យនិងសម្រេចចុងក្រោយ។

ជំហានទី៦នេះមានរយៈពេល៦០(ហុកសិប)ថ្ងៃ។ ក្នុងករណីមានបណ្តឹងតវ៉ាផ្សេងៗ រយៈពេល៦០(ហុកសិប)ថ្ងៃនេះអាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## ជំហានទី៧
## ការកែសម្រួលចុងក្រោយ

**ប្រការ ២១.-**

ការកែសម្រួលចុងក្រោយ ត្រូវធ្វើឡើងនៅពេលទទួលបានការសម្រេចពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដោយយោងទៅលើរបាយការណ៍របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងមតិយោបល់របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងដោយផ្អែកទៅលើទិដ្ឋភាពបច្ចេកទេស ច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ និងប្រពៃណីរស់នៅរបស់ប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌ។

ក្រោយពីការកែសម្រួលចុងក្រោយរួចហើយ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនឯកសារទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ដើម្បីសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

ឯកសារខាងលើនេះត្រូវផ្ញើជូន៖

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ នៃសាមីប្លង់គោលប្រើប្រាស់ដី ដើម្បីអនុវត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានទីតាំងជាប់ព្រំក្រុង ស្រុក ខណ្ឌ សាមីប្លង់គោលប្រើប្រាស់ដី ដើម្បីសហការអនុវត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ដើម្បីតាមដានការអនុវត្ត
- រក្សាទុកមួយច្បាប់នៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីតាមដានការអនុវត្ត
- ទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងមហាផ្ទៃ ដើម្បីជូនជ្រាបនិងរក្សាទុកជាឯកសារ។

ជំហានទី៧នេះ មានរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។

## ជំហានទី៨
## ការរៀបចំគម្រោងអាទិភាព

**ប្រការ ២២.-**

ការអនុវត្តគម្រោងត្រូវធ្វើទៅតាមលំដាប់អាទិភាពដែលបានសម្រេចជាផ្លូវការ។

គម្រោងអាទិភាពជាប្រភេទនៃប្លង់លម្អិតនគរូបនីយកម្មដែលមានសារៈសំខាន់សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដី និងបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមូលដ្ឋានក្នុងការបញ្ចូលគម្រោងទាំងនេះក្នុងផែនការស្នើសុំថវិកាដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនទៅតាមលំដាប់អាទិភាព។

គម្រោងអាទិភាព ត្រូវបែងចែកឲ្យបានច្បាស់រវាងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់និងហេដ្ឋារចនាសម្ព័ន្ធគ្រោងថ្មី។ ចំពោះហេដ្ឋារចនាសម្ព័ន្ធគ្រោងថ្មី ត្រូវបង្ហាញនៅលើប្លង់ដែលងាយស្រួលយល់ ហើយធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលត្រូវកសាងរយៈពេលខ្លី រយៈពេលមធ្យមនិងរយៈពេលវែង (គម្រោងថ្មីអាចរៀបចំនៅលើទីតាំងថ្មី ឬអាចរៀបចំកែលម្អនៅលើទីតាំងចាស់)។ បន្ទាប់មកយកគម្រោងនីមួយៗរៀបតាមលំដាប់អាទិភាពនៅក្នុងបញ្ជីមួយ ដោយភ្ជាប់ជាមួយនឹងការបរិយាយពីមូលហេតុនៃការធ្វើចំណាត់ថ្នាក់នេះ ព្រមទាំងតម្លៃប៉ាន់ស្មាននៃគម្រោងនីមួយៗ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ជំហានទី៨នេះ មានរយៈពេល៦០(ហុកសិប)ថ្ងៃ។

## ជំហានទី៩
## ការសម្រេចលើប្លង់គោលប្រើប្រាស់ដី

**ប្រការ ២៣.-**

ការសម្រេចលើសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី មានអត្ថប្រយោជន៍ក្នុងការធ្វើឲ្យមានតម្លៃជាផ្លូវការនិងជាមូលដ្ឋានបង្អែក ក្នុងការអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី ព្រមទាំងសំណុំឯកសារពាក់ព័ន្ធ(របាយការណ៍បច្ចេកទេស ប្លង់នានា គម្រោងអាទិភាព ឯកសារឧបសម្ព័ន្ធនានា...)ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ ដើម្បីដាក់ជូន៖

១. ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យនិងឯកភាពក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

២. គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងឯកភាពក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ។

៣. ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យនិងឯកភាពក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

៤. គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ពិនិត្យនិងសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃ។

ជំហានទី៩នេះ មានរយៈពេលសរុបចំនួន១៥០(មួយរយហាសិប)ថ្ងៃ។

# ផ្នែកទី២
# ការរៀបចំផែនការប្រើប្រាស់ដី

**ប្រការ ២៤.-**

ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១.ការប្រមូលនិងវិភាគទិន្នន័យៈ ត្រូវប្រមូលនិងវិភាគទិន្នន័យរូបវន្ត នគរូបនីយកម្ម ការប្រើប្រាស់ដី សំណង់លំនៅឋាន សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ធនធានធម្មជាតិ ផ្លូវនិងរូបភាព។ល។

២.ការកំណត់យុទ្ធសាស្ត្រៈ ត្រូវកំណត់យុទ្ធសាស្ត្រឲ្យស្របតាមប្លង់គោលប្រើប្រាស់ដី។

៣.គំនូសប្លង់ក្នុងផែនការប្រើប្រាស់ដី មានដូចជា៖

៣.១.ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

-ប្លង់បង្ហាញទីតាំង

-ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំផែនការប្រើប្រាស់ដី

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់កំណត់ប្រភេទប្រើប្រាស់ដី

-ប្លង់កំណត់តំបន់ប្រើប្រាស់ដី

-ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ

-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង

-ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍

-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី

-ប្លង់ធ្លាគម្លាតសំណង់និងប្លង់តម្រង់ជួរ

-ប្លង់កំណត់កម្ពស់សំណង់

-ប្លង់សរុប។

៣.២.ប្លង់អនាគតកាលមានដូចជា៖

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់បែងចែកតំបន់ប្រើប្រាស់ដី

-ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ

-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង

-ប្លង់បង្ហាញពីទិសដៅប្រើប្រាស់ដី

-ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍

-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី

-ប្លង់ធ្លាគម្លាតសំណង់និងប្លង់តម្រង់ជួរ

-ប្លង់កំណត់កម្ពស់សំណង់

-ប្លង់សរុប។

៤.បទបញ្ញាប្រើប្រាស់ដី ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់គ្រប់ប្រភេទ។

៥.ឯកសារនិងឧបសម្ព័ន្ធ។

**ប្រការ ២៥.-**

ការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី បទបញ្ញានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដីនិងការអភិរក្សក្នុងតំបន់នីមួយៗ។ ការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ក៏ត្រូវកំណត់អំពីបណ្តាញគមនាគមន៍និងការធ្វើសមាហរណកម្ម ព្រមទាំងកំណត់អំពីបទដ្ឋានបច្ចេកទេសនៃការសាងសង់ (កំណត់កម្ពស់អគារ ប្លង់តម្រង់ជួរ ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សន្ទស្សន៍ប្រើប្រាស់ដី និងផ្ទៃសួន(សួនជ្រាបទឹកនិងសួនមិនជ្រាបទឹក...) ស្របតាមចក្ខុវិស័យ យុទ្ធសាស្ត្រ និងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការបែងចែកតំបន់ប្រើប្រាស់ដីក្នុងប្រភេទដីអាចសាងសង់បាន រួមមាន តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លំហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា តំបន់ចម្រុះ និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។ ការបែងចែកតំបន់ប្រើប្រាស់ដីក្នុងប្រភេទដីកម្រិតការសាងសង់ រួមមាន តំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ។

**ប្រការ ២៦.-**

ការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ និងត្រូវអនុវត្តដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។

នីតិវិធីនិងដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមជំហានដូចនីតិវិធី និងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌដែរ។

## ផ្នែកទី៣
## ការរៀបចំប្លង់លម្អិតនគរូបនីយកម្ម

**ប្រការ ២៧**

ប្លង់លម្អិតនគរូបនីយកម្ម គឺជាប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងក្រុង ស្រុក ខណ្ឌ ឬជាគម្រោងអភិវឌ្ឍក្រុង ស្រុក ខណ្ឌ ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើននៃទីក្រុងដែលមានជាអាទិ៍ ការបង្ហាញអំពីការរៀបចំ ការរចនា ទម្រង់ រូបរាង និងសោភណភាពនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

ប្លង់លម្អិតនគរូបនីយកម្ម មានទំហំការងារអប្បបរមាដូចខាងក្រោម៖

-ប្លង់បង្ហាញទីតាំង
-ប្លង់សរុបដោយមានកំណត់ព្រំប្រទល់
-ប្លង់លម្អិតការប្រើប្រាស់ដី
-ប្លង់បណ្តាញផ្លូវថ្នល់
-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
-ប្លង់ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
-ប្លង់សួនច្បារដោយដីជ្រាបទឹកនិងផ្ទៃបៃតង
-ប្លង់ឆ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ
-ប្លង់កំណត់កម្ពស់សំណង់
-ប្លង់គំហើញសំណង់និងរចនាសម្ព័ន្ធ
-ប្លង់នេត្រាទស្សន៍ ឬ គំរូសំណាក
-បទប្បញ្ញត្តិនគរូបនីយកម្ម។

## ផ្នែកទី៤
## ការរៀបចំសិក្ខាសាលាទទួលធាតុចូល

**ប្រការ ២៨.-**

ក្នុងដំណើរការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី ត្រូវរៀបចំសិក្ខាសាលានៅទីតាំងគម្រោងដើម្បីទទួលធាតុចូល ឲ្យបានយ៉ាងតិច៣(បី)លើក មានជាអាទិ៍៖

១. សិក្ខាសាលាផ្សព្វផ្សាយគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី ដល់ប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធនានាឲ្យបានដឹងឮ និងចូលរួមចំណែកក្នុងការផ្តល់ព័ត៌មាននិងទិន្នន័យដល់អ្នកជំនាញនៅជំហានបន្តបន្ទាប់ទៀតដើម្បីឈានដល់ការសម្រេចជោគជ័យ។ សិក្ខាសាលានេះ ត្រូវរៀបចំធ្វើឡើងក្រោយការចុះសិក្សាបឋមលើទីតាំង(ជំហានទី១)និងមានរយៈពេលយ៉ាងតិច១(មួយ)ថ្ងៃ។

២. សិក្ខាសាលាផ្ទៀងផ្ទាត់ទិន្នន័យដែលទទួលបានពីការចុះប្រមូលផ្ទាល់នៅមូលដ្ឋាន ទាំងទិន្នន័យបឋមនិងទិន្នន័យទី២។ សិក្ខាសាលានេះមានសារៈសំខាន់ក្នុងការបំពេញបន្ថែមទិន្នន័យ ព័ត៌មានក៏ដូចជាការកែតម្រូវទិន្នន័យព័ត៌មាន ឲ្យបានត្រឹមត្រូវដើម្បីជាមូលដ្ឋានក្នុងការវិភាគនិងការព្យាករណ៍សម្រាប់ពេលអនាគត។ សិក្ខាសាលានេះ ត្រូវរៀបចំធ្វើឡើងនៅពេលបញ្ចប់ការប្រមូលទិន្នន័យព័ត៌មាន និងការកំណត់ព្រំប្រទល់(ជំហានទី២) និងមានរយៈពេលយ៉ាងតិច១(មួយ)ថ្ងៃ។

៣. សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈដែលត្រូវធ្វើឡើងនៅទីតាំងគម្រោង ដើម្បីទទួលធាតុចូលពីភាគីពាក់ព័ន្ធ ក្នុងការរៀបចំនិងកែសម្រួលប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដីឲ្យបានល្អ។ ក្នុងឱកាសសិក្ខាសាលានេះ គណៈកម្មាធិការអាចបើកឡើងនូវសំណូមពរដល់ភាគីពាក់ព័ន្ធឲ្យជួយផ្តល់ទិន្នន័យនិងព័ត៌មានបន្ថែមទៀត ក្នុងការបង្កើនភាពជាក់លាក់ក្នុងការវិភាគនិងការព្យាករណ៍ឲ្យចំទិសដៅនិងមានប្រសិទ្ធភាពខ្ពស់។ សិក្ខាសាលានេះ ត្រូវរៀបចំធ្វើឡើងនៅពេលបញ្ចប់ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី(ជំហានទី៤) និងមានរយៈពេលយ៉ាងតិច១(មួយ)ថ្ងៃ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ ២៩.-**

លក្ខខណ្ឌដែលមានចែងក្នុងសេចក្តីសម្រេចនេះនឹងត្រូវយកទៅអនុវត្តចំពោះតែប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្មដែលបានរៀបចំក្រោយពីថ្ងៃដែលសេចក្តីសម្រេចនេះចូលជាធរមាន។

ចំពោះប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម ដែលកំពុងដំណើរការរៀបចំនិងបានរៀបចំហើយ ប៉ុន្តែមិនទាន់បានអនុម័តដាក់ឲ្យប្រើប្រាស់ ត្រូវបានអនុញ្ញាតឲ្យបន្តរៀបចំបញ្ចប់និងដាក់ស្នើសុំការអនុម័ត ឲ្យប្រើប្រាស់ជាផ្លូវការដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវខិតខំជំរុញការរៀបចំបន្តបញ្ចប់ និងដាក់ស្នើសុំការអនុម័ត ឲ្យប្រើប្រាស់ជាផ្លូវការនូវប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនមិនឲ្យលើសពី២(ពីរ)ឆ្នាំ បន្ទាប់ពីសេចក្តីសម្រេចនេះចូលជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ៣០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣១.-**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែកក្កដាឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**អ៊ឹម ឈុនលឹម**

**<u>កន្លែងទទួល</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ
- សាលារាជធានី ខេត្ត
- ដូចប្រការ៣១
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៤៦ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

### នីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ



**ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៤១សសរ ចុះថ្ងៃទី២២ ខែកក្កដាឆ្នាំ២០១៤**
**ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង**
**ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ**

ការគណនាឬព្យាករណ៍កំណើនប្រជាសាស្ត្រ

<u>វិធីសាស្ត្រទី១: គណនាចំនួនប្រជាជនតាមធម្មជាតិ</u>

$$\text{កំណើនប្រជាជននាពេលចុងក្រោយ} \times \left( \frac{\text{អត្រាកំណើនធម្មជាតិ}}{100} + 1 \right)^{n}$$

n គឺជាផលដករវាងឆ្នាំចុងក្រោយ - ឆ្នាំមុន

ឧទាហរណ៍: យើងចង់គណនាចំនួនប្រជាជនឆ្នាំ២០០៩ ហើយគេមានតួលេខចំនួនប្រជាជនឆ្នាំ២០០៨ ចំនួន ១៣.៣៩៥.៦៨២នាក់ និងដឹងអត្រាកំណើន ១.៥៨%

តាមរូបមន្តខាងលើគេបាន៖

$$\text{ចំនួនប្រជាជនឆ្នាំ២០០៩} = \text{ចំនួនប្រជាជនឆ្នាំ២០០៨} \times \left( \frac{0.១៥៨}{១00} + ១ \right)^{១}$$

**ចំនួនប្រជាជនឆ្នាំ២០០៩ គឺ ១៣.៦០៧.៣៣៤នាក់**

**<u>វិធីសាស្ត្រទី២: គណនាចំនួនប្រជាជន</u>**

គណនាអត្រាកំណើនប្រចាំឆ្នាំ បែប Exponential

$$r = \frac{\log_e P^t - \log_e P_0}{t}$$

- $P_t = P_0 e^{rt}$
- $P_0$ ជាចំនួនប្រជារាស្ត្រនៅឆ្នាំគោល
- $P_t$ ជាចំនួនប្រជារាស្ត្រនៅឆ្នាំ t
- t ចំនួនឆ្នាំ រវាង $P_0$ និង $P_t$
- r អត្រាកំណើន។

ឧទាហរណ៍: យើងមានតួលេខចំនួនប្រជាជនឆ្នាំ១៩៩៨ ចំនួន ១១.៤៣៧.៦៥៦នាក់ និងចំនួនប្រជាជនឆ្នាំ២០០៨ ចំនួន ១៣.៣៩៥.៦៨២នាក់

$$r = \frac{\log_e(13{,}395{,}682) - \log_e(11{,}437{,}656)}{10}$$

ដោយ $\log_e(13,395,682) = 16.41044$ និង $\log_e(11,437,656) = 16.25242$

$$r = \frac{16.41044 - 16.25242}{10} = 0.0158$$ ឬ 1.58%

ចំនួនប្រជាជនឆ្នាំ២០០៩ គឺ $P_{2009} = P_{2008}\, e^{0.0158*1}$ តែ $e^{0.0158*1} = 1.0159$

នាំឲ្យចំនួនប្រជាជនឆ្នាំ២០០៩ = ចំនួនប្រជាជនឆ្នាំ២០០៨ X 1.0159 = 13,609,044

**ដូច្នេះចំនួនប្រជាជនឆ្នាំ២០០៩ គឺ ១៣.៦០៩.០៤៤នាក់**

គម្លាតរវាងវិធីសាស្ត្រទី១ និងទី២ គឺខុសចំនួន ១.៧១០នាក់
សន្និដ្ឋានរូបមន្តទាំងពីរមានលក្ខណៈប្រហាក់ប្រហែលគ្នា។

__វិធីសាស្ត្រទី៣: យើងត្រូវការព័ត៌មានមួយចំនួនដើម្បីដាក់បញ្ចូលក្នុងកម្មវិធីកុំព្យូទ័រមានដូចខាងក្រោម:__

- ចំនួនប្រជាជនតាមក្រុមអាយុ៥ឆ្នាំ និងតាមភេទ
- អត្រាមរណភាព
- អាយុសង្ឃឹមរស់
- លទ្ធភាពបង្កើតកូនរបស់ស្ត្រី
- ចំនួនប្រជាជនដែលបម្លាស់ទីទាំងចេញ និងទាំងចូល
- ចុងក្រោយគឺយើង RUN Program

លទ្ធផលដែលគេបានគណនាគឺចំនួនប្រជាជនឆ្នាំ២០០៩ គឺ **១៤.០៨៥.៣២៤នាក់**
**គម្លាតរវាងវិធីសាស្ត្រទី៣ និងទី១ គឺ ៤៧៧.៩៩០នាក់**
**គម្លាតរវាងវិធីសាស្ត្រទី៣ និងទី២ គឺ ៤៧៦.២៨០០នាក់**

__សន្និដ្ឋាន__: វិធីសាស្ត្រទី៣មានលក្ខណៈស្មុគស្មាញ ប៉ុន្តែមានការសិក្សាស៊ីជម្រៅជាង ហើយភាគច្រើនប្រព័ន្ធ UN គេប្រើវិធីសាស្ត្រនេះច្រើនជាង។ វិទ្យាស្ថានជាតិស្ថិតិបានផលិតរួចគឺ Population Projection ដែលមានដល់ថ្នាក់ខេត្តផងដែរ។

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៤៦ សសរ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤
ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង
ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

ការរៀបចំគម្រោងអភិវឌ្ឍនិងផែនការសកម្មភាពតាមលំដាប់អាទិភាព




រូបភាពទី១: ប្លង់បង្ហាញពីគម្រោងអាទិភាពនិងគម្រោងអនុវត្ត ក្នុងទីប្រជុំជនអន្លង់វែង

តារាងទី១: បញ្ជីគម្រោងអភិវឌ្ឍនិងផែនការសកម្មភាពតាមលំដាប់អាទិភាព

| ឈ្មោះគម្រោង: គម្រោងសាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រការពារដីកសិកម្ម | អាទិភាព<br>ក |
|---|---|
| ប្រវត្តិគម្រោង | |
| ទីប្រជុំជន គឺជាទីតាំងនៃកំណើនប្រជាជន សេដ្ឋកិច្ច និងសង្គមកិច្ច ដែលជាមូលហេតុនៃការរីករាលដាលនៃទីក្រុងទៅតំបន់ជាយក្រុង។ បាតុភាពនេះ បានធ្វើឲ្យអាជ្ញាធរមូលដ្ឋានលំបាកក្នុងការគ្រប់គ្រងរវាងប្រភេទដីអាចសាងសង់បាន និងប្រភេទដីគ្រប់គ្រងការសាងសង់។ | |
| បរិយាយគម្រោង | |
| <u>សមាសភាគគម្រោង</u> ៖ ផ្លូវខ្សែក្រវាត់តំបន់នគរូបនីយកម្ម និងប្រព័ន្ធលូចំនួន០១ខ្សែ មានប្រវែងប្រមាណ២០គ.ម<br><u>រយៈពេលអនុវត្តគម្រោង</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១២-២០១៣<br><u>ទីតាំងគម្រោង</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង | |
| អង្គភាពអនុវត្តគម្រោង | |
| មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង | |

| ឈ្មោះគម្រោង: គម្រោងសាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រការពារប្រភពទឹក | អាទិភាព ខ |
|---|---|

**ប្រវត្តិគម្រោង**

ប្រភពទឹកគឺជាទីតាំងដែលបង្កលក្ខណៈងាយស្រួលខ្លាំងដល់ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ តាមរយៈការផ្គត់ផ្គង់នូវប្រភពទឹកសម្រាប់បរិភោគ ការនេសាទ ការស្រោចស្រព។ល។ ការសាងសង់លំនៅឋាននៅជាប់មាត់ទឹកជារឿយៗ តែងតែជះឥទ្ធិពលមិនល្អដល់ប្រភពទឹក តាមរយៈការបង្ហូរទឹកកខ្វក់ ការចាក់ដីលុបទន្រ្ទានផ្ទៃទឹកយកកន្លែងសាងសង់សំណង់បណ្ដោះអាសន្ន...។

**បរិយាយគម្រោង**

<u>សមាសភាគគម្រោង</u> ៖ ផ្លូវខ្សែក្រវាត់បឹងអន្លង់វែង និងប្រព័ន្ធលូចំនួន០១ខ្សែ មានប្រវែងប្រមាណ១១គ.ម<br>ផ្លូវអមសងខាងអូរ ប្រឡាយ និងប្រព័ន្ធលូចំនួន០៤ខ្សែ មានប្រវែងប្រមាណ២០គ.ម

<u>រយៈពេលអនុវត្តគម្រោង</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៣-២០១៥

<u>ទីតាំងគម្រោង</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង

**អង្គភាពអនុវត្តគម្រោង**

**មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង**

| ឈ្មោះគម្រោង: គម្រោងសាងសង់ និងកែលម្អផ្លូវខ្សែក្រវាត់ទីប្រជុំជន | អាទិភាព គ |
|---|---|

**ប្រវត្តិគម្រោង**

ទីប្រជុំជន ត្រូវបានបង្កើតឡើងដោយមានព្រំប្រទល់ច្បាស់លាស់ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច ប្រជាសាស្ត្រ និងការងាររៀបចំផែនការ។ ការងារអនុវត្តជាក់ស្តែងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពជំនាញ តែងតែមានភាពមិនច្បាស់លាស់រវាងព្រំប្រទល់ដែលមាននៅលើផែនទី និងនៅលើដីជាក់ស្តែង។

**បរិយាយគម្រោង**

<u>សមាសភាគគម្រោង</u> ៖ ផ្លូវខ្សែក្រវាត់ទីប្រជុំជន និងប្រព័ន្ធលូចំនួន០១ខ្សែ មានប្រវែងប្រមាណ២២គ.ម

<u>រយៈពេលអនុវត្តគម្រោង</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៥-២០១៦

<u>ទីតាំងគម្រោង</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង

**អង្គភាពអនុវត្តគម្រោង**

**មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង**

| ឈ្មោះគម្រោង: គម្រោងសាងសង់ និងកែលម្អផ្លូវមេសំខាន់ៗ | អាទិភាព ឃ |
|---|---|

**ប្រវត្តិគម្រោង**

ទីប្រជុំជន គឺជាទីតាំងដែលអាចរស់នៅបាន ធ្វើចរាចរណ៍បាន ធ្វើការបាន និងសម្រាកកម្សាន្តបាន ដែលត្រូវការជាចាំបាច់នូវបណ្តាញផ្លូវថ្នល់ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ បណ្តាញផ្លូវថ្នល់ ត្រូវបាននូវកើតចេញពីផ្លូវវេទ្ធើរផ្សេង ឬផ្លូវរទេះ ដែលមានលក្ខណៈពុំសមស្របតាមបច្ចេកទេស និងពុំមានចំណាត់ថ្នាក់ត្រឹមត្រូវ។

| បរិយាយគម្រោង | |
|---|---|
| **<u>សមាសភាគគម្រោង</u>** ៖ ផ្លូវមេសំខាន់ និងប្រព័ន្ធលូចំនួន០៨ខ្សែ មានប្រវែងប្រមាណ១៧,២គ.ម<br>**<u>រយៈពេលអនុវត្តគម្រោង</u>**៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៦-២០១៨<br>**<u>ទីតាំងគម្រោង</u>** ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង | |
| អង្គភាពអនុវត្តគម្រោង | |
| **មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង** | |
| **ឈ្មោះគម្រោង: គម្រោងសាងសង់ និងកែលម្អផ្លូវឃុំ សង្កាត់** | **អាទិភាព**<br>ង |
| ប្រវត្តិគម្រោង | |
| ទីប្រជុំជន គឺជាទីតាំងដែលអាចរស់នៅបាន ធ្វើចរាចរណ៍បាន ធ្វើការបាន និងសម្រាកកម្សាន្តបាន ដែលត្រូវការជាចាំបាច់នូវបណ្តាញផ្លូវថ្នល់ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ បណ្តាញផ្លូវថ្នល់ ត្រូវបានកើតចេញពីផ្លូវធ្វើរជើង ឬ ផ្លូវរទេះ ដែលមានលក្ខណៈពុំសមស្របតាមបច្ចេកទេស និងពុំមានចំណាត់ថ្នាក់ត្រឹមត្រូវ។ | |
| បរិយាយគម្រោង | |
| **<u>សមាសភាគគម្រោង</u>** ៖ ផ្លូវឃុំ សង្កាត់ និងប្រព័ន្ធលូចំនួន០៦ខ្សែ មានប្រវែងប្រមាណ១២,២គ.ម<br>**<u>រយៈពេលអនុវត្តគម្រោង</u>**៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៨-២០២០<br>**<u>ទីតាំងគម្រោង</u>** ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង | |
| អង្គភាពអនុវត្តគម្រោង | |
| **មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង** | |
| **ឈ្មោះគម្រោង: គម្រោងរៀបចំទីលានចាក់សំរាម និងអាងប្រព្រឹត្តកម្មទឹកកខ្វក់** | **អាទិភាព**<br>គ |
| ប្រវត្តិគម្រោង | |
| កំណើនប្រជាជន បានធ្វើឲ្យកើនឡើងនូវបរិមាណសំណល់រឹង និងសំណល់រាវ។ ដូច្នេះ កង្វះខាតការគ្រប់គ្រងឲ្យបានល្អនូវសំណល់រឹង និងសំណល់រាវ បានជះឥទ្ធិពលមិនល្អដល់បរិស្ថាន និងការរស់នៅរបស់ប្រជាពលរដ្ឋ។ | |
| បរិយាយគម្រោង | |
| **<u>សមាសភាគគម្រោង</u>** ៖ ទីលានចាក់សំរាម និងអាងប្រព្រឹត្តកម្មទឹកកង្វក់ចំនួន០២កន្លែង<br>**<u>រយៈពេលអនុវត្តគម្រោង</u>**៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១២-២០១៣<br>**<u>ទីតាំងគម្រោង</u>** ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង | |
| អង្គភាពអនុវត្តគម្រោង | |
| **មន្ទីរបរិស្ថាន និងសាលាស្រុកអន្លង់វែង** | |

ប្រភព ៖ ក្រុមការងាររៀបចំផែនការប្រើប្រាស់ដីទីប្រជុំជនអន្លង់វែង ឆ្នាំ២០១៨

# ឧបសម្ព័ន្ធទី៣

# ព្រះរាជក្រម

នស/រកម/១១១៩/០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

# ស្តីពី

# សំណង់

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ច្បាប់នេះមានគោលបំណងធានា៖

- គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- សោភណភាពនិងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ
- គណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- ការបង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២ ._**

ច្បាប់នេះមានគោលដៅកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ._**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភេទសំណង់ដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ ._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ ._**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៣

## គោលការណ៍

**មាត្រា៦ ._**

រាល់ការងារសំណង់ត្រូវគោរពគោលការណ៍៖

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

## ជំពូកទី៤

## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**មាត្រា៧ .-**

រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្ដល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្ររាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៩ .-**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០ .-**

បទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ត្រូវដាក់ឱ្យប្រើប្រាស់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀតក្រៅពីបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ

ឧស្សាហកម្ម តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដទៃទៀតដែលមិនទាន់ត្រូវបានកំណត់ជាស្តង់ដាកម្ពុជា ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាននិងមានតំណាងក្រសួងស្ថាប័ននិងវិស័យឯកជនពាក់ព័ន្ធជាសមាជិក។

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

**មាត្រា១២ .-**

រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិជ្ជាជីវៈនីមួយៗពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា១៣ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

ក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤ .-**

ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

**មាត្រា១៥ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលអាចប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យបាន ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើយ។

នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

**មាត្រា១៦ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាកឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានបញ្ជាក់ពីគ្រូពេទ្យជំនាញឬបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិត្ថបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនេះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៧ .-**

រាល់ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្តទៅតាមប្រភេទអាជីវកម្ម។

**មាត្រា១៨ .-**

ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភដោយតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់មិនត្រូវមានរយៈពេលលើសពី១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្ដល់ឡើងវិញក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៩ .-**

បុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រធានារ៉ាប់រង ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។

កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង សំដៅធានាការបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈឬអ្នកប្រកបអាជីវកម្មនិងអតិថិជនរបស់ខ្លួន។

ចំនួនទឹកប្រាក់អប្បបរមាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០.-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនិងអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតឱ្យប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១.-**

ការស្នើសុំអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

## ជំពូកទី៧

## ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងមន្ទីរពិសោធន៍សំណង់

**មាត្រា២២.-**

សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬតាមស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ ដោយត្រូវមានបិទឬបោះពុម្ពសញ្ញាស្តង់ដាកម្ពុជានិងត្រូវមានអាជ្ញាបណ្ណប្រើសញ្ញាស្តង់ដាកម្ពុជា។

បែបបទនិងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពនិងប្រភេទនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣.-**

ការផលិត ការចែកចាយ ការនាំចូល ការដាក់លក់ ការផ្គត់ផ្គង់ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ដែលគ្មានបិទសញ្ញាស្តង់ដាកម្ពុជា ឬគ្មានការបញ្ជាក់ទទួលស្គាល់ ឬគ្មានការបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់

ឬផលិតផលសំណង់នោះ តម្រូវឱ្យមានបិទសញ្ញាស្តង់ដាកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនៃការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ជាតិសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥.-**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

**មាត្រា២៦.-**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៧.-**

ការងារសាងសង់ឬរុះរើក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៨ .-**

រាល់ការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាតមានដូចខាងក្រោម៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ។

ប្រភេទនិងទំហំនៃការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

រាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូលឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រភេទនិងទំហំការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ .-**

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

ការអនុវត្តការងារសាងសង់ឬរុះរើចំពោះសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតមិននាំឱ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

## ជំពូកទី៩

## ការគ្រប់គ្រងគម្រោងប្លង់

**មាត្រា៣២ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាព ជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ផ្ទាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។

អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គម្រោងប្លង់សាងសង់ឬរុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

មុនការអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ។

ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ .-**

រាល់ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូលឬដោយផ្នែកដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់ ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះនិងម្ចាស់សំណង់បានឡើយ។

រាល់ការអនុវត្តគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។ គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០

## ការគ្រប់គ្រងការងារសាងសង់ឬរះវើ

### មាត្រា៣៦ ._

រាល់ការងារសាងសង់ឬរះវើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។

អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ឬរះវើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និង
- សាងសង់ឬរះវើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

### មាត្រា៣៧ ._

រាល់ការងារសាងសង់ឬរះវើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬរះវើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

### មាត្រា៣៨ ._

រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា៣៩ ._

អ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅការដ្ឋានសំណង់របស់ខ្លួន។

**មាត្រា៤០ .-**

ម្ចាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើត្រូវរៀបចំដោយអ្នកសាងសង់និងមានការឯកភាពពីម្ចាស់សំណង់។

បែបបទនិងនីតិវិធីនៃការផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៤១ .-**

នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើត្រូវធ្វើរបាយការណ៍និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ចនិងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

**មាត្រា៤២ .-**

ក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការងារសាងសង់ឬរុះរើ។

ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់ រាប់បញ្ចូលទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់។

អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណី រកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត។

**មាត្រា៤៣ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យការងារសាងសង់ឬរុះរើត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១

## ការប្រើប្រាស់សំណង់

**មាត្រា៤៤ .-**

ការប្រើប្រាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់នោះ។

រាល់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

**មាត្រា៤៥ ..**

អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្តោះអាសន្នបាន ចំពោះសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់ ក្នុងករណីដែលសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។

**មាត្រា៤៦ ..**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៧ ..**

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រៀងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់ក្នុងរយៈពេលរៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល២(ពីរ)ឆ្នាំម្តង។

បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឱ្យមានការត្រួតពិនិត្យរៀងរាល់១(មួយ)ឆ្នាំម្តង។ ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែក្រោយថ្ងៃផុតកំណត់រយៈពេលដែលតម្រូវឱ្យអនុវត្តការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៤៨ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ក្នុងករណីមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៤៩ .-**

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

ចំពោះអគារសហកម្មសិទ្ធិ ម្ចាស់នៃចំណែកឯកជនទាំងអស់ត្រូវទទួលបន្ទុករួមគ្នាលើរាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ស្របតាមសមាមាត្រទៅនឹងទំហំនៃចំណែកឯកជន។

**មាត្រា៥០ .-**

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី១២
## សំណង់ដែលមានសភាពគ្រោះថ្នាក់

**មាត្រា៥១ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យ តាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៥២ .-**

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនិងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់ជាអាទិ៍ ហ៊ុំព័ទ្ធហាមចូល ហាមប្រើប្រាស់ និងតម្រូវឱ្យរុះរើសំណង់។

រាល់ការចំណាយក្នុងការបញ្ចៀសគ្រោះថ្នាក់ជាបន្ទុករបស់ម្ចាស់សំណង់។

**មាត្រា៥៣ .-**

កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១៣

## សំណង់ដែលសាងសង់ឬរុះរើដោយគ្មានឬខុសពីលិខិតអនុញ្ញាត

**មាត្រា៥៤ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ការងារសាងសង់ឬរុះរើដែលគ្មានលិខិតអនុញ្ញាត ក្នុងករណីការសាងសង់ឬរុះរើនោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

**មាត្រា៥៥ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាកការងារសាងសង់ឬរុះរើដែលបានធ្វើឡើងខុសពីលិខិតអនុញ្ញាត និងតម្រូវឱ្យម្ចាស់សំណង់កែតម្រូវឱ្យស្របតាមលិខិតអនុញ្ញាត។

**មាត្រា៥៦ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការកែសម្រួលឬរុះរើរាល់សំណង់ដែលសាងសង់ដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការហាមឃាត់រាល់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

## ជំពូកទី១៤

## អធិការកិច្ចសំណង់

**មាត្រា៥៧ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៥៨ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសំណង់ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៩ .-**

មន្ត្រីអធិការកិច្ចសំណង់មានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្ដោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់នេះ
- ដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦០ .-**

មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៦១ .-**

រាល់ប្រតិបត្តិការអធិការកិច្ចសំណង់ក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្ដែងឬមិនមានលិខិតអនុញ្ញាតសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្ដល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។

## ជំពូកទី១៥
## វិសមិតភាព

**មាត្រា៦២ .-**

មន្ត្រីរាជការដែលមានសមត្ថកិច្ចត្រួតពិនិត្យនិង/ឬសម្រេចលើគម្រោងប្លង់មិនអាចជាអ្នកសិក្សាគម្រោងប្លង់ឬអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សាឬត្រួតពិនិត្យនិងបញ្ជាក់បានឡើយ។

**មាត្រា៦៣ .-**

មន្ត្រីអធិការកិច្ចសំណង់ មន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ មិនអាចជាម្ចាស់សំណង់ ឬជាសហព័ទ្ធ ឬជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣(បី)ថ្នាក់ ឬញាតិពន្ធក្នុង៣(បី)ថ្នាក់របស់ម្ចាស់សំណង់ ឬជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានឡើយ។

**មាត្រា៦៤ .-**

ការបំពេញមុខងារជាអ្នកសិក្សាគម្រោងប្លង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់របស់ខ្លួន។

**មាត្រា៦៥ .-**

ការបំពេញមុខងារជាអ្នកសាងសង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់របស់ខ្លួន។

**មាត្រា៦៦ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ (បី) ថ្នាក់របស់ម្ចាស់សំណង់បានឡើយ។

សមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ មិនអាចបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់សំណង់នោះបានឡើយ។

## ជំពូកទី១៦

## កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៦៧ .-**

កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងខអប្បបរមាដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យានិងកាលបរិច្ឆេទនិងរបៀបនៃការទូទាត់
- ការធានារបស់ភាគីនៃកិច្ចសន្យាចំពោះការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌបច្ចេកទេសនិងលក្ខខណ្ឌសុវត្ថិភាពនៃការងារ
- លក្ខខណ្ឌពាក់ព័ន្ធនឹងការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬឧបករណ៍និងគ្រឿងចក្រសម្រាប់បម្រើឱ្យការងារសាងសង់ឬរុះរើនិងសម្រាប់បំពាក់លើសំណង់
- លក្ខខណ្ឌនៃការកែប្រែនិងរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងឬបញ្ញត្តិផ្សេងទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយការងារ
- ការអះអាងអំពីអនុលោមភាពនៃគម្រោងប្លង់ដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើតាមបទប្បញ្ញត្តិជាធរមាន
- កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់ការងារនិងកាលបរិច្ឆេទប្រគល់ទទួល

- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

**មាត្រា៦៨ ..**

ចំពោះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន ខដែលរំលោភបំពានត្រូវទុកជាមោឃៈ។

ខដែលរំលោភបំពាននៅក្នុងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន មានដូចខាងក្រោម៖

១. ខដែលតម្រូវឱ្យម្ចាស់សំណង់ផ្តល់អាណត្តិឱ្យអ្នកម៉ៅការស្វែងរកកម្ចីចាំបាច់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់។

២. ខដែលតម្រូវឱ្យម្ចាស់សំណង់ធ្វើការទូទាត់តម្លៃនៃកិច្ចសន្យាទាំងស្រុងជាមុនដើម្បីឱ្យអ្នកម៉ៅការប្រគល់សំណង់មកម្ចាស់សំណង់។

៣. ខដែលហាមឃាត់ម្ចាស់សំណង់ឬតំណាងមិនឱ្យចូលពិនិត្យក្នុងការដ្ឋាន មុនការទូទាត់តម្លៃនៃកិច្ចសន្យាក្នុងដំណាក់កាលនីមួយៗនិងមុនការប្រគល់ទទួល។

៤. ខដែលតម្រូវឱ្យអ្នកម៉ៅការអនុវត្តការងារសាងសង់ឬរុះរើ តាមលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ដែលលក្ខខណ្ឌបច្ចេកទេសមានការប្រែប្រួលធ្ងន់ធ្ងរខុសពីលក្ខខណ្ឌបច្ចេកទេសនៃគម្រោងសាងសង់ ជួសជុល ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យា។

៥. ខដែលដោះបន្ទុកអ្នកម៉ៅការពីកាតព្វកិច្ចអនុវត្តការងារពេញលេញតាមពេលកំណត់ក្នុងកិច្ចសន្យាដោយទទួលស្គាល់មូលហេតុនៃការយឺតយ៉ាវផ្សេងៗ លើកលែងតែមូលហេតុប្រធានសក្តិនិងមូលហេតុដែលបង្កដោយម្ចាស់សំណង់ផ្ទាល់។

**មាត្រា៦៩ ..**

ភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ចឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ដូចខាងក្រោម៖

១. លទ្ធកម្មដីឬសិទ្ធិប្រត្យក្សដែលអនុញ្ញាតឱ្យសាងសង់ ក្នុងករណីដែលម្ចាស់សំណង់ទទួលបានការសន្យាលក់។

២. ការទទួលបានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ឬការអនុញ្ញាតផ្សេងទៀតរបស់អាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវបញ្ជាក់កាលបរិច្ឆេទដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យបានច្បាស់លាស់។

៣. ការទទួលបានកម្ចីដើម្បីធ្វើហិរញ្ញប្បទានដល់ការងារសាងសង់ឬរុះរើ។

៤. ការទទួលបាននូវការធានារ៉ាប់រងចំពោះការខូចខាតបង្កដោយការងារសាងសង់ឬរុះរើ។

៥. ការទទួលបាននូវការធានាការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ការដ្ឋានសំណង់។

**មាត្រា៧០.-**

ករណីយកិច្ចសម្រេចការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះរើដោយគ្មានវិការៈមានដូចខាងក្រោម៖

១- ការងារសាងសង់ត្រូវបានអនុវត្តស្របតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិ និងសេចក្តីណែនាំជាធរមានដទៃទៀត។

២- ការងារសាងសង់ត្រូវបានអនុវត្តដោយប្រើវិធីសាស្ត្រសមស្របនិងប្រកបដោយសមត្ថភាពជំនាញ។

៣- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវសមស្របតាមមុខងារប្រើប្រាស់អនុលោមតាមគម្រោងប្លង់និងមានគុណភាពត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេស។

៤- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវតែជាសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ថ្មី លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា។

**មាត្រា៧១.-**

រយៈពេលនៃការធានាចំពោះវិការៈនៃការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ គិតចាប់ពីថ្ងៃប្រគល់ទទួលសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ១០(ដប់)ឆ្នាំយ៉ាងតិច ចំពោះគ្រឿងផ្គុំសំណង់ធ្វើពីបេតុងសរសៃដែក បេតុងដែក ឬដែក។

ខ- ៥(ប្រាំ)ឆ្នាំយ៉ាងតិច ចំពោះជញ្ជាំងខាងក្រៅ បង្អួច ទ្វារ និងដំបូលអគារ។

គ- ២(ពីរ)ឆ្នាំយ៉ាងតិច ចំពោះការងារផ្នែកអគ្គិសនី ទឹក មេកានិក និងការងារពាក់ព័ន្ធផ្សេងទៀត។

គូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់អាចព្រមព្រៀងគ្នាកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារវែងជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ។

ការកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារខ្លីជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ត្រូវចាត់ទុកជាមោឃៈ។

## ជំពូកទី១៧

## ការធានារ៉ាប់រង

**មាត្រា៧២.-**

អ្នកម៉ៅការសាងសង់ឬរះរើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ឬរះរើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះរើ ដើម្បីផ្តល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារនិងតតិយជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឱ្យបើកការដ្ឋាន។

**មាត្រា៧៣.-**

ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានគឺជាបន្ទុករបស់អ្នកម៉ៅការសាងសង់ឬរុះរើនោះ។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្តប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ឬរុះរើបន្តទាំងអស់។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើជាមួយអ្នកម៉ៅការសាងសង់ឬរុះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ឬរុះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ឬរុះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។

**មាត្រា៧៤.-**

ក្នុងករណីប្រតិបត្តិការការងារសាងសង់ឬរុះរើរបស់គម្រោងអភិវឌ្ឍអចលនវត្ថុ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។

**មាត្រា៧៥.-**

ប្រភេទនិងទំហំសំណង់ដែលតម្រូវឱ្យមានការធានារ៉ាប់រងចំពោះការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១៨

## ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

**មាត្រា៧៦.-**

អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ប្រសិនបើគម្រោងប្លង់នៃសំណង់នោះមានវិការៈ លើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិតម្រូវជាធរមាន។

**មាត្រា៧៧.-**

នៅក្នុងពេលអនុវត្តការងារសាងសង់ឬរុះរើ ម្ចាស់សំណង់និងអ្នកសាងសង់ឬរុះរើត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការងារសាងសង់ឬរុះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ។

**មាត្រា៧៨.-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់របស់ខ្លួន។

**មាត្រា៧៩.-**

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។

**មាត្រា៨០ .-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងការខូចខាត ឬ
- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូតខាតបានកើតឡើង។

**មាត្រា៨១ .-**

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោម៖

១- នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឱ្យមានការខូចខាត។

២- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។

**មាត្រា៨២ .-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាត ឬ

២- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី១៩
## ការដោះស្រាយវិវាទក្នុងវិស័យសំណង់
### ផ្នែកទី១
### ការប្តឹងតវ៉ាក្នុងវិស័យសំណង់

**មាត្រា៨៣ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបណ្តឹងត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបណ្តឹង មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ាមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៤ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ ត្រូវប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន មុននឹងប្តឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

**មាត្រា៨៥ .-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសំណង់អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ ឬអាចប្ដឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្ដឹងតវ៉ា។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

## ផ្នែកទី២
## ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់ និងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៨៦ .-**

បុគ្គលដែលរងការខូចខាតឬមានការបារម្ភជាក់ស្ដែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិ ឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្ដឹងទៅតុលាការ។

សំណើសុំសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលរងផលប៉ះពាល់។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគីនៃវិវាទក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់សម្រេចបដិសេធសំណើសុំសម្រុះសម្រួល គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ។ ក្នុងករណីនេះម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់មិនអនុវត្តនីតិវិធីសម្រុះសម្រួលក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីភាគីវិវាទពុំអាចព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទដើម្បីបញ្ចប់វិវាទតាមការសម្រុះសម្រួលរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៧ .-**

ភាគីឬគូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចធ្វើសំណើមកគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួលនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើនោះ។

សំណើសុំការសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០( សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលវិវាទបានកើតឡើង។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយគូភាគីនៃវិវាទនិងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០( សាមសិប)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលសំណើសុំការសម្រុះសម្រួល។

ភាគីនៃវិវាទអាចសម្រេចចិត្តឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ប៉ុន្តែភាគីនៃវិវាទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការដោះស្រាយវិវាទសំណង់អំពីការឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ មុននឹងប្តឹងទៅតុលាការ។

**មាត្រា៨៨ .-**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក ក្នុងករណីមានសំណើសុំសម្រុះសម្រួលទៅគណៈកម្មការដោះស្រាយវិវាទសំណង់។

**មាត្រា៨៩ .-**

គណៈកម្មការដោះស្រាយវិវាទសំណង់មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ជាតិ

២- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី២០

## ទោសប្បញ្ញត្តិ

**មាត្រា៩០ ..**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើនិង/ឬសាងសង់ឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់និងទោសដាក់ពន្ធនាគារ។

**មាត្រា៩១ ..**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងក្នុងមាត្រានេះជូនដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩២ ..**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសំណង់អាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យសំណង់។

**មាត្រា៩៣ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលមិនមែនជាវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់ដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៤ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ដោយមិនបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៥ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យដោយគ្មានអាជ្ញាបណ្ណ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៦ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានលិខិតអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៧ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៣(បី)ខែ និងពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចជាលើកទីពីររបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

**មាត្រា៩៨ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលបានប្រើឬបំពាក់ក្នុងការសាងសង់នូវសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដាណាមួយជាក់លាក់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៩ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសិក្សាគម្រោងប្លង់ណាដែលបានសិក្សាគម្រោងប្លង់ដោយមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយការអនុវត្តតាមគម្រោងប្លង់នោះបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០០ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសាងសង់ដែលបានសាងសង់ឬរុះរើមិនអនុលោមតាមគម្រោងប្លង់និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០១ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៣០ ០០០ ០០០(សាមសិបលាន)រៀលទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលបានបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់ឬរុះរើថាត្រឹមត្រូវ ដែលតាមជាក់ស្តែង គម្រោងប្លង់ឬការងារសាងសង់ឬរុះរើនោះមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០២ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្មនូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០៣ .-**

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានការកាត់អវយវៈឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានមនុស្សស្លាប់។

**មាត្រា១០៤ ៈ**

ត្រូវផ្តន្ទាទោសដូចមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់នេះ កាលបើអំពើល្មើសដូចមានចែងក្នុងមាត្រាទាំងនោះ ប្រព្រឹត្តដោយនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់។

**មាត្រា១០៥ ៈ**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀលទៅ៨០ ០០០ ០០០(ប៉ែតសិបលាន) រៀល ចំពោះនីតិបុគ្គលណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានអាជ្ញាបណ្ណ។

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០ ០០០ ០០០(ហុកសិបលាន)រៀលទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី២១

## អន្តរប្បញ្ញត្តិ

**មាត្រា១០៦ ៈ**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន ម្ចាស់សំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ត្រូវមកដាក់ពាក្យស្នើសុំ

វិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ក្នុងរយៈពេលកំណត់ខាងលើ រាល់ទោសប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវបន្តអនុវត្តចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន។

**មាត្រា១០៧ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់នេះចូលជាធរមាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០៨ .-**

ក្រោយច្បាប់នេះចូលជាធរមានក្នុងរយៈពេល២(ពីរ)ឆ្នាំ មន្ទីរពិសោធន៍សំណង់ដែលបាននិងកំពុងប្រតិបត្តិការឬប្រកបអាជីវកម្មត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០៩ .-**

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចតម្រូវឱ្យអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់តម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចដកយកប្រាក់តម្កល់វិញនៅពេលឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មនោះ និងនៅពេលអាជ្ញាបណ្ណផុតសុពលភាពឬត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។

អ្នកទទួលសេវាពីអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដែលទទួលរងការខូចខាតមានឯកសិទ្ធិលំដាប់ទី២បន្ទាប់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំពោះប្រាក់តម្កល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

លក្ខខណ្ឌនិងនីតិវិធីនៃការតម្កល់ប្រាក់ ការដកប្រាក់តម្កល់ និងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ទៅតាមប្រភេទនៃអាជ្ញាបណ្ណដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE ★ LE MINISTERE DU PALAIS ROYAL

## ជំពូកទី២២

## អវសានប្បញ្ញត្តិ

**មាត្រា១១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១១១.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

នស/រកម/១១១៩/០១៩

នរ សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីសំណង់

## សទ្ទានុក្រម

**១- ការងារសំណង់**(construction work) សំដៅដល់ការងារសិក្សាគម្រោងប្លង់ ការងារវាស់វែង ការងារសាងសង់(building work) ការងាររុះរើ ការងារគ្រប់គ្រងការដ្ឋាន ការងារត្រួតពិនិត្យនិងបញ្ជាក់ ការងារសិក្សាពិសោធ ការងារគ្រប់គ្រងគម្រោងសាងសង់ ឬការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

**២- ការងារសិក្សាគម្រោងប្លង់**(design work) សំដៅដល់ការងារគូរប្លង់ ការងារសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យសម្រាប់ការងារស្ថាបត្យកម្មនិងវិស្វកម្ម ការងារផែនការ ការងាររៀបចំបញ្ជីប៉ាន់តម្លៃ ការងាររៀបចំសេចក្ដីណែនាំបច្ចេកទេស និងការងារគូរប្លង់លម្អិត។

**៣- ការងារវាស់វែង**(surveying work) សំដៅដល់ការសិក្សានិងវិភាគទិន្នន័យនិងព័ត៌មានដែលបានពីការវាស់ ការស្ទង់ ការធ្វើថានលេខា និងការសង្កេត សម្រាប់បម្រើដល់ការធ្វើផែនការ ការសិក្សាគម្រោងប្លង់ និងការងារសាងសង់។

**៤- ការងារសាងសង់**(building work) សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ និងការដំឡើង។

**៥- ការងារជួសជុល**(repair work) សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្ដូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

**៦- ការងារកែប្រែ**(modification work) សំដៅដល់ការផ្លាស់ប្ដូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

**៧- ការងាររុះរើ**(demolition work) សំដៅដល់ការងារដោះឬដកចេញនូវចំណែកណាមួយ ឬដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់។

**៨- ការងារត្រួតពិនិត្យនិងបញ្ជាក់**(certification work) សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់ លើគម្រោងប្លង់ ការគណនា សេចក្ដីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

**៩- ការងារសិក្សាពិសោធ**(testing work) សំដៅដល់ការសិក្សា ការវិភាគ និងការងារគណនាផ្នែកភូគព្ភសាស្ត្រ ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកឧបករណ៍និងគ្រឿងចក្រសំណង់ និងផ្នែកសម្ភារៈ បរិក្ខារ និងផលិតផលសំណង់។

**១០- ការងារគ្រប់គ្រងគម្រោងសាងសង់**(construction project management) សំដៅដល់ការងារដែលអ្នកគ្រប់គ្រងគម្រោងសាងសង់អនុវត្តក្នុងនាមម្ចាស់សំណង់ ដើម្បីធានាឱ្យគម្រោងសាងសង់ឬរុះរើដំណើរការទៅប្រកបដោយប្រសិទ្ធភាពលើពេលវេលា តម្លៃ គុណភាព និងសុវត្ថិភាព។

**១១- ការដកហូត**(revocation) សំដៅដល់ការសម្រេចនិរាករអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតក្នុងវិស័យសំណង់ ដោយអាជ្ញាធរ ឬមន្ត្រីមានសមត្ថកិច្ច។

**១២- កិច្ចសន្យាម៉ៅការសាងសង់**(construction contract) សំដៅដល់កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកសាងសង់ និងកិច្ចសន្យារវាងអ្នកសាងសង់និងអ្នកម៉ៅការសាងសង់ ឬរ៉ះរើបន្តដើម្បីអនុវត្តការងារសាងសង់ ឬរ៉ះរើ។

**១៣- គម្រោងប្លង់**(design document) សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់ មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ប្លង់ប្រព័ន្ធមេកានិក ប្លង់ប្រព័ន្ធអគ្គិសនី ប្លង់ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់ ប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ឬប្លង់ ឯកសារ និងសេចក្ដីណែនាំបច្ចេកទេសដទៃទៀត សម្រាប់ការងារសាងសង់ ឬរ៉ះរើនិងការប្រើប្រាស់សំណង់។

**១៤- តម្លៃនៃកិច្ចសន្យា**(contract fee) សំដៅដល់កម្រៃ ឬតម្លៃថ្នូរដទៃទៀតដែលម្ចាស់សំណង់ត្រូវបង់ជូនអ្នកសាងសង់តាមការកំណត់ក្នុងកិច្ចសន្យាសាងសង់។

**១៥- ប្រធានសក្តិ**(force majeure) សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

**១៦- បទប្បញ្ញត្តិបច្ចេកទេសសំណង់**(building technical regulations) សំដៅដល់បទដ្ឋានបច្ចេកទេស លក្ខខណ្ឌបច្ចេកទេស វិធានបច្ចេកទេសដែលមានលក្ខណៈបញ្ញា សម្រាប់អនុវត្តការងារសំណង់ដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

**១៧- បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម**(spatial and urban regulations) សំដៅដល់បទប្បញ្ញត្តិដែលមានចែងក្នុងបទដ្ឋានគតិយុត្តរៀបចំដែនដីនិងនគរូបនីយកម្ម ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

**១៨- បន្ទុក**(load) សំដៅដល់ទម្ងន់ សំពាធ ឬកម្លាំងទាំងឡាយដែលសង្កត់ ឬមានឥទ្ធិពលលើគ្រឿងផ្គុំសំណង់។

**១៩- បរិក្ខារសំណង់**(construction equipment) សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើងដើម្បីប្រើប្រាស់ ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ធើងងូតទឹក ម៉ាស៊ីនត្រជាក់ ជណ្ដើរយន្ត ទុយោ។

**២០- ផលិតផលសំណង់**(construction product) សំដៅដល់ផលិតផលសម្រេច ឬពាក់កណ្ដាលសម្រេចដែលកើតចេញពីការបង្កើត ឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង ម្រាងសិលា ស៊ីម៉ងតសី ស្នាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជ័រស្អិតការ៉ូ។

**២១- ផលិតករ**(producer) សំដៅដល់អ្នកផលិត អ្នកនាំចូល ឬបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬជាអ្នកលក់។

**២២. ម្ចាស់សំណង់**(construction owner) សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

**២៣. មន្ត្រីត្រួតពិនិត្យសំណង់**(construction controller) សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

**២៤. វិការៈ**(defect) សំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។

**២៥. វិញ្ញាបនបត្រប្រើប្រាស់សំណង់**(occupancy certificate) សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

**២៦. សំណង់ដែលមានសភាពគ្រោះថ្នាក់**(dangerous building) សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

**២៧. សំណង់**(construction) សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការ្យទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

**២៨. សម្ភារៈសំណង់**(construction material) សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ ដែក កញ្ចក់ ដីឥដ្ឋ សេរ៉ាមិក ឈើ។

**២៩. អ្នកសាងសង់**(builder) សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬរុះរើ អ្នកសាងសង់ឬរុះរើតាមជំនាញ ឬក្រុមជាងសំណង់។

**៣០. អ្នកអភិវឌ្ឍអចលនវត្ថុ**(real estate developer) សំដៅដល់ពាណិជ្ជករ វិនិយោគិន ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសាងសង់សំណង់សម្រាប់លក់ដើម្បីស្វែងរកផលចំណេញ។

**៣១. អាជ្ញាធរមានសមត្ថកិច្ច**(competent authority) សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**៣២. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់**(construction professional) សំដៅដល់ស្ថាបត្យករឬវិស្វករដែលបានចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជាឬគណៈវិស្វករកម្ពុជា ឬអ្នកជំនាញដែលបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យសំណង់។

**៣៣. អ្នកជំនាញក្នុងវិស័យសំណង់**(tradesperson) សំដៅដល់អ្នកបច្ចេកទេសសំណង់(កម្មករជំនាញ/ជាង) ដែលបានទទួលការបណ្តុះបណ្តាលដោយសាលាបច្ចេកទេសជំនាញពាក់ព័ន្ធឬដែលមានជំនាញនិងបទពិសោធក្នុងការអនុវត្តការងារសាងសង់ឬអ្នកជំនាញក្នុងវិស័យសំណង់ដែលពុំទាន់មានបង្កើតគណៈវិជ្ជាជីវៈ។

៣៤  **អ្នកគ្រប់គ្រងសំណង់**(building manager)  សំដៅដល់អ្នកដែលបានទទួលអាណត្តិឬសិទ្ធិគ្រប់គ្រងសំណង់ពីម្ចាស់សំណង់ក្នុងរយៈពេលកំណត់។